អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Feb-2012, 12:42
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី២៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ដេល លីសាក់
*(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មៃខល ផេសមិន
*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោកស្រី ជេត វណ្ណលី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ស៊ីន សុវ៉ន

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម យ៉ា សុខន | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**
សួរដោយលោក ម៉ៃខល ផេសមិន ផ្ដើមពី..................................................................ទំព័រ ២៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

តាមកាលវិភាគដែលបានគ្រោងទុក សវនាការនៅថ្ងៃនេះ គឺបន្តការដាក់ឯកសារចំពោះមុខភាគីដោយអង្គជំនុំជម្រះ ឬក៏អាចបន្តដោយការដាក់ឯកសាររបស់ភាគីពាក់ព័ន្ធនឹងរឿងក្តីនេះ ចំពោះមុខអង្គជំនុំជម្រះ។ ហើយមុននឹងចាប់ផ្តើមនូវកិច្ចដំណើរការ អង្គជម្រះសូមរំឭកទៅដល់ជនជាប់ចោទជាពិសេសគឺ លោក អៀង សារី ហើយនិងលោក ខៀវ សំផន ដែលអង្គជម្រះបានដឹងច្បាស់អំពីការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប មិនធ្វើអត្ថាធិប្បាយអ្វីផ្សេងៗ ចំពោះកិច្ចដំណើរការពិភាក្សាដេញដោលនៅក្នុងដំណាក់កាលនេះ ហើយដោយឡែកគឺលោក អៀង សារី គឺបានប្រើសិទ្ធិជារហូត។ ប៉ុន្តែអង្គជម្រះសូមរំឭកថា នាពេលនេះអង្គជម្រះរៀបចំនូវកិច្ចដំណើរការនីតិវិធីដាក់ឯកសារភស្តុតាងចំពោះមុខភាគី។ ដូច្នេះឱកាសនេះគឺ ជនជាប់ចោទមានឱកាសនៅក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើអត្ថាធិប្បាយផ្សេងៗទៅលើឯកសារ ដែលអង្គជម្រះបានដាក់ចំពោះមុខភាគី ឬក៏ភាគីបានដាក់ចំពោះមុខអង្គជម្រះ។ នេះជាសិទ្ធិប្រសិនបើជនជាប់ចោទប្រើសិទ្ធិនេះ។

ជាបន្តអង្គជម្រះសូមផ្តល់ភារៈជូនទៅលោកចៅក្រម យ៉ា សុខន ដើម្បីធ្វើនីតិវិធីដាក់ឯកសារភស្តុតាងនៅចំពោះមុខភាគី។

សូមអញ្ជើញលោកចៅក្រម។

[០៩:០៦:៣៦]

**ចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន។

អង្គជម្រះដាក់ឯកសារភស្តុតាង ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា នៅចំពោះមុខគូ-- មុខភាគីដូចខាងក្រោមនេះ៖

ឯកសារ E3/1 មេរៀនសង្ខេបស្តីពីប្រវត្តិចលនាបដិវត្តកម្ពុជា ដឹកនាំដោយបក្សកុម្មុយនីស្ត កម្ពុជា។ លេខ ERN ជាភាសាខ្មែរ 00699264 ដល់ 00699277។ លេខ ERN ជាភាសាអង់គ្លេស 00000364 ដល់ 00000377។ លេខ ERN ជាភាសាបារាំង 00699264 ដល់ 00699277។ ក្នុង ឯកសារនេះនិយាយសង្ខេបពីចលនាបដិវត្តន៍ និងទស្សនវិស័យនៃបក្សកុម្មុយនីស្តកម្ពុជា ហើយក៏និយាយ ផងដែរ អំពីមនោគមវិជ្ជា និងយុទ្ធសាស្ត្រ ដើម្បីឲ្យបដិវត្តសង្គមនិយមមួយអាចសម្រេចបាននៅក្នុង ប្រទេសកម្ពុជា។ សូមដាក់ឯកសារទាំងមូល។

[០៩:០៨:២៦]

តើជនជាប់ចោទមានបំណងធ្វើអត្ថាធិប្បាយលើឯកសារនេះឬទេ? លោក នួន ជា? លោក ខៀវ សំផន?

**លោក ខៀវ សំផន៖**

សូមគោរពអង្គសវនាការ។ ខ្ញុំបាទអត់មានអត្ថាធិប្បាយអីទេនៅពេលនេះ។ សូមអរគុណ។

**ចៅក្រម យ៉ា សុខន៖**

លោក អៀង សារី?

[០៩:១០:១០]

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកចៅក្រម កូនក្តីរបស់ខ្ញុំចង់ឆ្លើយតប ប៉ុន្តែគាត់មិនអាចតាមបាននូវខ្លឹម សារនោះទេ ដោយហេតុថាមិនបានបង្ហាញឯកសារនោះជូនគាត់លោកចៅក្រម បាទ។

**លោក នួន ជា៖**

ថាម៉េច?

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការបង្ហាញឯកសារ ដែលបានលើកឡើងដោយចៅក្រមអម្បាញ់មិញនេះ ដែលជា ឯកសារដាក់នៅចំពោះមុខភាគី ដែលនៅលើអេក្រង់ទូរទស្សន៍ ហើយនិងនាំយកឯកសារ ជាក្រដាស ជូនទៅលោក-- ទៅជនជាប់ចោទ នួន ជា។

បាទ សូមអញ្ជើញលោក នួន ជា!

[០៩:១១:១៩]

**លោក នួន ជា៖**

សូមឲ្យអត្ថាធិប្បាយម្ដងទៀតមក អំមិញខ្ញុំស្ដាប់មិនច្បាស់។ ត្រចៀកខ្ញុំ វាធឿងអស់ហើយ។

**ចៅក្រម យ៉ា សុខន៖**

ឯកសារនេះ និយាយសង្ខេបពីចលនាបដិវត្តន៍ និងទស្សនវិស័យនៃបក្សកុម្មុយនីស្ដកម្ពុជា។ ហើយក៏និយាយផងដែរ អំពីមនោគមវិជ្ជានិងយុទ្ធសាស្ត្រដើម្បីឲ្យបដិវត្តន៍សង្គមនិយមមួយអាចសម្រេចបាននៅក្នុងប្រទេសកម្ពុជា។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារជាក្រដាសទៅជូនទៅលោក នួន ជា។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៥:៥៣]

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ឯកសារ-- មិនទាន់ទេ ចង់បានឯកសារដើម។ សូមស្នើលោកប្រធាន សុំឯកសារដើម។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ អំពីការប្រើប្រាស់ឯកសារ នៅចំពោះមុខអង្គជំនុំជម្រះនោះមិនចាំបាច់ឯកសារដើមទេ។ ឯកសារដែលនៅក្នុងសំណុំរឿងនេះ ប្រសិនបើមិនមានភស្តុតាងបញ្ជាក់ថាឯកសារនោះក្លែងក្លាយទេ គឺជាឯកសារដែលពាក់ព័ន្ធដែលអាចដេញដោលបានហើយ។ បញ្ហាដែលសំខាន់នេះ គឺលោកមានមតិយោបល់អ្វីទេ លើខ្លឹមសារនៃឯកសារដែលបានជម្រាបជូនទៅហ្នឹង តែប៉ុណ្ណឹងទេ។

**លោក នួន ជា៖**

ខ្ញុំអានមិនទាន់ទេ។

**ប្រធានអង្គជំនុំ៖**

ហើយបើមិនទាន់ទេ លោកអាចជ្រាបបញ្ហាឯកសារពាក់ព័ន្ធនឹងទៅ ហើយពេលណាដែលលោកមានឱកាស លោកសិក្សារួចហើយ លោកអាចធ្វើអត្ថាធិប្បាយបាន នៅពេលក្រោយ ជាពិសេសគឺនៅក្នុងសប្ដាហ៍ក្រោយនេះ ដែលជាកិច្ចដំណើរការនៃការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញតទៀត លោកចៅក្រម!

[០៩:១៧:២១]

**ចៅក្រម យ៉ា សុខន៖**

ឯកសារ E3/95 កំណត់ហេតុនៃការពិភាក្សាដេញដោលរបស់លោក អៀង សារី ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៧។ លេខ ERN ជាភាសាខ្មែរ 00153377។ លេខ ERN ជាភាសាអង់គ្លេស 00153391។ លេខ ERN ជាភាសបារាំង 00153403។ នៅក្នុងកំណត់ហេតុនោះ លោក អៀង សារី បានបញ្ជាក់ថា ខ្ញុំសូមបញ្ជាក់ថា ឈ្មោះកំណើតរបស់ខ្ញុំ គឺ គឹម ត្រឹង។ ឈ្មោះនេះត្រូវគ្នានឹងឆ្នាំ និងទីកន្លែងកំណើតខាងលើ។ ខ្ញុំបានប្តូរឈ្មោះនេះ នាពេលដែលខ្ញុំសុំប្តូរសំបុត្រកំណើត ដើម្បីអាចប្រឡងចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ ហើយបានយកឈ្មោះ អៀង សារី ពីពេលនោះមក។ ខ្ញុំយល់ព្រមក្នុងការប្រើឈ្មោះ អៀង សារី នៅក្នុងដំណើរការនីតិវិធីនេះ។

តើជនជាប់ចោទមានបំណងធ្វើអត្ថាធិប្បាយលើឯកសារនេះឬទេ លោក អៀង សារី?

[០៩:១៩:១៥]

**ប្រធានអង្គជំនុំ៖**

គាត់រក្សាសិទ្ធិមិនឆ្លើយតប។ ចាត់ទុកថា គាត់រក្សាដដែល មិនប្រែប្រួលទេ ហើយសូមបន្តកិច្ចការរបស់លោកចៅក្រមតទៅទៀត។

បើកក្បាលមេក្រូសិន សឹមនិយាយ!

**ចៅក្រម យ៉ា សុខន៖**

ឯកសារ E3/19 ជីវប្រវត្តិរបស់លោក អៀង សារី។ លេខ ERN ភាសាខ្មែរ 00586668។ លេខ ERN ជាភាសាអង់គ្លេស 00555704។ លេខ ERN ជាភាសាបារាំង 00391415។

ជីវប្រវត្តិនេះ លោក អៀង សារី បានសរសេរថា កើតនៅថ្ងៃទី១ មករា ឆ្នាំ១៩៣០ នៅបារាយខេត្តព្រៃវែង ប្រទេសកម្ពុជា។

សិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិភ្នំពេញ បន្ទាប់មកនៅប្រទេសបារាំងសាលាបណ្តុះបណ្តាល ជាន់ខ្ពស់។ ឆ្នាំ១៩៥១ បានចូលរួមក្នុងមហោស្រពយុវជនអន្តរជាតិ នៅទីក្រុងប៊ែរឡាំងខាងកើត។ ឆ្នាំ១៩៥៣ ត្រូវបានកាត់ផ្តាច់អាហារូបករណ៍សិក្សានៅប្រទេសបារាំង ដោយមូលហេតុធ្វើសកម្មភាពនយោបាយ។

[០៩:២០:៥៨]

ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៥៦ ប្រធានសម្ព័ន្ធទូទៅនិស្សិតខ្មែរប្រចាំនៅប្រទេសបារាំង។ ឆ្នាំ១៩៥៨ សាស្ត្រាចារ្យ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ភ្នំពេញ។ ត្រូវបានចាត់ ទុកជាកម្មាភិបាលកុម្មុយនីស្តទទួលបន្ទុកធ្វើសកម្មភាពក្នុងមជ្ឈដ្ឋានគ្រូបង្រៀនខ្មែរ មានទំនាក់ទំនងស្និតរមួតជាមួយស្ថានទូតសូវៀតនៅភ្នំពេញ។ ខែកក្កដា ឆ្នាំ១៩៦៣ បានចាកចេញពីភ្នំពេញ ចូលព្រៃម៉ាគី ខ្មែរក្រហម។ ឆ្នាំ១៩៧១, ៧២, ៧៣ អ្នកតំណាងចលនាតស៊ូផ្ទៃក្នុងប្រទេសប្រចាំរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅប៉េកាំង។

ចាប់តាំងពីចុងឆ្នាំ១៩៧៣ ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំនៅតំបន់រំដោះ។ ធ្វើដំណើរជាញឹកញាប់ទៅកាន់ប្រទេសចិន និងវៀតណាមខាងជើង។ តើលោកអៀង សារី មានបំណងធ្វើអត្ថាធិប្បាយនៅលើឯកសារនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ចាត់ទុកថា គាត់នៅរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយកិច្ចដំណើរការនីតិវិធីអំណើះតទៅសូមលោកចៅក្រមបន្តនីតិវិធីធម្មតា មិនបាច់សួរគាត់ថែមទៀតទេ កាលបើគាត់មានបំណងក្នុងការធ្វើអត្ថាធិប្បាយ សូមឲ្យលោក អៀង សារី លើកដៃ ដើម្បីសូមធ្វើការធ្វើអត្ថាធិប្បាយចំពោះឯកសារណាដែលលោកមានបំណងធ្វើដូច្នេះ។

សូមអញ្ជើញលោកមេធាវីការពារ អៀង សារី។

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់នៅក្នុងសវនាការ។ ក្នុងរយៈពេលបួនឆ្នាំកន្លងមក នៅក្នុងសាលាក្តីអន្តរជាតិ ដែលនឹងអនុវត្តនូវស្តង់ដារអន្តរជាតិនោះ ខ្ញុំមិនដឹងថា មានតុលាការអន្តរជាតិណាមួយ ឬក៏តុលាការជាតិណាមួយ ដែលទទួលបានមូលនិធិពីអង្គការសហប្រជាជាតិ ដែលបន្តទទូច ហើយតាំងសំណួរទៅជនជាប់ចោទ ទោះបីជាជនជាប់ចោទនោះបានចង្អុលបង្ហាញយ៉ាងច្បាស់ថា គ្មានលក្ខខណ្ឌថា ដែលខ្លួនរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ។

[០៩:២៣:៤៤]

ដូច្នេះ ខ្ញុំគិតថានេះជាការបំពានដំណើរការនីតិវិធី។ លោក អៀង សារី គាត់បង្ហាញថា គាត់មិនឆ្លើយសំណួរអ្វីទេ។ ការស្នើសុំឲ្យគាត់បញ្ជាក់យោបល់ មិនខុសអ្វីពីការឲ្យសួរឲ្យគាត់ឆ្លើយនោះទេ។ ដូច្នេះហើយនេះជាទម្រង់នៃការបង្ខិតបង្ខំគាត់។ ដូច្នេះសូមតុលាការជ្រាប លោកប្រធានជ្រាបថា ការ

ទទួចបែបនេះ ការប្រើវិធីនេះគឺសូមឲ្យសម្រេចបញ្ឈប់ការប្រើនីតិវិធីបែបនេះតទៅទៀត។ ប្រសិនបើគាត់មានចេតនានឹងធ្វើអត្ថាធិប្បាយ មិនបញ្ហាអ្វីនោះទេ។

ចំពោះខ្ញុំ ខ្ញុំយល់ឃើញថា នេះជាទម្រង់នៃការបង្ខិតបង្ខំមួយឲ្យជនជាប់ចោទ ដែលជាការបំពានទៅលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់គាត់។ មិនមានយុត្តាធិការច្បាប់ណាមួយរបស់ប្រទេសបារាំងនោះទេ។ នេះជាតុលាការកម្ពុជា ជាតុលាការអន្តរជាតិ ត្រូវអនុវត្តនូវបទដ្ឋានអន្តរជាតិ មិនមែនជាស្តង់ដារជាតិ នៅក្នុងយុត្តាធិការពីបុរាណនោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យតុលាការកុំអនុវត្តនូវនីតិវិធីនេះតទៅទៀត ដើម្បីកុំឲ្យខាតពេលវេលា និងបន្ថយពេលវេលា និងខ្ជះខ្ជាយធានធនតុលាការផងដែរ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៥:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី តែអង្គជំនុំជម្រះសូមជម្រាបថា កិច្ចនីតិវិធីដែលអង្គជំនុំជម្រះធ្វើដូច្នេះ ក្នុងន័យគោរពសិទ្ធិនៅក្នុងការធ្វើការកត់សម្គាល់ ធ្វើការអត្ថាធិប្បាយឯកសារពាក់ព័ន្ធ ឯកសារភស្តុតាងពាក់ព័ន្ធនឹងខ្លួនដែលត្រូវប្រឈមនឹងការចោទប្រកាន់ប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនបានដាក់កាតព្វកិច្ចឲ្យទៅលោក អៀង សារី ទេ នៅក្នុងអត្ថន័យ គឺផ្តល់ឱកាសឲ្យគាត់ប៉ុណ្ណោះ។ ការធ្វើដូច្នេះមិនមានហេតុផលណាមួយ ដែលអង្គជំនុំជម្រះដាក់សម្ពាធ ឬការគាបសង្កត់បង្ខំទៅលើជនជាប់ចោទនោះឡើយ។ ការគោរពសិទ្ធិដល់ជនជាប់ចោទ វាមិនមែនជាការបង្ខិតបង្ខំនោះឡើយ។

អញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន ហើយបើរឿងដដែលទេមិនបាច់និយាយទេ លើកលែងតែរឿងផ្សេងទៀត។

[០៩:២៧:១១]

**លោក គង់ សំអុន៖**

ខ្ញុំបាទចង់លើកបញ្ហាក់ពីចំណុចនេះ ប៉ុន្តែចង់ធ្វើការកត់សម្គាល់ចំពោះសេចក្តីពន្យល់របស់លោកប្រធានអម្បាញ់មិញនេះ។ បាទ បើអនុញ្ញាត ខ្ញុំនឹងបាទនឹងធ្វើ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីបានលើកឡើង ប៉ុន្តែលោកមេធាវីត្រូវប្រើសិទ្ធិរបស់លោកឲ្យបានត្រឹមត្រូវ លោកមិនអាចធ្វើការកត់សម្គាល់អ្វីមកលើអង្គជំនុំជម្រះសម្ដី ពាក្យពេចន៍របស់យើងនិយាយនោះទេ។

សូមអញ្ជើញលោក យ៉ា សាខន!

[០៩:២៨:០៥]

**ចៅក្រម យ៉ា សុខន៖**

ឯកសារE3/144 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផាន សុវណ្ណហាន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ របស់សហចៅក្រមស៊ើបអង្កេត អ.វ.ត.ក។ លេខERN ជាភាសាខ្មែរ 00287712។ ERN ជាភាសាអង់គ្លេស 00295161។ លេខERN ជាភាសាបារាំង 00353125។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីនេះ សាក្សីបានឆ្លើយថា៖ “ក្នុងឆ្នាំ១៩៧០ ខ្ញុំបានទៅហាណូយជាមួយ អៀង សារី, អៀង ធីរិទ្ធ និងកងការពាររបស់គាត់ពីរនាក់ និងក្មេងប្រុសពីរនាក់ ស្រីម្នាក់ គឺខ្ញុំ។ ខ្ញុំជាអ្នកច្រៀងនៅក្នុងក្រុមកុមាររួមគ្នាផ្សាយតាមវិទ្យុ”។

តើជនជាប់ចោទមានបំណងធ្វើអត្ថាធិប្បាយលើឯកសារនេះដែរឬទេ?

[០៩:២៩:២៨]

**ប្រធានអង្គជំនុំ៖**

បន្តទៀត យើងដូចប្រាប់ហើយ មិនចាំបាច់ធ្វើនីតិវិធីនេះទេ ប្រសិនបើជនជាប់ចោទរូបណាគាត់មានបំណងគឺគាត់លើកដៃសូមនិយាយ បើអត់ទេគឺធ្វើដំណើរនីតិវិធីតទៅមុខរហូតដល់ចប់ទៅ។ លោកចៅក្រម យើងបាននិយាយរួចហើយ។

**ចៅក្រម យ៉ា សុខន៖**

ឯកសារE3/16 សៀវភៅនិពន្ធដោយលោក ខៀវ សំផន ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ។ លេខ ERN ជាភាសាខ្មែរ 00380364 ដល់ 00380365។ លេខ ERN ជាភាសាអង់គ្លេស 00498230។ លេខ ERN ជាភាសាបារាំង 00643833។ នៅក្នុងសៀវភៅនោះបានសរសេរថា៖ “បក្សថ្មីឈ្មោះបក្សពលករកម្ពុជា”។ តាមលោក អៀង សារី ប្រាប់លោក ហ្វីលីព សត ថា ឈ្មោះនេះដឹងតែអ្នកដែលបានចូលរួមសន្និបាតទេ មិនមានកត់ត្រាក្នុងកម្មវិធីនយោបាយ ឬក្នុងលក្ខន្តិកៈទេ គ្រាន់តែមាននិយាយអំពីបក្សកម្ពុជាប៉ុណ្ណោះ។ ឯវៀត-

ណាមវិញដឹងតែឈ្មោះចាស់ប៉ុណ្ណោះ គឺបក្សបដិវត្តន៍នៃប្រជាជនកម្ពុជា ប.ប.ប.ក។ គេកំណត់ថា បក្សនេះជាបក្សរបស់ពលករដោយយកលទ្ធិម៉ាក្ស-លេនីន ធ្វើជាមូលដ្ឋាន នៅជាប់ជិតស្និទ្ធជាមួយមហាជនមានការចាត់តាំង ឈរលើមូលដ្ឋាននៃប្រជាធិបតេយ្យប្រមូលផ្តុំ ប្រើការទិតៀន និងស្វ័យទិតៀនជាគោលការណ៍ដឹកនាំ។

ក្នុងឯកសារនេះដែរ លេខ ERN ជាភាសាខ្មែរ 00380371។ លេខ ERN ជាភាសាអង់គ្លេស 0046498235 ដល់ 00498236។ លេខ ERN ជាភាសាបារាំង 00643839។ នៅក្នុងសៀវភៅនេះក៏សរសេរដែលថា៖ "ចុងខែកុម្ភៈ ឆ្នាំ១៩៦៣ មហាសន្និបាតលើកទីពីរក៏បានកោះប្រជុំ ដើម្បីប្រថាប់ត្រាលោក សាឡុត ស ជាលេខាបក្ស។ នួន ជា នៅជាអ្នកទីពីរដដែល។ អៀង សារី និង សោ ភឹម ទៅជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍"។

[០៩:៣២:៥៦]

នៅក្នុងឯកសារដដែលនេះដែរ លេខ ERN 00380378 ដល់ 00380379។ លេខ ERN ជាភាសាអង់គ្លេស 00498237។ លេខ ERN ជាភាសាបារាំង 00643841។ នៅក្នុងឯកសារនេះបានសរសេរថា៖ "នៅក្នុងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា លោក សាឡុត ស ក៏ប្រកាស សមាជិកគណៈអចិន្ត្រៃយ៍ទាំងបីនាក់ ដែលមានឈ្មោះក្នុងបញ្ជីត្រូវតែចាកចេញពីភ្នំពេញ។ ម៉្យាងទៀតគំនិតនេះមានជាពន្លកតាំងពីឆ្នាំ១៩៦០ មកម្ល៉េះ មកហើយ។ ថ្ងៃក្រោយមកលោក អៀង សារី បានប្រាប់លោកហ្វីលីព សត ថា គាត់បានប្រឆាំងនឹងគំនិតនេះ។ គាត់យល់ថា មុននឹងចេញពីទីក្រុងភ្នំពេញ បក្សត្រូវមានមូលដ្ឋានរបស់ខ្លួននៅជនបទសិន ហើយត្រូវមានបណ្តាញនៅក្នុងទីក្រុងឲ្យរឹងមាំ។ ប៉ុន្តែលោក នួន ជា ដែលគាត់អត់មានឈ្មោះនៅក្នុងបញ្ជី៣៤នាក់ ដូច្នេះមិនទាន់បែកឈ្មោះថា គាត់ធ្វើសកម្មភាពអ្វីទេ។ ក៏គូសសង្កត់ថា អ្នកដឹកនាំដែលបែកឈ្មោះ ហើយមិនត្រូវនៅតទៅទៀតទេ។ បើមិនដូច្នេះ នឹងនាំឲ្យប៉ះពាល់ដល់គេឯងផ្សេងទៀត ដូច្នេះលោក អៀង សារី ក៏យល់ស្របតាមដោយមិនអស់ចិត្តទេ។ នេះជាផ្លូវបត់ទីពីរធំរបស់ចលនា"។

[០៩:៣៤:៥៨]

ឯកសារ E3/10 ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជាក្រោមចំណងជើងថា "ទង់បដិវត្តលេខពិសេស ខែកញ្ញា តុលា ឆ្នាំ១៩៧៦"។ លេខ ERN ជាភាសាខ្មែរ 00063064 ដល់ 00063065 ERN ជាភាសាអង់គ្លេស 00450506 លេខ ERN ជាភាសាបារាំង 00491872។ នៅក្នុងទស្សនាវដ្តីនេះ បាន

សរសេរថា៖ "លុះដល់ថ្ងៃទី៣០ ខែ៩ ឆ្នាំ១៩៦០ ទើបយើងរៀបចំមហាសន្និបាតលើកទីមួយ របស់បក្ស នៅទូទាំងប្រទេស។ ពេលនោះ មានបំណង មានតំណាងនៅគ្រប់មូលដ្ឋាន មកចូលរួមប្រជុំ មាន សមាជិកជិត២០នាក់ យើងធ្វើការប្រជុំក្នុងពេលដែលខ្មាំងវាវាតត្បាតខ្លាំង វាចាប់ដាក់គុកច្រវាក់ វាកាប់ សម្លាប់។ អង្គការចំហរបស់យើងនៅទីក្រុងត្រូវរងគ្រោះ ឯនៅជនបទក៏ខ្មាំងធ្វើសកម្មភាព *ហ្វាស៊ីស* កម្ទេចមូលដ្ឋាន និងកម្មាភិបាលយើងខ្ទេចខ្ទី។ ទោះបីស្ថិតនៅក្នុងសភាពនេះក្តី ក៏យើងរៀបចំធ្វើមហា សន្និបាតលើកទីមួយបាននៅភ្នំពេញ ដោយយើងយល់ថា បើបក្សគ្មានលក្ខន្តិកៈ គឺគ្មានខ្លឹមសារ មិនដឹង ឈរលើអី ទាល់តែមានលក្ខន្តិកៈទើបយើងមានឯកសារជាមូលដ្ឋាន។ ទន្ទឹងនេះ យើងប្តេជ្ញារៀបចំមាគ៌ា ជាយុទ្ធសាស្ត្រ និងជាយុទ្ធវិធីរបស់យើង។ ព្រោះតាមពិសោធមកបើគ្មានមាគ៌ាជាយុទ្ធសាស្ត្រ និងជា យុទ្ធវិធីទេ យើងគ្មានទិសដៅ យើងដឹកនាំចលនាទាំងងងឹតងងុលគឺគ្រោះថ្នាក់ដល់កម្លាំងប្រជាជនណាស់។ ដូច្នោះត្រូវរៀបចំលក្ខន្តិកៈផង រៀបចំមាគ៌ាជាយុទ្ធសាស្ត្រ និងជាយុទ្ធវិធីនៃបដិវត្តន៍ប្រជាជាតិប្រជា ធិបតេយ្យផង។ យើងរៀបចំឯកសារនេះជាមូលដ្ឋានហើយ ទាល់តែមានមហាសន្និបាតទូទាំងប្រទេស របស់បក្សអនុម័តសម្រេច។ ដូច្នេះហើយបានជាមានមហាសន្និបាតលើកទីមួយប្រជុំនៅភ្នំពេញ"។

[០៩:៣៨:០២]

ឯកសារ E3/50 សារាចររបស់បក្សកុម្មុយនីស្តកម្ពុជាចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧១ ក្រោម ចំណងជើងថា៖ "ខួបឆ្នាំទីបីនៃការចាត់តាំងសហករណ៍"។ លេខ ERN ជាភាសាខ្មែរ 00442210។ លេខ ERN ជាភាសាអង់គ្លេស 00636010។ លេខ ERN ជាភាសាបារាំង 00623784។

នៅក្នុងសារាចរនោះបាននិយាយថា៖ "សហករណ៍ជំរុញចលនាឲ្យវាយសម្រុកខ្លាំងនៅសមរភូមិ មុខទាំងយោធា ទាំងនយោបាយ ទាំងសេដ្ឋកិច្ច។ បក្សបំផុសចលនាសមូហភាពរូបនីយកម្មជនបទនៅ ឆ្នាំ១៩៧៣។ ឆ្នាំ១៩៧៣ ជាឆ្នាំវាយសង្គ្រាមអាកាសដ៏សាហាវឃោរឃៅព្រៃផ្សៃរបស់ចក្រពត្តិអាមេរិក។ យើងវាយឈ្នះទាំងសង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិក ទាំងកងទ័ពពួកអាក្បត់ ហើយចូលកៀកដល់ ទីក្រុងភ្នំពេញធ្វើឲ្យស្ថានការណ៍ខ្មាំងប្រែប្រួលយ៉ាងខ្លាំង ទាំងនយោបាយ ទាំងយោធា ទាំងសេដ្ឋកិច្ច។ ឆ្នាំ១៩៧៤ ជាការវាយសម្រុកភ្នំពេញ និងជុំវិញភ្នំពេញរយៈកាលទីមួយ។ ឆ្នាំ១៩៧៥ ជាការវាយសម្រុក ផ្តាច់ព្រាត់។ នេះជាលទ្ធផលជាក់ស្តែង នៃការសម្រេចរបស់បក្ស។ ថ្ងៃ២០ ឧសភា ឆ្នាំ១៩៧៣ ចាត់តាំង សហករណ៍កសិករទូទាំងប្រទេស បើគ្មានសហករណ៍ទប់ទល់សង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិក ក៏មិនបាន វាយផ្តាច់ខ្មាំងក៏មិនដាច់"។

[០៩:៤០:២៤]

ឯកសារ E3/94 បទសម្ភាសរបស់ អេលីហ្សាប៊េត បេកយ័រ ជាមួយលោក អៀង សារី នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៨១ នៅទីក្រុងញូវយ៉ក។ លេខ ERN អក្សរខ្មែរ 00578892 ។ ERN ជាភាសាអង់គ្លេស 00342500។ លេខ ERN ជាភាសាបារាំង 00601999។ នៅក្នុងបទសម្ភាសនោះ បាននិយាយថាៈ "មានមូលហេតុច្រើន មូលហេតុមួយ គឺការភ័យខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ នៅពេលនោះសាយហ្គន មិនទាន់រំដោះឡើយទេ។ ខ្ញុំទើបតែមកដល់ភ្នំពេញ នៅថ្ងៃទី២៤ ខែមេសា តែប៉ុណ្ណោះ។ ខ្ញុំបានដឹងពីការជម្លៀសតាមតែរបាយការណ៍តែប៉ុណ្ណោះ"។

ឯកសារ E3/2 ប្រវត្តិសង្ខេប ពីគណបក្សកុម្មុយនីស្តខ្មែរ 1/75។ លេខ ERN ជាភាសាខ្មែរ 00679877 ដល់ 00679883។ លេខ ERN ជាភាសាអង់គ្លេស 00444348 ដល់ 00444354។ លេខ ERN ជាភាសាបារាំង 00657347 ដល់ 00657351។ យោងតាមការបញ្ជាក់នៅក្នុងឯកសារនេះ វាត្រូវបានបោះពុម្ពដោយអង្គភាពនយោបាយយោធារបស់ការិយាល័យមជ្ឈិមប្រចាំភូមិភាគបូព៌ារបស់គណបក្សកុម្មុយនីស្តកម្ពុជា។ ប្រហែលក្នុងពេលរៀបចំខួបលើកទី២២ ខែកញ្ញា ឆ្នាំ១៩៧៣ និងនិយាយអំពីប្រវត្តិបក្សដោះស្រាយបញ្ហា និងគោលបំណងរបស់បក្ស ពីឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៦៧។

[០៩:៤៣:២៥]

ឯកសារ E3/92 កំណត់ហេតុនៃការចូលខ្លួនដំបូង របស់លោក អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧។ លេខ ERN ជាភាសាខ្មែរ 00152279 ដល់ 00152283។ លេខ ERN ជាភាសាអង់គ្លេស 00153311 ដល់ 00153314។ លេខ ERN ជាភាសាបារាំង 00153325 ដល់ 00153328។ សូមដាក់ឯកសារទាំងមូល។ ក្នុងកំណត់ហេតុនេះ លោក អៀង សារី បានបញ្ជាក់មុខរបរមុនបដិវត្តន៍ ជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រ និងភូមិវិទ្យានៅអនុវិទ្យាល័យកម្ពុជបុត្រ។ មុខរបរក្នុងរបបក្នុងរបបកម្ពុជាជាបន្តបន្ទាប់ "ខ្ញុំជាបេសកជនពិសេស នៃអ្នកតស៊ូផ្ទៃក្នុងនៅប៉េកាំង ដើម្បីទំនាក់ទំនងជាមួយប្រមុខរដ្ឋ នរោត្តម សីហនុ និងចាប់ពីថ្ងៃ២៣ មេសា ឆ្នាំ១៩៧៥ ខ្ញុំធ្វើជាអ្នកទទួលភ្ញៀវបរទេសនៅក្រសួងកិច្ចការបរទេស និងរៀបចំសារមន្ទីរជាតិឡើងវិញ។ ចាប់ពីថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧១ ខ្ញុំមិនចាំថ្ងៃច្បាស់ទេ ខ្ញុំជាឧបនាយករដ្ឋមន្ត្រីទីមួយ និងជារដ្ឋមន្ត្រីក្រសួងការបរទេស"។

[០៩:៤៥:៥០]

ឯកសារ E3/15 សេចក្តីថ្លែងការណ៍របស់ ឌុច លេខ ERN ជាភាសាខ្មែរ 00234070។ លេខ ERN ជាភាសាអង់គ្លេស 00251372។ លេខ ERN ជាភាសាបារាំង 00234089។ ក្នុងសេចក្តីថ្លែងការណ៍ឌុច នោះបាននិយាយថា៖ “១)លក្ខន្តិកៈបក្ស។ ២)មាគ៌ានយោបាយជាយុទ្ធសាស្ត្រ នៃការតស៊ូបក្សបដិវត្តន៍នៅកម្ពុជា និងគោលនយោបាយជាយុទ្ធវិធី នៃការប្រមូលកម្លាំងរណសិរ្សធំទូលាយ វាយឈ្នះខ្មាំងក្នុងបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ”។ ឯកសារទាំងពីរនេះ អនុម័តនៅក្នុងមហាសន្និបាតបក្សលើកទី១ ថ្ងៃទី៣០ កញ្ញា ឆ្នាំ១៩៦០។

[០៩:៤៦:៥៨]

ឯកសារ E3/24 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ឈ្មោះហៅក្រៅ វីជាម ចុះថ្ងៃទី៥ ខែ១២ ឆ្នាំ២០០៧ នៅខេត្តបន្ទាយមានជ័យរបស់សហចៅក្រមស៊ើបអង្កេត។ លេខ ERN ជាភាសាខ្មែរ 00204067។ ERN ជាភាសាអង់គ្លេស 00223580។ លេខ ERN ជាភាសាបារាំង 00503919។ សាក្សីបានឆ្លើយថា៖ “ឆ្នាំ១៩៦៧ ខ្ញុំបានជួប អៀង សារី នៅកន្ទុយនាគ នៅខេត្តរតនគីរី។ អៀង សារី គាត់មានសំបុត្រឲ្យខ្ញុំយកទៅឲ្យវៀតណាម ដែលជាតំណាងមជ្ឈិមរបស់វៀតណាម ដើម្បីរំដោះភាគខាងត្បូងវៀតណាម។ បន្ទាប់មក ខែ១២ ឆ្នាំ១៩៦៧ ខ្ញុំបានជួប ប៉ុល ពត ពេលនោះ គឺគាត់ឈឺ ខ្ញុំបានសែងគាត់យកទៅដេកពេទ្យវៀតណាម។ ខ្ញុំនៅជាប់ជាមួយ អៀង សារី។ អៀង សារី នៅមន្ទីរ១០២ គឺជាមន្ទីររបស់គាត់។ ចំណែក ប៉ុល ពត នៅមន្ទីរ១០០ នៅឆ្ងាយពីគ្នាប្រហែល៣គីឡូ នៅក្នុងព្រៃ-- ៣គីឡូម៉ែត្រនៅក្នុងព្រៃ។ ឆ្នាំ៦៨ ដល់៦៩ ខ្ញុំនៅទីនេះរហូត។ ចុងឆ្នាំ១៩៦៩ ប៉ុល ពត ទៅវៀតណាម និងប៉េកាំង។ នៅឆ្នាំដដែល ខ្ញុំនៅជាមួយ អៀង សារី ដដែល”។

[០៩:៤៩:០៧]

ឯកសារ IS13.34 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពលធំ និងវរសេនាធំឯករាជ្យ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ វេលាម៉ោង១៤។ លេខ ERN ជាភាសាខ្មែរ 00052402។ ERN ជាភាសាអង់គ្លេស 00183982។ ERN ជាភាសាបារាំង 00334972។ ក្នុងកំណត់ហេតុប្រជុំនោះបានសរសេរថា៖ “បង៨៩ សុំខទ្មេសនាមសំណូមពរបុណ្យបក្ស និយាយសមាសភាពចូលរួមបុណ្យ។ យើងធ្វើបុណ្យបក្សឆ្នាំនេះ ដោយអង្គការជាប់រវល់ ពេលវេលាខុសបន្តិច តែសំខាន់ខ្លឹមសារទេ។ សូមបញ្ជាក់តាមបក្សកំណត់ បុណ្យខួបបក្សពីមុនឆ្នាំ១៩៥១ តែឥឡូវ កំណត់យកថ្ងៃ៣០ ខែ៩ ឆ្នាំ១៩៦០វិញ។ ពេលនោះ ហើយដែលបក្សយើងមានលក្ខន្តិកៈ មានមាគ៌ាត្រឹមត្រូវ បក្សយើងប្រែប្រួល

ឈ្មោះជាបន្តបន្ទាប់។ ដំបូង បក្សប្រជាជនបដិវត្តន៍ ក្រោយមក បក្សពលករ។ ទីបំផុតប្រែឈ្មោះ បក្សកុម្មុយនីស្តកម្ពុជា”។

[០៩:៥១:00]

ឯកសារ IS20.28 សម្ភាសន៍លោក នួន ជា ជាមួយ ខែម ងុន។ លេខ ERN 00078192 ជាភាសាខ្មែរ។ ERN ជាភាសាអង់គ្លេស 00184662។ ERN ជាភាសាបារាំង 00596185។

នៅក្នុងបទសម្ភាសនេះបានសរសេរថា៖ “នៅក្នុងការឆ្លងនេះជ្រើសរើសគណៈកម្មាធិការបក្ស សួរ៖ មានប៉ុន្មាននាក់? នួន ជា៖ ១០ទៅ១៥នាក់ មិត្តឯងគិតមើល ហើយនៅដេកក្នុងបន្ទប់មួយក្តៅសម្បើមណាស់។ តំណាងមកពីគ្រប់ទីកន្លែង កាលណោះ មិនទាន់តាទេ។ សួរ៖ អ៊ំចាំឈ្មោះអស់ទេ? នួន ជា៖ ខ្ញុំចាំមិនអស់ កាលណោះ គ្មានតាទេ។ អត់ទាន់មានតាទេ ក៏ប៉ុន្តែ តែខ្ញុំចាំអ៊ីចេះ ជ្រើសរើសគណៈកម្មាធិការបក្ស គណៈកម្មាធិការមជ្ឈិមនោះណ៎ា។ មានមួយ ទូ សាមុត លេខាបក្ស, ខ្ញុំ អនុលេខា, សាឡុត ស សមាជិក, ម៉ាម៉ង់ កំពង់ឆ្នាំង សមាជិក, អៀង សារី សមាជិក, កែវ មាស សមាជិក កាលណោះដូចមាន អាចុង ដែរ អ្នកនៅកោះកុង ក៏ប៉ុន្តែខ្ញុំមិនចាំ។ អចិន្ត្រៃយ៍គឺបីនាក់ តាទូ, ខ្ញុំ, សាឡុត ស ដូចជាមាន ម៉ាម៉ង់ ដែរ។ ប្រជុំហើយប្រជុំ ប្រជុំនៅថ្ងៃទី៣០ ខែ៩ ១៩៦០។ រួចទៅចែកគ្នាចុះជនបទ អ្នកណានៅជនបទ ទៅជនបទ។ អ្នកណានៅទីក្រុង នៅទីក្រុង។ ហើយខ្ញុំនៅទទួលការងារទាក់ទងជនបទផងទីក្រុងផង។ ប៉ុន្តែទីក្រុងទៅធូន់ខាង សាឡុត ស ហើយខ្ញុំធូន់ខាងជនបទ ពីព្រោះលោកតាមាននៅណារួច គាត់ចាស់ហើយ គាត់បែកការណ៍ផង និយាយរួម គាត់មិនយល់អី គាត់មិនយល់ទេ ប៉ុន្តែគាត់ល្អ គាត់អាចារ្យ”។

[០៩:៥៤:០៦]

ក្នុងបទសម្ភាសន៍នោះដែរ លេខ ERN ជាភាសាខ្មែរ 00078196។ លេខ ERN ជាភាសាអង់គ្លេស 00184667។ លេខ ERN00596189។ ក្នុងបទសម្ភាសនោះបាននិយាយថា៖ “ដូច្នេះ បានសន្និបាតបក្សលើកទីពីរឆ្នាំ១៩៦៣ សាឡុត ស ធ្វើលេខាបក្ស ខ្ញុំធ្វើអនុវិញ។ ខ្ញុំសុខចិត្ត អត់អីទេ ខ្ញុំមិនប្រកែប្រកាន់ទេ ហើយពេលនោះ គ្មានក្រុមប្រជាជនចូលទេ ពីព្រោះគោលការណ៍មិនឲ្យអ្នកចំហចូលទេ យកអ្នកសម្ងាត់សុទ្ធ។ កែវ មាស អីឈប់ហើយ ឈប់ឲ្យចូលហើយ។ សួរ៖ ធ្វើនៅឯណា? នួន ជា៖ នៅផ្លូវ ឌីហ្គោល ពេលហ្នឹងមានមកច្រើនគ្នាទៀត មានសាឡុត ស មានខ្ញុំ មានអៀង សារី មានអាណុង ហៅខ្មែច មានអាគី ហៅសុផល។ សុផលវាបង្ហាត់ខាងកីឡា នៅសាលារៀនយុគន្ធ។ ហើយ

វន វ៉េត នេះ ហើយអារស់ ញឹម អាញឹម ហៅ មូល សម្បត្តិ។ ហើយ តាម៉ុក ហើយនិងអ្នកអាណាទៀត អ៊ីចេះ ម៉ាម៉ង់ អីមកទៀតហើយ ពីព្រោះអ្នកចាស់ណា!។ ឆ្នាំ៦៣ ដល់ឆ្នាំ៦៣ រៀបចំបក្សអីស្រួលបួល ហើយ រៀបចំជនបទចេះតែរីកហើយ ចលនាតស៊ូចេះតែកើន ទីក្រុងក៏កើន ជនបទក៏កើន កើតគេ ហៅថាព្រឹត្តិការណ៍២៤នាក់ ដែលសីហនុប្រកាសថាឲ្យទៅធ្វើនាយកនោះ។ ក៏ប៉ុន្តែចលនាមហាជនវា ខ្លាំងណាស់ដែរ។ ដល់ប្រកាសអំពីព្រឹត្តិការណ៍២៤នាក់ហ្នឹងទៅ វាមានទាំងអស់ សាឡុត ស, អៀង សារី, សុន សេន។ ទេ អានេះបើស្រាវជ្រាវទៅបែបដឹង។ ន៉ែ ពីណាទៀតទេ សុទ្ធតែពួកបញ្ញវន្ត បញ្ញាជន។ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ន៉ែ ពីណាទៀតទេខ្ញុំ។ សួរ៖ កាលណោះអ៊ំហែមអីអត់ ចូលទេ? នួន ជា៖ អត់ទាន់ចូលមជ្ឈិម ប៉ុន្តែគាត់ចូលបក្សហើយ។ ខ្ញុំមិនចាំ ចាំសួរគាត់ គាត់ចូលព្រៃ ឆ្នាំណា។ ដល់កើតព្រឹត្តិការណ៍អ៊ីចឹងទៅ គណបក្សប្រជុំទៅឃើញថា មជ្ឈិមយើងបើនៅទីក្រុងតទៅ ទៀតមិនបានទេ។ ដូច្នេះត្រូវទៅនៅព្រៃ។ ដូច្នេះ ខែបី ៦៣ ចេញព្រៃហើយ ប៉ុល ពត ចេញមុនគេ។ បន្ទាប់មកទៀត អៀង សារី ចេញ។ ប៉ុន្តែ អៀង សារី មិនចង់ចេញទេ ពីព្រោះឯណាកូនចៅអី ហើយ គេខ្លាចលំបាក។ ខ្ញុំអ្នកនាំចេញ ថ្ងៃទី១៥ ខែ៣ ៦៣ សុន សេន ចេញ"។

[០៩:៥៧:៥៧]

ឯកសារ IS20.8 បទសម្ភាសលោក អៀង សារី ជាមួយទូរទស្សន៍ អេ.ប៊ី.ស៊ី អូស្ត្រាលី ក្បែរ ស្រុកម៉ាឡៃ។ លេខ ERN ជាភាសាខ្មែរ 00224443។ លេខ ERN ជាភាសាអង់គ្លេស 00078610។ លេខ ERN ជាភាសាបារាំង 00347376 ដល់ 00347377។ ក្នុងបទសម្ភាសនេះ អៀង សារី សម្រេច ទាំងអស់ត្រូវធ្វើឡើងដោយគណៈកម្មាធិការបួនរូបនោះឯង។

"ការជម្លៀសប្រជាជនចេញពីទីក្រុងនានា មិនពាន់ព័ន្ធនឹងការចូលរួមធ្វើសេចក្តីសម្រេចរបស់ខ្ញុំ ទេ។ ពីព្រោះនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចុះពីយន្តហោះមកពីទីក្រុងប៉េកាំង ហើយខ្ញុំបាន ឃើញទីក្រុងក្លាយជាទីរហោឋានរួចទៅហើយ។ គ្រប់យ៉ាងត្រូវបានគេសម្រេចរួចទៅហើយ ហើយវា គ្មានតម្លៃអ្វីដែលត្រូវនិយាយអំពីបញ្ហានេះទេ"។

ឯកសារ IS4.1 សៀវភៅនិពន្ធដោយ អេលីហ្សាប៊ែត បេកយ័រ មានចំណងជើងថា "នៅពេល ដែលសង្គ្រាមរលត់ទៅ" លេខ ERN ជាភាសាខ្មែរ 00232072 ដល់ 00232073។ លេខ ERN ជាភាសាអង់គ្លេស 00237762 លេខ ERN ជាភាសាបារាំង 00638334 ដល់ 00638335។ ក្នុង សៀវភៅនេះបានសរសេរថា៖ "អៀង សារី និង សាឡុត ស បានក្លាយទៅជាមិត្តភក្តិនឹងគ្នាយ៉ាងជិតស្និទ្ធ

បំផុត និងបានចងក្រងសម្ព័ន្ធមិត្តដោយឡែកជាមួយនឹង ជួន ប្រសិទ្ធ ទៀត ដែលជាអ្នកមិនសូវបានរៀនសូត្រប៉ុន្មានទេក្នុងចំណោមបងប្អូនប្រុសទាំងបួននាក់។ សារី ដែលជាមនុស្សចូលចុះក្នុងជំនុំចំណោមមិត្តភក្តិជាងគេ គឺជឿយុវបុរសម្នាក់មានទឹកមុខស្រស់ស្រាយ ដែលងាយក្នុងការសើច និងជនប្រកបដោយឆន្ទៈម្នាក់ ដែលលម្អៀងទៅខាងការសម្រេចចិត្តភ្លាមៗ ហើយឆាប់រំភើបញាប់ញ័រដែលរោលរាលដូចអណ្តាតភ្លើង។ សាឡុត ស ជាមនុស្សម៉ឺងៗ មិនសូវចេះនិយាយស្តី ប្រកបដោយលក្ខណៈផ្សេងៗ ជាអ្នកគិតគូរវែងឆ្ងាយ និងមានបុគ្គលិកលក្ខណៈស្អាតបរិសុទ្ធជាងគេ។ គាត់មានសេចក្តីប្រាកដក្នុងចិត្តមួយយ៉ាងស្ងប់ស្ងៀមដែលនាំឲ្យគេចូលចិត្តធ្វើតាមគាត់គ្រប់គ្នា។ ពួកអ្នកទាំងនោះបានរស់ជុំគ្នានៅផ្ទះលេខ ២៨ ផ្លូវសាំងអង់ជ្រេ ដេហ្សា សង្កាត់ឡាតាំង ក្នុងល្វែងបន្ទប់នៃអគារមួយដែល អៀង សារី, មុំ, ប្រសិទ្ធិ និង ឌិក សុគន្ធ ព្រមទាំងនិស្សិតខ្មែរក្រហមផ្សេងៗទៀតបានរស់នៅក្នុងសម័យកាលខុសៗគ្នា។ មិនយូរប៉ុន្មានមានយុវតីម្នាក់បានចូលមករស់នៅជាមួយដែរ នាងជាស្ត្រីម្នាក់ដែលមានរូបសម្រស់ជាខ្មែរ និងមានឆន្ទៈរឹងប៉ឹង ឈ្មោះ ខៀវ ធីរិទ្ធ ជាកូនស្រីរបស់ចៅក្រមគួរឲ្យគោរពម្នាក់។ ជាមនុស្សមានចរិតមិនចំណុះអ្នកណា នាងបានទៅជានារីម្នាក់ក្នុងចំណោមនារីដំបូងៗដែលបានរៀនសូត្រនៅសាលាស៊ីសុវត្ថិ ហើយបានទទួលពិន្ទុផ្នែកភាសាបារាំងល្អប្រសើរជាងគេ។ នាងបានទាក់ទាញការយកចិត្តទុកដាក់ពីយុវជនមួយចំនួនដែរ ប៉ុន្តែតាមការភ្ញាក់ផ្អើលពីបណ្តាមិត្តរួមថ្នាក់របស់នាង គេថានាងបានបាក់ចិត្តស្រឡាញ់ អៀង សារី ទៅហើយ"។

[១០:០២:៤៩]

ឯកសារ IS4.1 ដដែលនេះរបស់ អេលីហ្សាប៊េត លេខ ERN 00 ជាភាសាខ្មែរ 00272185។ ERN ជាភាសាអង់គ្លេស 00237844។ លេខ ERN ជាភាសាបារាំង 00638410។ សៀវភៅនេះបានសរសេរថា៖ "ជាការពិតនេះ ជាការផាត់ពណ៌ លាបម្សៅហួសប្រមាណមួយដែលធ្វើឲ្យគេជឿស្អុង អៀង សារី ពុំមានតំណែងជាផ្លូវការទេ ទាំងក្នុងរណសិរ្ស ទាំងក្នុងរាជរដ្ឋាភិបាល។ ប៉ុន្តែត្រូវបានតែងតាំងជាបេសកជនពិសេសទទួលរ៉ាប់រងធ្វើការទាក់ទងរវាងសមរភូមិនៅកម្ពុជា និងប្រធានរណសិរ្សនៅប៉េកាំង។ តាមការពិត គាត់ជាអ្នក--

[១០:០៤:១១]

ឯកសារ IS4.23 សៀវភៅរបស់លោក ខៀវ សំផន "អំពីប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"។ ឯកសារលេខ ERN ជាភាសាខ្មែរ 00103815 ដល់

00103816។ លេខ ERN ជាភាសាអង់គ្លេស 00103729 លេខ ERN ជាភាសាបារាំង 00595388។ ក្នុងសៀវភៅនោះបានសរសេរថា៖ “ប៉ុន្តែជាអកុសល មានឧបាយកលសម្ងាត់ជាបន្តបន្ទាប់ ឈ្នានីស មិនឲ្យការងារនេះបន្តទៅទៀតបាន។ ឧបាយកលទីមួយ គឺ លន់ នល់ ឆ្លៀតឱកាសបាតុកម្មនិស្សិតមួយ នៅសៀមរាប ធ្វើបញ្ជីមនុស្ស៣៤នាក់ ដែលត្រូវចាប់ នៅក្នុងនោះមានទាំងឈ្មោះខ្ញុំផងដែរ”។

[១០:០៥:២៩]

ឯកសារ IS6.3 សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា “សេចក្តីសម្រេចរបស់គណៈកម្មការមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន” ចុះថ្ងៃទី៣០ ខែ៣ ឆ្នាំ១៩៧១។ លេខ ERN ជាភាសាខ្មែរ 00003137។ លេខ ERN ជាភាសាអង់គ្លេស 00182810 លេខ ERN ជាភាសាបារាំង 00224364 ដល់ 00224364។ ក្នុងសេចក្តីសម្រេចនោះបានសរសេរថា៖ “បញ្ហាប្រវត្តិបក្សកំណត់កំណើតបក្សពីឆ្នាំ១៩៦០វិញ មិនយកឆ្នាំ១៩៥១ ទេ ដើម្បីកុំឲ្យជាប់ជាមួយគេឯង ឲ្យដាច់ស្រឡះ”។

សូមជម្រាបលោកប្រធានឯកសារបានបញ្ចប់ហើយ។

[១០:០៦:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អគុណលោកចៅក្រម។

ហើយជាកិច្ចបន្តអង្គជំនុំជម្រះសួរទៅភាគី ថាតើភាគីណាមានបំណងចង់ដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ នាពេលនេះដែរឬទេ? ហើយប្រសិនបើមាន សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមដាក់ឯកសារមួយចំនួនព្រឹកនេះ ហើយខ្ញុំនឹងបង្ហាញច្រើនទៀតនៅថ្ងៃចន្ទ អង្គារ អាទិត្យក្រោយ នៅពេលដែលសវនាការបន្តទៅទៀតនោះបាទ។

[១០:០៧:៤៨]

លោកប្រធាន ទាក់ទងទៅនឹងបញ្ហាដែលថា ជនជាប់ចោទគាត់មានឱកាសក្នុងការផ្តល់នូវអត្ថាធិប្បាយ គឺថាជាពិសេសឯកសារមួយចំនួនទាក់ទងទៅនឹងលោក នួន ជា ខ្លះ ទាក់ទងទៅនឹងលោក ខៀវ សំផន ហើយខ្ញុំក៏ឯកភាពជាមួយមេធាវីរបស់លោក អៀង សារី ថាគាត់បានអះអាងជាច្បាស់លាស់ ហើយដាច់អហង្ការថាគាត់នៅស្ងៀមមិនឆ្លើយតប។ ដូច្នេះនេះជាចំណុចសំខាន់មួយ ចំពោះលោក នួន

ជា វិញលោកបានផ្ដល់នូវយោបល់មួយចំនួនលើឯកសារ។ ដូច្នេះយ៉ាងហោចណាស់ ទាក់ទងទៅនឹងឯកសារនេះដើម្បីស្នើថា តើគាត់មានឱកាសដើម្បីសម្ដែងមតិដែរឬទេ? ចំពោះលោក ខៀវ សំផន វិញ គាត់ខុសពីលោក អៀង សារី គាត់មិនបានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះដាច់ខាតនោះទេ ដែលគាត់និយាយថា គាត់ចង់រក្សាសិទ្ធិនៅស្ងៀម ហើយខ្ញុំនឹងឆ្លើយតបពេលណាមួយ នៅពេលដែលសវនាការបន្តទៅមុខ។ ហើយនៅពេលដែលមានឯកសារដាក់លាក់ ហើយគាត់បានធ្វើបែបនោះ គាត់បានផ្ដល់យោបល់មួយចំនួន តាំងពីចាប់ផ្ដើមសវនាការមក ពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។

[១០:០៩:១៥]

ដូចម្សិលមិញនោះដែរ គាត់បានរក្សាសិទ្ធិនៅស្ងៀមចំពោះឯកសារមួយចំនួន ប៉ុន្តែឯកសារខ្លះគាត់បានសម្ដែងគំនិតចំពោះរយៈពេលដែលគាត់ជាសមាជិកនៃបក្សនោះ គឺថាគាត់មិនមាន មិនបានដឹងនោះទេ។ ប៉ុន្តែលោក ខៀវ សំផន ខ្ញុំយល់ឃើញថា គាត់រក្សាសិទ្ធិមិនឆ្លើយតបទៅនឹងភស្តុតាងមួយចំនួនឯកសារមួយចំនួន ប៉ុន្តែឯកសារខ្លះ គាត់អាចនឹងផ្ដល់មតិយោបល់។ អ៊ីចឹងក៏ជូនឱកាសទៅគាត់ដែរ។

អ៊ីចឹង ខ្ញុំសូមជម្រាប់តុលាការឲ្យបានជ្រាបថា នៅពេលខ្លះគឺថាអាចនឹងសូមឲ្យលោក នួន ជា ឬក៏លោក ខៀវ សំផន នឹងផ្ដល់ឱកាសជូនគាត់ ថាតើគាត់មានមតិ ឬក៏យោបល់អ្វីលើឯកសារ ដែលខ្ញុំនឹងបម្រុងនឹងដាក់ ដែលខ្ញុំបានដាក់នេះបាទ?

[១០:១០:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ ដោយសារគិតគូរទៅលើពេលវេលា និងធនធាន ដែលត្រូវប្រើក្នុងសវនាការនេះ ខ្ញុំបាទសូមបញ្ជាក់អំពីជំហររបស់លោក ខៀវ សំផន ថា លោកនឹងមិនធ្វើការឆ្លើយតបចំពោះការដាក់ឯកសារដែលលោកសហព្រះរាជអាជ្ញានឹងលើកនេះទេ។ ដូច្នេះសហព្រះរាជអាជ្ញា អាចបន្តនីតិវិធីដូចលោកចៅក្រម យ៉ា សុខន បានធ្វើអម្បាញ់មិញនេះបាទ។ សូមអរគុណ។

[១០:១០:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ផ្នែកលើមតិរបស់លោកមេធាវីនោះ ខ្ញុំនឹងកត់សម្គាល់ ខ្ញុំមិនផ្ដល់ឱកាសទៅគាត់ទេ ប្រសិនបើ បើសិនជាគាត់ប្ដូរជំហរ ហើយខ្ញុំនឹងសូមអនុញ្ញាតពីតុលាការអំពីបញ្ហានោះ ដើម្បីផ្ដល់ឱកាសឲ្យគាត់បានផ្ដល់ជាយោបល់។

ឯកសារទីមួយ ដែលខ្ញុំនឹងដាក់ជូនភាគីចំពោះមុខអង្គជំនុំជម្រះនោះ ទាក់ទងទៅនឹងសក្ខីកម្មទាក់ទងទៅលោក នួន ជា ដែលថាគាត់ចូលរួមពាក់ព័ន្ធក្នុងកិច្ចការយោធា ដែលថៅក្រមបានដឹងហើយថា គាត់បានបដិសេធមិនបានមានការពាក់ព័ន្ធជាមួយយោធាទេ។ ប៉ុន្តែមានឯកសារបី បទសម្ភាសដែលធ្វើឡើង លោក អៀង សារី នៅពេលដែល អៀង សារី នៅក្នុងឱកាសបីខុសគ្នាដែលគាត់បានបញ្ជាក់ច្បាស់ថា នួន ជា សមាជិកនៃគណៈកម្មការយោធា ហើយក៏មានការទទួលខុសត្រូវខាងយោធា។

[១០:១២:០៥]

ឯកសារទីមួយនោះ គឺឯកសារ D366/7.1.6.56 ដែលខ្ញុំជឿថា ដែលថាឯកសារហ្នឹងក៏កត់ថាជាលេខ E3/94 គឺជាការសម្ភាសនៅខែកក្កដា ឆ្នាំ១៩៨១ ផងដែរ។ ដែលអង់គ្លេស ERN លេខ 00342501 រហូតទៅដល់ 310252។ បារាំង 00602000។ ខ្មែរ ERN 00578895។ លោក អៀង សារី បានបញ្ជាក់ថា បញ្ហាសន្តិសុខគឺជាការទទួលខុសត្រូវរបស់ ប៉ុល ពត, នួន ជា, សោ ភឹម ហើយនិង សុន សេន ដែលទទួលខុសត្រូវ នឹងរាយការណ៍ជូនដល់គណៈអចិន្ត្រៃយ៍ពីបញ្ហានេះ”។

១៥ឆ្នាំ ក្រោយមកលោកបញ្ជាក់ថា បានដែលគាត់កាន់កាប់អង្គការចលនាប្រជាធិបតេយ្យនោះ គឺថាដែលចេញឯកសារមួយគឺថា ឯកសារហ្នឹងចុះថ្ងៃទី០៩ កញ្ញា ឆ្នាំ១៩៧៦ ដែលថៅក្រម ឡាវែន៍ បានដាក់ជូននោះ។

[១០:១៣:៥១]

ឯកសារមួយទៀត IS20.3 ERN នោះគឺថាជាភាសាអង់គ្លេស 00081215។ បារាំង ERN00614094។ ខ្មែរ ERN 00224430។ នៅក្នុងឯកសារនេះបានបញ្ជាក់ថា គណៈកម្មការសន្តិសុខដែលរាប់ទាំង ប៉ុល ពត, នួន ជា និង សុន សេន ផង ដែលបានដកស្រង់ថា “គឺជាអ្នកសម្រេចនៅក្នុងការកាប់សម្លាប់ និងការសម្លាប់រង្គាល” ដកស្រង់។ ហើយបីឆ្នាំក្រោយមកនៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៧៩ លោក អៀង សារី ជាថ្មីម្ដងទៀត បានបញ្ជាក់ថា “សេចក្ដីសម្រេចក្នុងការចាប់ខ្លួន និងសម្លាប់គឺធ្វើឡើងដោយ នួន ជា, សុន សេន ហើយនិង ស-២១ គឺសេចក្ដីថ្លែងការណ៍ នៅឆ្នាំ១៩៩៩”

គឺឯកសារ IS លេខ 20.7។ ERN អង់គ្លេស 00081571។ បារាំង ERN 00667965 ខ្មែរ ERN លេខ 00172247។

លោកប្រធាន នេះចម្លើយបីយ៉ាង ដែលជាជនជាប់ចោទ ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ដែលគាត់បានឆ្លើយ ទាក់ទងទៅនឹង នួន ជា ហើយដែលវាផ្ទុយពីការអះអាង នួន ជា ថាគាត់មិនមានការពាក់ព័ន្ធទៅនឹងកិច្ចការយោធាទេ។ ដូច្នេះ ខ្ញុំផ្ដល់ឱកាសឲ្យលោក នួន ជា ថាតើលោក នួន ជា មានការឆ្លើយតបអ្វីដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ខ្ញុំមិនមែននៅក្នុងគណៈកម្មការយោធាទេ។ ខ្ញុំនៅខាងសភាឯណោះតើ ដូច្នោះខ្ញុំប្រធានគណៈកម្មការប្រធានសភាន៎ៃ ខ្ញុំទៅធ្វើខាងយោធាយ៉ាងម៉េច វាខុសគ្នាឆ្ងាយណាស់ បើដូច្នោះឯកសារនេះសរសេរខុសទេ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញតទៀតលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ឯកសារបន្ទាប់ទៅទៀតនេះ ខ្ញុំនឹងដាក់ជូនភាគី និងអង្គជំនុំជម្រះនោះ គឺឯកសារ D262.26 ហើយជាពិសេស ERN ជាភាសាអង់គ្លេស 00168465 រហូតទៅដល់ 168470។ បារាំង ERN 00698444 រហូតទៅដល់ 698450។ ខ្មែរ ERN 0067792 រហូតទៅដល់ 679802។ នេះជារបាយការណ៍ ដែលធ្វើឡើងនៅខែមករា ឆ្នាំ១៩៧៧ នៅក្នុងការផ្សាយវិទ្យុកម្មវិធីព័ត៌មានអន្តរជាតិ ដែលនិយាយថា នួន ជា និយាយអំពីខួបកំណើតរបស់កងទ័ពបដិវត្តកម្ពុជា នៅពីវិទ្យុផ្សាយសំឡេងភ្នំពេញ ដែលគេថតសំឡេងដោយម៉ោង០៤ ម៉ោងបួនជាម៉ោងសកលនៅឆ្នាំ១៩៧៧ ដែលអាចជាថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៧។ ឯកសារនោះ គឺនិយាយថា ការសេចក្ដីដកស្រង់ការផ្សាយអំពី នួន ជា ដែលសភាតំណាងសភាប្រជាជនកម្ពុជា ជានាយករដ្ឋមន្ត្រីស្ដីទីនៅក្នុងការប្រជុំកត់សម្គាល់នូវខួបកំណើតទី៩ នៃកងទ័ពបដិវត្តកម្ពុជា។

[១០:១៩:២០]

ហើយខ្ញុំក៏សូមកត់សម្គាល់ផងដែរថា ដាក់ជូននូវឯកសារ D248/6.1.14 ដែលជាឯកសារនិយាយពីការផ្សព្វផ្សាយដូចគ្នាដែរ ដែលរាយការណ៍របស់ ប៊ី.ប៊ី.ស៊ី ជាព័ត៌មានសង្ខេបទៅពិភពលោក គឺការផ្សព្វផ្សាយនេះគឺជាសុន្ទរកថារបស់ នួន ជា។ ចំណុចសំខាន់នៅចំណុចនេះ គឺថាយើងបានកំណត់អត្តសញ្ញាណនៅក្នុងអង្គហេតុដែលជនជាប់ចោទបានជំទាស់ពីយថាភាពទាំងអត្ថបទផ្សាយទាំងពីរនេះ ទាំងវិទ្យុរបស់ ប៊ី.ប៊ី.ស៊ី ផងដែរ។ ហើយដែលគេថតចេញពីការផ្សាយវិទ្យុភ្នំពេញនោះក៏ដោយ ហើយសេចក្ដីដកស្រង់នោះគឺដកស្រង់ពីសុន្ទរកថារបស់ នួន ជា។

[១០:២០:៣៣]

ខ្ញុំនឹងអានផ្នែកនៃអត្ថបទរបស់ការផ្សាយព័ត៌មានអន្តរជាតិ។ បាទ ដែលថាមានផ្សាយជាសំឡេងខ្លឹមសារទាំងស្រុង។ នៅក្នុងនោះ ជាសុន្ទរកថារបស់ នួន ជា ហើយខ្ញុំនឹងអានដូចខាងក្រោមនេះ ជាវគ្គមួយ ជាផ្នែកមួយដែលពីទំព័រ២ ដល់៣ ដែលជាទំព័រទី២, ទី៣ នៅក្នុង ERN 00168466 រហូតទៅដល់ 67 នៅខាងចុង ជាទំព័រទី២នៅក្នុងរបាយការណ៍នេះ។ ដែលនិយាយដូចខាងក្រោមនេះ ដកស្រង់៖ “នៅចាប់ផ្ដើមឆ្នាំ១៩៧៧ ក្រុមក្បត់លន់ នល់ បានបង្កសង្គ្រាម គឺថាបានកាប់សម្លាប់ជន អ្នកស្នេហាជាតិកម្ពុជា និងពួកបដិវត្តន៍ ដោយក្នុងខ្នាតធំ ហើយជាប្រព័ន្ធផងដែរ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៧ ហើយយើងបានរៀបចំអង្គភាព ហើយបង្គាប់មក បង្គាប់ឲ្យអង្គការបដិវត្តន៍វាយប្រហារទីតាំងខ្មាំងនៅស្ទឹងសង្កែ នៅបាយដំរាំផងដែរ ដែលថាបានបំផ្លាញមូលដ្ឋាននោះ។ យើងបានចាប់ខ្មាំង និងអាវុធនោះផងដែរ។ នេះគឺជាការទទួលបានអាវុធពីខ្មាំង ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ គឺជាការតស៊ូប្រដាប់អាវុធលើកទីមួយ ប្រឆាំងនឹងប្រតិកិរិយាផ្ទៃក្នុង គឺជាសង្គ្រាមប្រឆាំងនឹងខ្មាំង។ នេះគឺជាកំណើតនៃកងទ័ពបដិវត្តន៍កម្ពុជា។ ការចាប់ផ្ដើម ការតស៊ូប្រដាប់អាវុធនៅថ្ងៃទី១៧ មករា នោះ មិនមែនជាចៃដន្យទេ។ ថ្ងៃនេះ បានឃើញចាប់ផ្ដើមការចលនាបដិវត្តន៍បង្កើតយុទ្ធសាស្ត្រ យុទ្ធវិធី ដើម្បីអនុវត្តតទៅមុខ។ ហើយយើងទទួលស្គាល់ថា ចក្រពត្តិអាមេរិក ហើយនិងពួកបរិវារ ហើយនិងវណ្ណៈជិះជាន់ ៗហើយនិងពួកផ្ដាច់ការ ប៊ុនប៉ង ហើយនិងបំភិតបំភ័យប្រជាជនយើង។ ហើយយើងប្រកាន់នូវជំហរដោយច្បាស់ ដើម្បីកម្ទេចពួកអាមេរិក និងបរិវារ ហើយនិងវណ្ណៈផ្សេងទៀត។ នយោបាយតែឯងមិនជោគជ័យទេ ខ្មាំងប្រើប្រដាប់អាវុធ ហើយនិងឧបករណ៍ផ្ដាច់ការដើម្បីគាបសង្កត់និងសម្លាប់ប្រជាជនយើង។ ដោយហេតុនេះហើយ បន្ទាប់ពីឆ្នាំ១៩៦០ អង្គការបដិវត្តន៍របស់យើងបានសម្រេចច្បាស់ថា ការតស៊ូ

នយោបាយ និងអាវុធត្រូវប្រើរួមគ្នា ដើម្បីបង្ក្រាប ឬក៏យកជ័យជម្នះលើខ្មាំង”។ ចប់សេចក្ដីដកស្រង់។

[១០:២៣:៥២]

ជាថ្មីម្ដងទៀតដែល លោកប្រធាន ខ្ញុំផ្ដល់ឱកាសជូនជនជាប់ចោទ នួន ជា ដើម្បីឲ្យគាត់មានមតិយោបល់ ដោយសារថានេះ គឺជាសុន្ទរកថារបស់គាត់ ដែលគាត់បានធ្វើកាលពីសម័យនោះ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ទាន! អ៎! សូមគោរពលោកប្រធាន ខ្ញុំសូមបដិសេធដាច់ខាត ថាខ្ញុំមិនដែលធ្វើឧបនាយករដ្ឋមន្ត្រីស្ដីទីទេ-- អ៊ូ! មិនដែលធ្វើនាយករដ្ឋមន្ត្រីស្ដីទីទេ។ នេះខទីមួយ។ ខ ទីពីរ ខ្ញុំមិនដែលធ្វើសុន្ទរកថាអីពីរឿងយកបុណ្យ យោធាទេ បើថាមានសំឡេងថតណា! ខ្ញុំសុំសំឡេងខ្ញុំមកស្ដាប់មើល! តើសំឡេងខ្ញុំមែន ឬមិនមែន។

ខ្ញុំសូមជម្រាបអ៊ីចេះ អ្នកដែលត្រៀមជំនួសប៉ុល ពត ខាងនេះ គឺសុន សេន ទេ មិនមែនខ្ញុំទេ ព្រោះខ្ញុំខាងសភាដាច់(ឮមិនច្បាស់) ហើយ។ ខ្ញុំមក ច្រឡូកច្រឡំខាងយោធាយ៉ាងម៉េច។

[១០:២៥:១២]

**លោក ខេល លីសាក់៖**

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមញ្ជើញ!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន ជាបញ្ហាបច្ចេកទេស យើងបានទទួលដំណឹងថា ឯកសារត្រូវតែមានជាភាសាបីភាសា ប៉ុន្តែបើអត់មានទេ យើងគិតថាមុននឹងចង្អុលទៅរកសាក្សីណាមួយបង្ហាញតុលាការនោះ គឺថាអាចជាការខុសមួយ បើមិនមានគ្រប់បីភាសាទេ។ ខ្ញុំគិតហ្នឹង គឺថាឯកសារនេះ មិនទាន់បានបកទៅជាពីរភាសាទៀតទេ ហើយខ្ញុំសូមឲ្យតុលាការមានការណែនាំ ថាតើសុំឲ្យបញ្ជាក់ថាតើភាគីផ្សេងទៀត គាត់ប្រើភាសាតែមួយហ្នឹងដែរឬទេ? ទោះបីជាមិនចំពោះខ្ញុំក៏ដោយ។

**លោក ឌេល លីសាក់៖**

សូមអនុញ្ញាតឆ្លើយតប។ លើកលែងតែខ្ញុំភ្លេច ប៉ុន្តែពីចាប់ផ្តើម ខ្ញុំអានថាឯកសារហ្នឹង ERN ទាំងខ្មែរ បារាំង អង់គ្លេសហើយ ប្រហែលជាលោកតាមមិនទាន់ ឬក៏បកខ្វះ ប៉ុន្តែមានក្នុងកំណត់ត្រាប្រតិចារឹកហើយ។

[១០:២៦:២៨]

**ប្រធានអង្គជំនុំ៖**

ហើយយើងការរំឭកឡើងវិញ ដល់ភាគីដែលពាក់ព័ន្ធនៅក្នុងការលើកឡើងឯកសារមកដេញដោល គឺសុំប្រើប្រាស់ឯកសារដែលជាបីភាសា។ បញ្ហានេះ យើងបានបដិសេធនៅសំណើរបស់ក្រុមមេធាវីការពារក្តី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្តងរួចមកហើយ នៅពេលដែលគាត់លើកឡើងនូវឯកសារដែលប៉ុនប៉ងធ្វើជាមូលដ្ឋានក្នុងការលើកមកជជែកពិភាក្សាដេញដោល នៅក្នុងអំឡុងពេលដែលធ្វើសវនាការពីកន្លងទៅនេះ ដោយសារមូលហេតុគាត់មិនបានបកប្រែឯកសារនុ៎ង ទៅជាភាសាពីរទៀត ដែលសរុបមានបីភាសា នៅប្រើប្រាស់នៅ អ.វ.ត.ក នេះ។

អ៊ីចឹង យើងគិតថាបញ្ហានេះ មិនទំនងកើតមានទៀតទេ ចំពោះភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះដែលចូលរួមនៅក្នុងកិច្ចដំណើរការ។ ប្រាកដជាប្រឹងប្រែងធ្វើការឲ្យបាន លើកលែងតែករណីមួយចំនួនប៉ុណ្ណោះ ដែលយើងបានជម្រាបជូនរួចហើយ ជាលាយលក្ខណ៍អក្សរ។

សូមអញ្ជើញ!

បញ្ជាក់ជាថ្មីម្តងទៀតបានទេ លើឯកសារអម្បាញ់មិញនេះ ដើម្បីជាបញ្ជាក់ជាបីភាសា លេខ ERN។

[១០:២៧:៥៨]

**លោក ឌេល លីសាក់៖**

បាទ អរគុណលោកប្រធាន។ ឯកសារចុងក្រោយដែលខ្ញុំអាននោះ គឺត្រង់នៅឯកសារ D262.261 ហើយ ERN អង់គ្លេស 00168465 រហូតទៅដល់ 168704។ បារាំង ERN 009698444 រហូត 698450។ ខ្មែរ ERN 0067792 រហូតទៅដល់ 679802។ ហើយដើម្បីឲ្យគ្រប់នៅក្នុងកំណត់ហ្នឹងសេចក្តីដកស្រង់ដែលខ្ញុំអាននោះ ចេញមកពីអង់គ្លេស ERN 168466 រហូតទៅដល់ 67 ខាងចុងនោះបាទ។ ខ្មែរ ERN 00679796 បារាំង ERN 00698446។

ខ្ញុំសូមអនុញ្ញាតបន្តទៅឯកសារទៀត ដោយសារ ឬក៏លោកប្រធានយល់ថា យើងដល់ម៉ោងសម្រាកពេលព្រឹកហើយ។ បាទ បើដូច្នោះ ខ្ញុំនឹងគោរពទៅតាមនោះ។

[១០:២៩:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ក៏ដល់ពេលសមល្មមនឹងសម្រាក។

សូមអញ្ជើញ!

**លោក នួន ជា៖**

បើមានឯកសារតែងតាំង ខ្ញុំជានាយករដ្ឋមន្ត្រីស្តីទី សុំមើលឯកសារហ្នឹងផងមើល៍។

**ប្រធានអង្គជំនុំ៖**

បានផ្តល់ជូនរួចហើយ អំមិញអំពីលេខឯកសារ អត្តសញ្ញាណឯកសារ ហើយទំនងជាមេធាវីរបស់លោក ហើយនិងក្រុមជំនួយការរបស់មេធាវីរបស់លោកអាចដកស្រង់យកឯកសារនុំ៎ង ជាក្រដាសដើម្បីបង្ហាញលោកបានហើយ។

[១០:៣០:៥១]

អង្គជំនុំជម្រះបានសម្រេចរួចហើយ ការប្រើប្រាស់ឯកសារនេះ គឺឯកសារមាននៅក្នុងប្រព័ន្ធហ្សាយឡេប ដែលយើងបានរៀបចំនៅក្នុងកម្មវិធីដែលយើងបានដេញដោលនេះ រួចហើយ។ លើកលែងតែមានមូលហេតុ មូលដ្ឋានដែលថាឯកសារនោះ វាជាឯកសារក្លែងក្លាយ ហើយមានភស្តុតាងជាក់ច្បាស់។ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើបញ្ហានោះ ដើម្បីថាគប្បីធ្វើការដកចេញ ឬក៏យ៉ាងណាទៅតាមការពិនិត្យឲ្យឃើញជាក់ស្តែងនៅក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ។

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ សូមអរគុណ។ សូមគោរព លោក លោកស្រីចៅក្រម។

ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាឈឺចង្កេះ និងជើង លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់នៅក្នុងសវនាការនេះ សម្រាប់មួយថ្ងៃនេះពេញ។ ប៉ុន្តែសុំចូលរួមសវនាការនៅបន្ទប់រង់ចាំខាងក្រោយ។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្ដាប់នូវសំណើសុំរបស់មេធាវីការពារក្ដីលោក អៀង សារី។ ស្នើសុំឱ្យកូនក្ដីរបស់លោកនូវការលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយបញ្ហា មូលហេតុសុខភាពមិនអាចអង្គុយយូរបាន។

អ៊ីចឹង អង្គជំនុំជម្រះយល់ព្រមតាមសំណើរសុំ ដោយក្នុងការលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយឱ្យបន្តទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់ដែលបានរៀបចំរួចហើយ នៅខាងក្រោមសាលសវនាការនេះ តែតម្រូវឱ្យមេធាវីផ្ដល់មកឱ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់របស់ជនជាប់ចោទ ដោយមានហត្ថលេខា ឬក៏ស្នាមម្រាមដៃជាក់លាក់ពីជនជាប់ចោទ។ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍តប្រព័ន្ធសោតទស្សន៍រូបភាពសំឡេងទៅបន្ទប់ខាងក្រោមសម្រាប់លោក អៀង សារី សម្រាប់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលកិច្ចដំណើរការសវនាការ។ ហើយពេលវេលាសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សឹមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោយសម្រាប់គាត់ចុះ។

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះសូមផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការបង្ហាញឯកសារដែលមានបំណងដាក់ចំពោះមុខអង្គជំនុំជម្រះ។

លោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ចង់មានបញ្ហាអីទៅ?

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន ខ្ញុំមានសំណួរមួយ ហើយនិងសេចក្តីសង្កេតមួយ។ ប៉ុន្តែជាបឋម តុលាការ-- យើងបានទទួលដំណឹងថា យើងត្រូវផ្តល់បញ្ជីឯកសារមួយ ហើយយើងនឹងដាក់ជូនអង្គជំនុំជម្រះសប្តាហ៍ក្រោយ។ យើងខ្ញុំនឹងធ្វើដូច្នោះ ហើយនិងអាចនឹងមានសារប្រយោជន៍សម្រាប់កូនក្តីខ្ញុំ ដោយហេតុថា ឯកសារខ្លះធ្វើឲ្យគាត់មានការភ្ញាក់ផ្អើលណាស់នៅថ្ងៃនេះ ដែលថាដាក់ដោយភាគីនៅព្រឹកនេះនេះ ដែលថាបើបានឯកសារនេះមុន ដើម្បីឲ្យគាត់បានត្រៀមខ្លួនជាមុនផងដែរ។

ហើយនិងឆ្លើយ-- ដើម្បីឲ្យគាត់ឆ្លើយតប ឬក៏អាចនឹងផ្តល់មតិយោបល់។ នេះជាសំណើទីមួយ។ បន្ទាប់មកទៀត ខ្ញុំមានយោបល់មួយ ជូនតុលាការ។ កូនក្តីរបស់ខ្ញុំបានស្នើម្តងទៀត ឲ្យគាត់បានឃើញឯកសារដើម ឬក៏បានស្តាប់នូវ*ថេប* នូវកាសែតដើម ដែលគាត់បានអានសុន្ទរកថាពី៣០ឆ្នាំកន្លងហើយនោះ។ ចំណុចនេះគឺថាគាត់ជា ជាការជំទាស់លើយថាភាពនៃឯកសារនោះ។ ហើយគាត់មិនទទួលស្គាល់នូវឯកសារនោះ ថាជាឯកសារមានយថាភាពទេ ទោះបីជាតុលាការទទួលស្គាល់ដាក់ជាឯកសារហ្នឹងក៏ដោយ។

ដូច្នេះ យោបល់នេះសំខាន់ណាស់ នៅពេលដែលតុលាការៗ ដើម្បីនឹងបញ្ជាក់ភស្តុតាងថា ឯកសារនោះមានយថាភាព និងតម្លៃជាភស្តុតាងនៃឯកសារទាំងនោះនោះ។

បន្ទាប់ខ្ញុំមានកំណត់សម្គាល់មួយទៀត ជាពិសេសគឺបញ្ជីរាយនាមសាក្សីដែលតុលាការឲ្យយើងខ្ញុំដាក់ជូនតុលាការនោះ ខ្ញុំជម្រាបថា មានបញ្ហាមួយចំនួនត្រូវជម្រាប។ តើតុលាការឲ្យខ្ញុំជម្រាបពេលនេះ ឬក៏នៅចុងវគ្គសវនាការព្រឹកនេះ? ខ្ញុំនឹងបញ្ជាក់ជូនជាសង្ខេបទេ បាទ។

[១០:៥៦:២៣]

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យលោកធ្វើអ្វីទៀតទេ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ បានឆ្លើយតបនឹងសំណើសុំរបស់លោកកាលពីម្សិលមិញ។ ក្នុងករណីដែលលោកមានបំណងស្នើសុំដាក់នូវសាក្សីថ្មី ឬក៏បន្ថែមសាក្សីណាផ្សេងទៀតនោះ លោករៀបចំនូវសំណើជាលាយលក្ខណ៍អក្សរ ដោយគោរពនូវគោលការណ៍សម្ងាត់ក្នុងការដាក់ឯកសារនោះមកអង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះពិនិត្យ សម្រេច។ ដូចជាច្បាស់លាស់ហើយ កាលពីម្សិលមិញ ដើម្បីឲ្យច្បាស់លាស់ ក្រែងលោយើងនិយាយភាសាខ្មែរទៅបកប្រែមិនច្បាស់ យើងបានផ្តល់វេទិកាទៅឲ្យលោកស្រីថៅក្រម ខាតវ៉ាយថ៍ ឆ្លើយតបនឹងសំណើសុំរបស់

លោកយ៉ាងជាក់ច្បាស់។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន ជាប្រកាសមួយ គឺថាយើងធ្វើការខ្លាំងណាស់លើបញ្ជីនេះ។ ហើយជាពិសេសបញ្ជីនេះ យើង-- ដែលយើងបានដាក់ជូនពីមុននោះនៅខែកុម្ភៈ ឆ្នាំ២០១១ នោះ គឺថាបញ្ជីរាយនាមនោះគឺថាអាចនឹងតុលាការបានដឹងហើយ។

**ប្រធានអង្គជំនុំ៖**

យើងដូចប្រាប់មិនឲ្យលោកនិយាយទេ។ បញ្ហានេះដូចជាប្រាប់រួចហើយអំមិញណ៎ា! លោកស្នើសុំឲ្យយើង-- យើងនិយាយ យើងមិនឲ្យនិយាយបញ្ហានេះទេ។ យើងបានឆ្លើយតបរួចហើយកាលពីម្សិលមិញ មើលប្រតិចារឹកឡើងវិញ អំពីសំណើរបស់លោក និងការឆ្លើយតបរបស់អង្គជំនុំជម្រះ ទៅនឹងសំណើរបស់លោកកាលពីម្សិលមិញ។

អស់ពេលហើយ យើងបន្តនីតិវិធីណ៎ា! លោកអង្គុយចុះ! លោក ផេសមិន អង្គុយចុះ។ យើងអត់ឲ្យលោកនិយាយទៀតទេ អង្គុយចុះ!

**លោក ម៉ៃខល ផេសមិន៖**

អរគុណ។ កាលពីម្សិលមិញ តុលាការមិនអនុញ្ញាតឲ្យខ្ញុំសួរសំណួរចុងក្រោយទេ--

**ប្រធានអង្គជំនុំ៖**

លោកចង់ធ្វើសំណើស្អីឥឡូវហ្នឹង វាឲ្យច្បាស់លាស់មើល! ដូចជាបញ្ហាមិនច្បាស់លាស់ ហើយបញ្ហាដដែលជាច្រើន។ ឥឡូវលោកលើកបញ្ហាដដែល ឬក៏លើកបញ្ហាថ្មី?

**លោក ម៉ៃខល ផេសមិន៖**

បាទ តាមពិត គឺដូច្នោះមែន។ ម្សិលមិញ--

[១១:០០:៤៧]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ? ដូច្នោះអំមិញ? ដូច្នោះអីគេ ដូច្នោះហ្នឹង? បញ្ហាឥឡូវបញ្ហាថ្មី ឬក៏បញ្ហាចាស់?

**លោក ម៉ៃខល ផេសមិន៖**

បាទ ខ្ញុំមិនលើកពីបញ្ជីសាក្សីនោះទេ ខ្ញុំនឹងលើកដោយសង្ខេប។ ខ្ញុំ ម្សិលមិញ ខ្ញុំទទួលបានថាដែលលោកតុលាការនឹងត្រូវបិទនូវវគ្គទីមួយ នៃសវនាការអំពីប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជានេះ។ តើ

ចំណុចមួយនៅក្នុងចំណុចនេះ ខ្ញុំសូមជំទាស់ចំពោះការប្រកាស ឬក៏ការសម្រេចថានឹងផ្អាកវគ្គនេះ គឺដោយហេតុថា សំណួរចុងក្រោយរបស់ខ្ញុំ និងកូនក្តីរបស់ខ្ញុំ មិនត្រូវមិនបានផ្តល់ឱកាសឲ្យពិនិត្យលម្អិតទៅលើបរិបទប្រវត្តិសាស្ត្រនោះទេ។ បាទ មុននឹងបិទវគ្គសវនាការទីមួយនេះ គឺថាយើងខ្ញុំសូមអនុញ្ញាតដើម្បីឲ្យយើងខ្ញុំបានតទល់ ឬក៏អះអាងតបចំណុចនោះផងបាទ។

[១១:០១:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០២:៥៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីក្រោកឈរ!

កាលពីម្សិលមិញ អង្គជំនុំជម្រះបានផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់មេធាវីនៅក្នុងការតាំងសំណួរដេញដោលចំពោះកូនក្តីរបស់លោក។ ហើយអង្គជំនុំជម្រះបានព្យាយាមនៅក្នុងការដាស់តឿនលោក ដើម្បីឲ្យលោកប្រើសិទ្ធិនៅក្នុងសួរដេញដោលចំពោះកូនក្តីរបស់លោកច្រើនលើកច្រើនសា។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកមានចេតនាមិនប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យនៅក្នុងការតាំងសំណួរចំពោះកូនក្តីរបស់លោក ពាក់ព័ន្ធទៅនឹងអង្គហេតុនៅក្នុងក្របខ័ណ្ឌបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាតាមការកំណត់របស់អង្គជំនុំជម្រះទេ។

[១១:០៣:៥៥]

ដូច្នេះការនេះ គឺជារឿងដែលលោកលះបង់សិទ្ធិក្នុងការសួរដេញដោលដោយខ្លួនឯង មិនមែនអង្គជំនុំជម្រះដកហូតនូវសិទ្ធិនេះរបស់មេធាវីឡើយ។

ឥឡូវនេះដើម្បីចង់បានជាក់ច្បាស់ សួរថា សួរជាថ្មីម្តងទៀត ថាបំណងរបស់លោកដែលលើកឡើងនេះក្រៅពីរំខានដល់កិច្ចដំណើរការប្រព្រឹត្តទៅដ៏ប្រឹងប្រែងល្អប្រសើររបស់កិច្ចដំណើរការសវនាការ សួរថា តើលោកត្រូវការពេលវេលាប៉ុន្មាន ដើម្បីសួរដល់កូនក្តីរបស់លោក នៅក្នុងបណ្តាអង្គហេតុនៅក្នុងបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានេះ ពីព្រោះលោកបានប្រើពេលវេលាច្រើនហើយ។

**លោក ម៉ៃខល ផេសមិន៖**

មានបញ្ហាមួយចំនួនដែលខ្ញុំចង់ជម្រាបតុលាការ។ ទីមួយ ខ្ញុំមិនបានបោះបង់សិទ្ធិក្នុងការតាំងសំណួរកូនក្តីរបស់ខ្ញុំទេ។ ហើយក៏កូនក្តីរបស់ខ្ញុំក៏មិនបានបោះបង់សិទ្ធិថា មិនឆ្លើយចំពោះខ្ញុំដែរ។ ប៉ុន្តែ

ម្សិលមិញនោះ ខ្ញុំបញ្ជាក់តុលាការថាខ្ញុំមានសំណួរបី ឬបួន ជូនតុលាការ និងកូនក្តីរបស់ខ្ញុំ។ ខ្ញុំមិនអាចនិយាយច្បាស់ទេ ប៉ុន្តែការដែលខ្ញុំចាប់អារម្មណ៍នោះ គឺមិនបានប្រើ ថានឹងមិនប្រើពេលលើសពីសាមសិបនាទីទេ។ ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់លោកប្រធានថា ខ្ញុំធ្វើឲ្យនីតិវិធីនេះ អូសបន្លាយ ខ្ញុំនឹងជម្រាបតបទៅនៅពេលក្រោយ បាទ។

[១១:០៦:៣១]

**ប្រធានអង្គជំនុំ៖**

ឥឡូវម្តងទៀតលោក ផេសមិន លោកបង្ហាញច្បាស់លាស់មើល៍ តើលោកត្រូវការពេលវេលាប៉ុន្មាន ដើម្បីក្នុងការសួរកូនក្តីរបស់លោកពាក់ព័ន្ធនឹងអង្គហេតុទាក់ទិននឹងក្របខ័ណ្ឌបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា? សូមលោកគ្រាន់តែឆ្លើយការត្រូវការពេលវេលា នៅក្នុងការសួរដេញដោលចំពោះកូនក្តីរបស់លោក នៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការវគ្គមួយ ហើយបញ្ហាដែលសំណួរនៅសេសសល់តែប៉ុណ្ណោះ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំត្រូវការពេលសាមសិបនាទី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអង្គុយចុះ!

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៨:០៥]

សូមខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ តើលោកត្រូវការពេលវេលាប៉ុន្មានទៀត ដើម្បីក្នុងការបង្ហាញឯកសារនៅព្រឹកនេះ សម្រាប់ផ្នែកដែលត្រូវធ្វើនៅព្រឹកនេះ?

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំបញ្ជាក់ពីខាងដើមអ៊ីចឹង គឺថាយើងបានរៀបចំ ហើយយើងនឹងធ្វើការដាក់បង្ហាញភស្តុតាង ឬដាក់ជូនភស្តុតាងហ្នឹងថ្ងៃនេះ ហើយនិងថ្ងៃចន្ទ អង្គារ អាទិត្យក្រោយទៀត។ ហើយខ្ញុំបានត្រៀមជាស្រេចដើម្បីដាក់ជូនភាគី បើសិនជានៅសេសសល់ ខ្ញុំនឹងយកថ្ងៃចន្ទ និងថ្ងៃអង្គារ អាទិត្យក្រោយទៀត។ ហើយយើងខ្ញុំមានបញ្ជីរាយនាមឯកសារមួយចំនួនទៀត យើងខ្ញុំត្រូវការពេលនេះ ប្រហែលជាមួយម៉ោងទៀតលោកប្រធាន។ បាទ ដើម្បីឲ្យមានបញ្ជីនោះ ដើម្បីភាគី

អាចដឹងថា មានអ្វីខ្លះ ប៉ុន្តែថ្ងៃនេះ ខ្ញុំនៅសល់ពេលតែមួយម៉ោង។ ខ្ញុំត្រូវការពេលមួយទៀតប៉ុណ្ណោះ បាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១០:១៩]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយមានការស្នើសុំពីក្រុមមេធាវីការពារក្តីលោក នួន ជា ក្នុងការសួរកូនក្តីរបស់គាត់ ហើយដើម្បីបញ្ចប់បញ្ហានេះ អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំរបស់លោកមេធាវីការពារក្តីលោក នួន ជា នាពេលនេះ នៅក្នុងការតាំងសំណួរពាក់ព័ន្ធនឹងបញ្ហាបរិបទប្រវត្តិសាស្ត្រកម្ពុជា។ ចំណែកកិច្ចការរបស់លោកក្រុមសហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារ អង្គជំនុំជម្រះនឹងពិចារណាជម្រាបជូនដំណឹងនៅចុង នៅមុនពេលសម្រាកអាហារថ្ងៃត្រង់នេះ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះ!

*(ជនជាប់ចោទ នួន ជា ទៅកាន់ឈើរាងវង់ក្រចកសេះ)*

[១១:១១:២៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់ជម្រាបថា ខ្ញុំប្រហែលជាមួយម៉ោងសែសិបប្រាំនាទី ហើយសហសេវិកព្រះរាជអាជ្ញាជាតិក៏អាចនឹងមានឯកសារមួយចំនួន ដូចជា-- ហើយយើងមិនដឹងថា ពេលប៉ុនណាទេ ប្រហែលជាមួយម៉ោងសាមសិបនាទី ឬមួយម៉ោង។ អ៊ីចឹងគឺថាអាចមាន យើងត្រូវគោរពទៅតាមពេលដែលតុលាការសម្រេចថ្ងៃនេះ។ ប៉ុន្តែសល់ពេលប៉ុន្មាន យើងខ្ញុំនឹងយកទៅប្រើនៅថ្ងៃចន្ទ អង្គារ អាទិត្យក្រោយ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា កិច្ចការដែលលោកបែងចែកឲ្យលោកធ្វើការបង្ហាញឯកសារនៅថ្ងៃនេះ គឺលើកនៅពេលរសៀល បន្តធ្វើនៅពេលរសៀល ចាប់ផ្តើមពីម៉ោងមួយសាមសិននាទី។

អង្គជំនុំជម្រះប្រគល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការសួរដេញដោលកូនក្តីរបស់ខ្លួន ពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់នៅក្នុងក្របខ័ណ្ឌបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើសវនាការ ហៅថា វគ្គមួយនៃសំណុំរឿង

០០២/០១។

សូមអញ្ជើញ!

[១១:១៣:១៨]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក នួន ជា ខ្ញុំជឿថា ថ្ងៃទី២ ខែកុម្ភៈ ដែលខ្ញុំបានសួរលោកសំណួរចុងក្រោយនោះ លោកបានផ្តល់ចម្លើយវែងមួយ ហើយឥឡូវនេះ ខ្ញុំត្រឡប់ទៅរកចម្លើយរបស់លោកវិញ ហើយនិងសួរបន្ថែម។ មានបញ្ហាមួយចំនួនដែលលោកបានលើកឡើងនៅកាលនោះ។ ចំណុចមួយលោកនិយាយថា ក្រុមគ្រួសាររបស់លោក គឺមានមរណភាព ដូចជា ពុក-- អំមានបំណុល (សូមកែតម្រូវអ្នកបកប្រែ) គឺថាមានបំណុល ថាតើបំណុលនោះវាមានស្ថានភាពដូចម្តេច បាទ?

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន បំណុល នោះគឺមកពីរកស៊ីខាត លក់ស្រូវ ទិញស្រូវ ហើយក្រោយសង្គ្រាមលោកលើកទីមួយហ្នឹង ស្រូវសម័យហ្នឹងស្រូវសម័យនោះ វាចុះថ្លៃច្រើនណាស់។ ដូច្នោះ ឪពុកខ្ញុំនោះរកស៊ីខាតស្រូវ ហើយវាដឹកស្រូវយកទៅលក់នៅព្រៃនគរនោះ វាត្រូវខ្យល់ព្យុះលិចអស់ទៅ។ ដូច្នោះ ជំពាក់លុយគេ ខ្ចីគេ។

**ស៖** តើលោកអាចចង្អុលបង្ហាញទេថា បំណុលហ្នឹងចំនួនប៉ុនណាដែរ ជាលុយកាក់នោះបាទ ដែលថាវាមានផលប៉ះពាល់ខ្លាំងណាស់ដល់គ្រួសាររបស់លោកនោះ?

**ឆ៖** សូមជម្រាបគោរពលោកប្រធាន។ កាលណោះ ខ្ញុំនៅក្មេងខ្ញុំមិនដឹងទេ មិនដឹងខ្ចីប៉ុន្មានទេ ប៉ុន្តែសងគេទៅប្អូនដប់ម្ភៃឆ្នាំ សងតែការប្រាក់គេហ្នឹងមិនរួចផង។ នេះតាមខ្ញុំដឹង ឯចំនួនខ្ចីគេនោះ កាលណោះខ្ញុំនៅតូចខ្ញុំមិនដឹងដែរ។

**ស៖** ថាតើលោកដឹងទេក្រុមគ្រួសាររបស់លោក ឪពុករបស់លោកអាចសងបំណុលគេគ្រប់ទេ?

**ឆ៖** គោរពលោកប្រធាន ក្រុមគ្រួសារខ្ញុំសងបំណុលគេមិនគ្រប់ទេ រហូតដល់មកសម័យថៃគ្រប់គ្រងបាត់ដំបងទៀត ក៏សងនៅទាន់គ្រប់ទៀត សងគេជាលុយថៃផង។

[១១:១៦:១០]

**ស៖** នៅពេលដែលលោកបញ្ជាក់តុលាការចុងក្រោយ លោកក៏បានបញ្ជាក់ដែរថា លោកបានឃើញថា ឃើញគេវាយមនុស្ស គេវាយអ្នកបម្រើដែលធ្វើឱ្យលោកចាប់អារម្មណ៍ខ្លាំង។ តើលោកអាចជម្រាបតុលាការឱ្យលម្អិតជាងហ្នឹងបានដែរឬទេ អំពីហេតុការណ៍នៃការវាយដំមនុស្សជាខ្ញុំបម្រើនោះបាទ?

**ឆ៖** សូមគោរពលោកប្រធាន សម័យកាលនោះ នៅសម័យបារាំងគ្រប់គ្រងនៅឡើយ។ អ្នកដែលជំពាក់គេនោះ គឺអ្នកទៅស៊ីខ្ចីលុយគេ ហើយទៅធ្វើខ្ញុំគេរត់រ៉ឺម៉ក។ ហើយមិនដឹងជាយ៉ាងម៉េច បានជាយករ៉ឺម៉កនោះវាខូច បើតាមខ្ញុំដឹង អង្កាល់នោះខ្ញុំនៅក្មេងដែរ។ ដល់អ៊ីចឹងទៅ ចៅហ្វាយនោះឋានៈជាស្មៀនទេ ស្មៀនសាលាខេត្តបាត់ដំបង ឈ្មោះ លោកប្រធានឱ្យចេញឈ្មោះដែរ? សូមអនុញ្ញាត។ លោកប្រធានតើអនុញ្ញាតឱ្យចេញឈ្មោះទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក នួន ជា៖**

**ឆ៖** ហាក់ ស្រីណាល់។ ស្រាប់តែហៅគ្នាមកចាប់បាន ដឹងថារត់ហើយចាប់គ្នាយកមក ឱ្យគ្នាអង្គុយបត់ជើង ហើយគ្នាសុំទោស រួចទៅមិនអស់ចិត្ត ឱ្យអ្នកបម្រើហ្នឹងឡើងទៅលើផ្ទះ ទៅយកកាលនោះ អត់ទោសចុះប្រើពាក្យគេហៅថា ក្ដគោយកមកវ៉ៃក្បាលគ្នា។ គ្នាលើកដៃសំពះប៉ុន្មានដង ក៏មិនចេះមិននេះវ៉ៃ ទាល់តែជិតសន្លប់។ អាហ្នឹងរឿងមួយ។

[១១:១៨:០៦]

រឿងមួយទៀត ហ្នឹងក៏អ្នកបម្រើដែរ។ ប៉ុន្តែបម្រើឪពុកក្មេកឈ្មោះ កាលនោះកាលសម័យហ្នឹងគេហៅថា លោកអ្នកឧកញ៉ាស្នាក្ដី ឧកញ៉ា នូ ភឹង ឱ្យខ្ញុំបម្រើហ្នឹងវ៉ៃអ្នកបម្រើមួយទៀត ហើមមុខហើមមាត់អស់ ហើយគ្មានអ្នកណាយកទោសយកពៃអីទៅ។ មួយទៀត កាលពីសង្គ្រាមវាកើតមានសង្គ្រាមថៃហើយនិងបារាំង។ បារាំងយកពួកអាពួក*ឡេហ្សូនែរ* គេហៅហៅពួកទាហាន*ឡេហ្សូនែរ* គឺពួកប្រទេសដែលចំណុះបារាំងហ្នឹង យកទៅច្បាំងមានពួកម៉ារ៉ុកពួកអីៗ។ ពួកនេះដើរចាប់ស្រីចាប់ញី នៅក្នុងភូមិឃុំធ្វើបាបប្រជាជន ខ្ញុំកើតគំនិតថា ឱប្រទេសយើងហើយ គិតក្នុងចិត្តទេកាលនោះ នៅតូចមិនទាន់ដឹងអីប៉ុន្មាន មិនទាន់ស្គាល់បញ្ហាជាតិហ្នឹងស្អីច្បាស់លាស់ទេ ក៏ប៉ុន្តែនឹកអាណិតអាសូរជាតិឯង

ប្រជាជនឯង នឹកនោះណាស់។ អាហ្នឹងទៅដល់អ៊ីចឹងទៅ កើតអា-- ស្អប់អំពើអយុត្តិធម៌ តាំងពីហ្នឹងមកស្អប់អំពើអយុត្តិធម៌ហ្នឹងតែម្តង។

នេះរឿងទីបី រឿងក្នុងភូមិឃុំហ្នឹង តាំងពីពួកទាហានបារាំងចូលទៅច្បាំងហ្នឹង វៃកាប់ចាក់គ្នារាល់យប់។ នេះខ្ញុំសូមជម្រាបលោកប្រធាន។

[១១:២០:០០]

ដូច្នោះ អារម្មណ៍ខ្ញុំ វាស្អប់អយុត្តិធម៌ខ្លាំងណាស់ ក៏ប៉ុន្តែមិនដឹងធ្វើម៉េច។ បានតែក្រោយមក នែ៎! ខ្ញុំទៅរៀននៅថៃ ឆ្នាំ១៩៤១, ៤២, ៤៣ ហ្នឹង។ ទៅឯណោះទៀត ខ្ញុំស្មានតែថៃឯករាជ្យ ប៉ុន្តែការពិតមិនមែនឯករាជ្យ ធ្វើរដ្ឋប្រហារ បាញ់នាយក-- បាញ់រដ្ឋមន្ត្រីស្លាប់បីបួននាក់។ ខ្ញុំឃើញថា ហ៎! រកយុត្តិធម៌មិនឃើញទេ។ ដល់អ៊ីចឹងទៅ ខ្ញុំគិតថារៀនឥតប្រយោជន៍ មិនដឹងទៅបម្រើអ្នកណា បម្រើតែពួកជិះជាន់ពួកកាន់អំណាច។ ដូច្នោះ ឆ្នាំ១៩៥០ ខ្ញុំសុំឈប់រៀនហើយ ចេញមកតស៊ូ កាលណោះមានចលនាឥស្សរៈហើយតាំងពីឆ្នាំ១៩៤៦មកម្ល៉េះ។ ហើយខ្ញុំមកតស៊ូពីឆ្នាំ១៩៥០, ៥១, ៥២, ៥៣ វៀតណាមហ្នឹងដែលឈ្មោះ ង្វៀង ថាញ់ស៊ីន ហ្នឹងឲ្យខ្ញុំទៅរៀន ទៅភាគខាងជើងវៀតណាម។ ខ្ញុំទៅរៀនបានបីបួនឆ្នាំកិច្ចព្រមព្រៀងហ្សឺណែវសម្រេច ខ្ញុំត្រឡប់មកប្រទេសវិញ។ អាហ្នឹងអស់មួយរយៈទៅ ដល់មកត្រឡប់មកប្រទេសខ្ញុំវិញ កើតបារាំងទៅធ្វើបាបទៀតហើយ ធ្វើបាបពួកឥស្សរៈ ពួកណាដែល ព្រោះកិច្ចព្រមព្រៀងហ្សឺណែវហ្នឹងកំណត់ឲ្យអ្នកតស៊ូចាស់ហ្នឹង ចូលទៅរស់នៅក្នុងសង្គមជាតិ។ ទៅដល់ណោះរដ្ឋាភិបាល កាលណោះរដ្ឋាភិបាល លន់ នល់ ចាប់ដាក់គុក ដាក់ច្រវាក់ ខ្លះគ្នាក្រ សុទ្ធតែពួកអ្នកក្រទេធ្វើបដិវត្តន៍អង្កាល់ណោះ ហៅទៅធ្វើបដិវត្តន៍ ធ្វើបាប ធ្វើកម្មគ្នា រត់ចោលស្រុក ចោលស្រែ តស៊ូអ៊ីចឹងប៉ុន្តែចេះតែតស៊ូទៅ បើកើតអាបញ្ហាគេហៅឆ្នាំ១៩៦៧ កើតបញ្ហាសំឡូតតែម្តង។ អង្កាល់បញ្ហាសំឡូតហ្នឹង គ្មានអ្នកណាដឹកនាំទេ គឺប្រជាជនបះបោរខ្លួនឯង ក្រោកឡើងតស៊ូប្រឆាំងនឹងពួកជិះជាន់។

[១១:២២:៤៩]

ហើយសង្គ្រាមហ្នឹង វាតៗមក ដល់ឆ្នាំ១៩៧០ហ្នឹង កើតរដ្ឋប្រហារទម្លាក់សម្តេចព្រះករុណាដល់ទម្លាក់ព្រះករុណា។ ព្រះករុណាអំពាវនាវចូលព្រៃម៉ាកគី ទាំងពួកអ្នកខូច ទាំងពួកអ្នកល្អ ពួកអ្នកអីស្រឡាញ់ជាតិក៏ដោយ មិនស្រឡាញ់ជាតិក៏ដោយ រត់ចូលព្រៃម៉ាកគីទៅ អាពួកផ្តៀតឱកាសនិយមហ្នឹងក៏ផ្តៀតឱកាសនិយមប្លន់ប្រជាជន។ គិតទៅមួយរយៈប្រមាណសិបឆ្នាំហ្នឹង ប្រជាជនគ្មានសេចក្តីសុខទេដេកៗតែព្រៃទេ ដេកតែព្រៃចេកទេយប់ៗ។ ដល់តស៊ូទៅ តស៊ូមក កើតមានចលនាឥស្សរៈហ្នឹងចេះតែ

រីកធំឡើង ប៉ុន្តែឥស្សរៈមួយចំនួនក្លែង-- ឥស្សរៈក្លែងក្លាយ ដើរតែប្លន់ ដើរតែអី រកតែលុយ ដើម្បីដាក់ហោប៉ៅ។ ហើយបានមានឥស្សរៈមួយក្រុមហ្នឹង ដែលមានវៀតណាមគេជួយឧបត្ថម្ភផងដែរ និយាយឲ្យត្រង់ទៅ។ ក៏ប៉ុន្តែវៀតណាមហ្នឹងធ្វើជាចូលទៅ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវហ្នឹង វៀតណាមអត់ចេញមកអត់ទេ ទុកអ្នកជំនាញការមួយចំនួនសម្រាប់គ្រប់គ្រងប្រទេស មើលការខុសត្រូវប្រទេសកម្ពុជា។ ក៏ប៉ុន្តែចូលក្នុងប្រជាជនខ្មែរមិនសូវចុះ ប្រជាជនខ្មែរក៏មិនស្រឡាញ់វៀតណាម មិនចូលចិត្តវៀតណាមដែរទេ។ តើសង្គ្រាមម្តងទៀតហើយ កើតសង្គ្រាមរវាងខ្មែរ និងវៀតណាមទៀត អានេះខ្ញុំសុំសរុបដោយខ្លីប៉ុណ្ណឹងចុះ។

[១១:២៤:៥៥]

**ស៖** សូមអរគុណលោក នួន ជា។ លោក ទើបតែនិយាយថា លោកបានឃើញទាហានបារាំង ឬក៏ពួក*ឡេហ្សូនែរ* ដែលបានមកតំបន់ក្នុងភូមិរបស់លោក ហើយបានប្រព្រឹត្តខុសលើស្ត្រី រំលោភ ថា តើប្រព្រឹត្តខុសលើស្ត្រីនោះ មានន័យថា រំលោភសេពសន្ថវៈឬ?

**ឆ៖** ត្រូវហើយបាទ។ គឺរំលោភសេពសន្ថវៈ។ ពួកនេះ ឃោរឃៅណាស់។ ដូច្នោះ សរុបមកមួយជីវិតរបស់ខ្ញុំនោះ គ្មានសេចក្តីសុខទេ អសន្តិសុខក្នុងចិត្ត អសន្តិសុខក្នុងខួរក្បាលទាំងអស់ ហើយកើតមានអី គំនិតខ្លាច។ ក៏ប៉ុន្តែដល់បានទៅរៀននៅថៃ ដូចជាមានស្មារតីជាតិ។ មានស្មារតីជាតិ មានចលនាឥស្សរៈ ខ្ញុំចេញមកតស៊ូនឹងគេដែរ។

**ស៖** សូមអរគុណ។ នៅក្នុងលោក-- ពីសប្តាហ៍មុន លោកបាននិយាយផងដែរ ថាមានមនុស្សម្នាក់ឈ្មោះ ហេង សំរិន។ តើលោកអាចជម្រាបតុលាការបានទេ នៅពេលលោកជួបគាត់ដំបូង ជួបពេលណា?

**ឆ៖** សូមជម្រាបលោកប្រធាន។ ខ្ញុំបានជួបគាត់ដំបូង នៅបូព៌ា ភូមិភាគបូព៌ា។ គាត់ធ្វើការជាមួយ សោ ភឹម ហើយសោ ភឹម ហ្នឹង ប្រគល់លោក ហេង សំរិន ហ្នឹង ដើម្បីជូនខ្ញុំទៅមក ពីប្រទេសកម្ពុជា ទៅព្រំដែនថៃ ដើម្បីទៅទាក់ទងជាមួយវៀតណាម។ បើគេហៅថាពីកាលណោះ គេហៅថានីរសារ។ គាត់ជាអ្នកល្អទេ ជាអ្នកត្រឹមត្រូវ ប៉ុន្តែក្រណាស់ រកតែក្របីឃ្វាលគ្មានផង។ ព្រឹកព្រហាម ពីយប់ ដើរមកយប់ ពីដីខ្មែរទៅដីវៀតណាម ព្រឹកឡើងត្រូវត្រឡប់មកដល់ផ្ទះវិញ ដើម្បីស្ទូងស្រូវ កុំឲ្យពួកគិញ ពួកអីវាចាប់អារម្មណ៍។

[១១:២៨:០៤]

**ស៖** តើលោកចាំទេ លោកជួបគាត់នោះ គឺនៅមុន ឬក៏ក្រោយសន្និសីទក្រុងហ្សឺណែវ បាទ គឺឆ្នាំ១៩៥៤?

**ឆ៖** សូមជម្រាបលោកប្រធាន។ នេះ ដូចជាខ្ញុំជួបគាត់ហ្នឹង ដូចក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ប៉ុន្តែខ្ញុំមិនច្បាស់ដែរទេ។

**ស៖** តើលោកអាចរៀបរាប់លម្អិតបន្តិចទៀតទេ អំពីការជួបជាមួយគាត់ដំបូងនោះ ថាតើក្នុងការជួបនោះ ធ្វើការងារអ្វីខ្លះ? មានរឿងអ្វីកើតឡើងដែរទេ?

**ឆ៖** គោរពលោកប្រធាន ក្នុងការជួបកាលដំបូងហ្នឹង គឺខាង សោ ភឹម ហ្នឹង គាត់ប្រគល់ភារកិច្ចឱ្យលោក ហេង សំរិន ហ្នឹង សម្រាប់ជូនដំណើរការពារខ្ញុំ បីបួននាក់ ប៉ុន្តែយប់ ខ្ញុំមិនស្គាល់មុខអីទេ ស្គាល់តែលោក ហេង សំរិន ម្នាក់ឯងហ្នឹង។ ពីព្រោះគាត់នៅជាប់ជាមួយខ្ញុំ ប៉ុន្តែគាត់ក៏ក្លាហានដែរ ការពារ។

[១១:២៩:៤៦]

**ស៖** ហើយគាត់បានអមដំណើរលោក រហូតទៅដល់ព្រំដែនវៀតណាម ត្រូវដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ត្រូវហើយ។ គាត់ជូនដំណើរខ្ញុំទៅដល់វៀតណាម ខាងវៀតណាមគេមកទទួលត្រង់ជាយដែន។ ប៉ុន្តែដីហ្នឹងវាមិនច្បាស់ជាដីខ្មែរ ឬដី វៀតណាមផងទេ។ ប៉ុន្តែបើតាមខ្ញុំថា ប្រហែលជាដីខ្មែរហើយ ប៉ុន្តែវៀតណាមយកនៅទៅ។

**ស៖** ចាតើគាត់នៅរង់ចាំរហូតទល់ត្រឡប់មកវិញ ឬក៏ដើម្បីចាំលោកការពារលោកត្រឡប់មកវិញ ឬក៏គាត់ត្រឡប់មកវិញមុន?

**ឆ៖** គោរពលោកប្រធាន គាត់ត្រឡប់មកធ្វើស្រែ គាត់ត្រឡប់មកផ្ទះមុន ដើម្បីកុំឱ្យបាត់មុខពីផ្ទះ។ បើបាត់មុខពីផ្ទះគិញវាយកចិត្តទុកដាក់។ ហើយដល់ពេលណាត់គ្នា បានគាត់ទៅទទួលខ្ញុំមកវិញ។ ផ្លូវត្រង់ហ្នឹង គេហៅផ្លូវកណ្តោលជ្រុំ។ ទៅចុះទីប្រជុំជនកណ្តោលជ្រុំ ហើយដើរទៅខាងត្បូងទៅ ហើយទៅខាងចុះទៅ ទៅខាងវៀតណាម។

**ស៖** ពេលដែលលោកជួបលោក ហេង សំរិន លើកដំបូងហើយនាំលោកទៅព្រំដែនវៀតណាម តើលោកចាំទេ ថាតើលោកទៅជួបនរណាដែរ? គេនាំទៅជួបនរណាដែរនៅវៀតណាមនោះ ជិតព្រំដែនវៀតណាមនោះ?

[១១:៣១:៣៦]

**ឆ៖** នៅ-- គោរពលោកប្រធាន។ កាលនោះជួបតែម្នាក់ទេ ង្វៀន វ៉ាន់លិញ គាត់ជួបខ្ញុំ។ គាត់សួរពីសភាពការណ៍នៅប្រទេសកម្ពុជាយ៉ាងម៉េច អីយ៉ាងម៉េច? ហើយក្រៅពីជួប ង្វៀន វ៉ាន់លិញ ក្រោយមកខ្ញុំជួប ផាំ ហ៊ុង។ ផាំ ហ៊ុង និង ង្វៀន វ៉ាន់លិញ ហ្នឹងខុសគ្នា។ ផាំ ហ៊ុង គាត់ចិត្តក្តៅបន្តិច ង្វៀន វ៉ាន់លិញ គាត់ទោះបីមានបាត់អីៗក៏គាត់មិនសូវប្រតិកម្មទេ។ ហើយដល់ក្រោយមកទៅជួបទៀត ព្រោះខាងវៀតណាមគេសង្កត់មិនឲ្យយើងតស៊ូ ប៉ុន្តែឆ្នាំនោះ៦០ហើយ វៀតណាមចាប់ផ្តើមតស៊ូអាវុធខ្លះហើយ។ ហើយគេមិនឲ្យខ្មែរហ្នឹងកុំឲ្យតស៊ូអាវុធរួមផ្សំនយោបាយ ឲ្យតស៊ូនយោបាយទទេ។ ពីព្រោះបើមិនអ៊ីចឹងទេ វាប៉ះពាល់ដល់ផ្លូវដឹកជញ្ជូនអាវុធ ពីកំពង់សោម ទៅដល់ដីវៀតណាមនោះ។ ហើយ ង្វៀន វ៉ាន់លិញ អ៊ំន៎ែ! ង្វៀន វ៉ានលិញ ហ្នឹងគេនិយាយប្រាប់ខ្ញុំ គេថាយើង ខ្មែរណ៎ា យើងត្រូវរៀនសូត្រពីអ៊ំហូ ហូជីមិញនោះ។ បានខ្ញុំឆ្លើយទៅវិញថា ពួកខ្ញុំរៀនសូត្រពីបក្សធំច្រើនហើយ ឥឡូវឲ្យបក្សធំស្តាប់បក្សតូចខ្លះផង ឲ្យខ្ញុំលះបង់តស៊ូអាវុធ បក្សខ្ញុំខ្ទេចខ្ទីអស់ហើយ។

**ស៖** ការធ្វើដំណើរដំបូងទៅវៀតណាម ជាមួយនឹងលោក ហេង សំរិន ថាតើប្រហែលជានៅក្នុងឆ្នាំ១៩៥៩ មែនដែរឬទេ?

[១១:៣៤:០៤]

**ឆ៖** គោរពលោកប្រធាន ប្រហែលប៉ុណ្ណឹង។

**ស៖** តើលោក ហេង សំរិន បាននាំលោកទៅព្រំដែនវៀតណាមនោះញឹកញយប៉ុនណាដែរក្រោយពីបានធ្វើដំណើរលើកដំបូងទៅព្រំដែននោះ?

**ឆ៖** គោរពលោកប្រធាន ជួនណាពីរខែម្តង សម្រេចនឹងខាងមានការប៉ះទង្គិចអីគ្នា ខ្ញុំត្រូវ-- ព្រោះខ្ញុំមានភារកិច្ចមួយនៅ ន៎ែធ្វើជាគណៈទាក់ទងជាមួយវៀតណាម។ មានការទំនាស់អីគឺជួនណាខ្ញុំទៅដោះស្រាយជាមួយវៀតណាម ជួនណា ប៉ុល ពត ទៅដោះស្រាយជាមួយវៀតណាម។ មានការប៉ះទង្គិចខាងកងទ័ពញឹកញាប់។ ព្រោះវៀតណាមហ្នឹងចង់ជ្រៀក-- មិនមែនចង់ទេ វៀតណាមហ្នឹងជ្រៀតជ្រែកចូលមកដីកម្ពុជាហើយ ចូលមកដីហើយ ពីព្រោះកាលនោះអាមេរិកទម្លាក់គ្រាប់បែកខ្លាំងណាស់ វៀតណាមរកដីនៅគ្មានទេ។ ហើយចូលមកនៅដីកម្ពុជាៗ គេជួយ ប៉ុន្តែថាសូមឲ្យគោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដីរបស់កម្ពុជាផង។ ក៏ប៉ុន្តែវៀតណាម ពួក-- សំខាន់ពួកខាងក្រោមៗ ពួកកងទ័ពហ្នឹងវាអត់គោរពទេ។

[១១:៣៥:៥២]

**ស៖** នៅពេលណាដែលលោក ហេង សំរិន បាននាំលោកទៅព្រំដែនវៀតណាមជាលើកចុងក្រោយនោះ តើលោកចាំដែរឬទេ?

**ឆ៖** ចុងក្រោយ-- គោរពលោកប្រធាន ខ្ញុំមិនចាំទេ ប៉ុន្តែថាចាប់ផ្ដើមវៀតណាមចូលបុករុកប្រទេសខ្មែរហើយ ឆ្នាំ១៩៧៩។

**ស៖** សូមអភ័យទោស សំណួររបស់ខ្ញុំនេះ គឺចង់សួរថាតើលោក ហេង សំរិន បាននាំលោកទៅព្រំដែនវៀតណាមនៅចុងក្រោយហ្នឹងក្នុងឆ្នាំណាដែរ? តើលោកចាំឆ្នាំដែរឬទេ?

**ឆ៖** ខ្ញុំចាំតែឆ្នាំវៀតណាមចូលឈ្លានពានកម្ពុជា មកឆ្នាំ១៩៧៩ ដើមឆ្នាំ។ ៧៨, ៧៩ ហ្នឹង ក៏ប៉ុន្តែមិនមែនទើបហ្នឹងចូលណ៎ា! ចូលមកយូរណាស់ហើយ ពីព្រោះវៀតណាមមានកន្លែងនៅឯណា អត់មានកន្លែងនៅ។ វៀតណាម២៥០.០០០ ខ្ញុំសូមជម្រាបអ៊ីចេះ ចូលមកប្រទេសកម្ពុជា ហើយខ្ញុំជួបៗ មេបញ្ជាការស្រីរបស់រណសិរ្សវៀតណាមហ្នឹងឈ្មោះ ង្វៀន វ៉ាន់ឌិញ មកជួប សោ ភឹម។ ប៉ុន្តែអត់និយាយជាមួយខ្ញុំទេ ដល់ត្រឡប់ទៅវិញ ខ្ញុំសួរ សោ ភឹម ថា អ្នកស្រី ង្វៀន វ៉ាន់ឌិញ ហ្នឹងគាត់មកធ្វើអី? ថាមកសុំកន្លែងនៅ ពីព្រោះកន្លែងវៀតណាមហ្នឹង នៅមិនបានទេ ពីព្រោះអាមេរិកទម្លាក់គ្រាប់បែកខ្លាំងណាស់។ ខ្ញុំថា អើ! គេក៏រើវៀតណាមដែរ-- អ៊ំ គេក៏រើអាមេរិកដែរ រកកន្លែងឲ្យនៅខ្លះទៅ។ ហើយមិនមែននៅតែមួយកន្លែងណា ស្បៀងអាហារអីនៅលើខ្មែរទាំងអស់ ហូបចុកអីៗ។

[១១:៣៨:២៩]

**ស៖** សូមអរគុណលោក នួន ជា។ ប៉ុន្តែខ្ញុំសូមសួរសំណួរ រៀបចំសំណួរឡើងវិញ តើលោក ហេង សំរិន ដែលជាអ្នកនាំផ្លូវលោក ហើយជាមនុស្សម្នាក់ដែលនាំលោកទៅព្រំដែនវៀតណាមដោយសម្ងាត់នោះ ថាតើគាត់ធ្វើការងារហ្នឹងរយៈពេលប៉ុន្មានដែរជូនលោកហ្នឹង?

**ឆ៖** គាត់ធ្វើតាំងពីចប់កិច្ចព្រមព្រៀងហ្សឺណែវ រហូតដល់វៀតណាមចូលច្រើនឆ្នាំដែរ ប្រហែលជាប្អូនឆ្នាំ ប្រាំមួយឆ្នាំហ្នឹង ជាងផង។

**ស៖** តើគាត់បំពេញការងារនុ៎ង គឺគាត់ធ្វើរយៈពេលប៉ុន្មានដែរ? បានន័យថា គាត់បម្រើការងារហ្នឹងតាំងពីទសវត្សរ៍៦០, ៧០ ហើយគាត់បានដឹកនាំលោកទៅព្រំដែនវៀតណាមហ្នឹងចុងក្រោយនៅក្នុងឆ្នាំណាដែរ គឺឆ្នាំ៧០ ឬ៧៥?

**ឆ៖** ចុងក្រោយដូចឆ្នាំ៧៥។ ៧៥ រំដោះ ដល់រំដោះមានផ្លូវផ្សេងទៅទាក់ទងវៀតណាម ដូច្នោះមិនបាច់ដើរកាត់ព្រៃ ដូច្នោះកាលណោះលោក ហេង សំរិន ហ្នឹងតាមខ្ញុំចាំគាត់ឡើងធ្វើជាឧត្ដម មេបញ្ជា

ការធ្វើមេន៉ែ ហៅ មេបញ្ជាការកងទ័ពហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមមិនជំទាស់ទៅនឹងសំណួរទាំងអស់នោះ ដោយសារតែសំណួរនោះ ហាក់ដូចជាមានការពាក់ព័ន្ធតិចតួចណាស់ទៅនឹងប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា ហើយមេធាវីការពារក្ដីមានរយៈពេលតែកន្លះម៉ោងតែប៉ុណ្ណោះ។ ដូច្នេះហើយ ទោះបីយ៉ាងនេះក៏ដោយគឺខ្ញុំសូមឲ្យអង្គសវនាការធ្វើការកម្រិតការតាំងសំណួររបស់មេធាវីការពារក្ដី សួរសំណួរតែទៅលើប្រវត្តិដែលពាក់ព័ន្ធទៅនឹងបក្សកុម្មុយនីស្តកម្ពុជានៅមុនឆ្នាំ១៩៧៥ គឺមិនឲ្យ-- គឺមិនអាចសួរទៅក្រោយរយៈពេលនោះទេ។ សូមអរគុណ។

[១១:៤១:១០]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ខ្ញុំជិតបញ្ចប់សំណួររបស់ខ្ញុំហើយ ខ្ញុំសូមសួរសំណួរចុងក្រោយ តើលោកដឹងតួនាទីលោក ហេង សំរិន ផ្សេងទៀតដែរឬទេ ក្រៅពីអ្នកការពារលោកទៅព្រំដែនវៀតណាមនោះ? តើគាត់មានមុខងារជាផ្លូវការអ្វីដែរ នៅក្នុងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មុនពេលរំដោះទីក្រុងភ្នំពេញនោះ?

**លោក នួន ជា៖**

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ។ ហើយសំណួរនេះមិនពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ-- ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាទេ។ មេធាវី ពេលវេលាសម្រាប់លោកដែលបានសុំ គឺអស់ហើយ។

**លោក ម៉ៃខល ផេសមិន៖**

តើខ្ញុំសូមអាចអនុញ្ញាតសួរតែមួយសំណួរចុងក្រោយដែរឬទេ ដែលសំណួរនេះ ខ្ញុំគិតថាវាពាក់ព័ន្ធ?

**ប្រធានអង្គជំនុំ៖**

បើលោកយល់ថា ពាក់ព័ន្ធអាចសួរបាន ប៉ុន្តែបើមិនពាក់ព័ន្ធទេ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសួរ

ទេ ឬក៏មិនអនុញ្ញាតឲ្យឆ្លើយទេ។ សំណួរអម្បាញ់មិញនេះ អង្គជំនុំជម្រះបានបដិសេធរួចទៅហើយ មិនឲ្យជនជាប់ចោទឆ្លើយទេ ដោយវាមិនពាក់ព័ន្ធនៅក្នុងបរិបទប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា។

សូមអញ្ជើញសំណួរចុងក្រោយ!

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

**សៈ** មេធាវីលោក នួន ជា សំណួរចុងក្រោយរបស់ខ្ញុំនោះ គឺថាតើត្រឹមត្រូវដែរឬទេ ដែលលោក ហេង សំរិន គឺជាមេដឹកនាំកងពលនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយគាត់ដឹកនាំក្នុងការរំដោះទីក្រុងភ្នំពេញផង ហើយគាត់គឺជាមេបញ្ជាការមួយក្នុងការនាំទៅដល់ការរំដោះទីក្រុងភ្នំពេញមុនឆ្នាំ ១៩៧៥ តើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំៈ**

លោក នួន ជា មិនបាច់ឆ្លើយទេ។ សំណួរនេះ មិនពាន់ព័ន្ធទេ សំណួរនេះបានអង្គជំនុំជម្រះបានបដិសេធរួចហើយអម្បាញ់មិញ។

[១១:៤៣:៥៦]

បាទ ឥឡូវនេះ ពេលវេលាសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយដែរ ហើយអង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោក ម៉ៃខល ផេសមិនៈ**

លោកប្រធាន ខ្ញុំសូមធ្វើសំណើធម្មតា ទូទៅដូចរាល់ថ្ងៃ បានន័យថា សូមអនុញ្ញាតឲ្យកូនក្ដីរបស់ខ្ញុំនេះទៅបន្តតាមដានសវនាការនៅបន្ទប់រង់ចាំខាងក្រោម។ ដូច្នេះគឺគាត់ស្នើសុំបោះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណ ហើយខ្ញុំនឹងប្រគល់ឯកសារជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះនៅពេលក្រោយ។

**ប្រធានអង្គជំនុំៈ**

អញ្ជើញលោកសហព្រះរាជអាជ្ញា!

[១១:៤៤:៥៣]

**លោក ឌេល លីសាក់ៈ**

សូមអរគុណ លោកប្រធាន យើងមិនជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្ដីនោះទេ ក៏ប៉ុន្តែ

នៅពេលរសៀលគឺយើងមានផែនការក្នុងការបង្ហាញឯកសារនានា។ ដូច្នេះហើយ យើងអាចស្នើសុំឲ្យលោក នួន ជា ហ្នឹងផ្តល់ជាឱកាសឲ្យគាត់ឆ្លើយតបទៅនឹងឯកសារទាំងអស់នោះ។ ដូច្នេះហើយ យើងខ្ញុំចង់ឲ្យគាត់ហ្នឹងមានវត្តមាននៅក្នុងបន្ទប់សវនាការនេះដោយផ្ទាល់។ សូមអរគុណ។

**លោក ម៉ៃខល ផេសមិនៈ**

ប្រសិនបើខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប កូនក្តីរបស់ខ្ញុំហ្នឹង នឹងតាមដាននីតិវិធីនៅបន្ទប់រង់ចាំខាងក្រោម។ បន្ទប់រង់ចាំខាងក្រោមនេះមានរៀបចំក្នុងគោលបំណងឲ្យគាត់តាមដានពីចម្ងាយ ហើយប្រសិនបើចង់ឲ្យគាត់ផ្តល់យោបល់ទៅលើឯកសារ ដែលបង្ហាញជូនដោយខាងសហព្រះរាជអាជ្ញានោះ គឺគាត់អាចធ្វើមកបាន។ សូមអរគុណ។

[១១:៤៥:៤៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៨:៤០]

**ប្រធានអង្គជំនុំៈ**

បានស្តាប់សំណើសុំរបស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា បានស្នើសុំឲ្យកូនក្តីរបស់ខ្លួនទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងរសៀលនេះ ដោយលះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅរសៀលនេះ។

បានស្តាប់នូវមតិកត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានកត់សម្គាល់អំពីអត្ថប្រយោជន៍នៃការ ដែលមានវត្តមានជនជាប់ចោទនៅក្នុងអំឡុងពេលខ្លួនដាក់បង្ហាញឯកសារភស្តុតាងដើម្បីជនជាប់ចោទមានឱកាសតទល់ ឬក៏ធ្វើអត្ថាធិប្បាយលើឯកសារដែលខ្លួនបានដាក់ចំពោះមុខ។ អង្គជំនុំជម្រះយល់ឃើញថា កិច្ចដំណើរការប្រព្រឹត្តទៅនៅក្នុងសវនាការនៅរសៀលនេះ គឺការបង្ហាញឯកសារដោយសហព្រះរាជអាជ្ញា ដែលជាឯកសារដាក់បន្ទុកលើជនជាប់ចោទ។ ជនជាប់ចោទមានឱកាសនៅក្នុងការពិនិត្យ ស្តាប់ មើលនូវឯកសារភស្តុតាងដែលដាក់ដោយសហព្រះរាជអាជ្ញា ហើយនិងមានអាចមានមតិយោបល់ ហើយកិច្ចដំណើរការសវនាការនៅរសៀលនេះមានប្រយោជន៍សំខាន់ខ្លាំងណាស់ចំពោះជនជាប់ចោទ។

ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើសុំរបស់លោក នួន ជា ដែលធ្វើតាមរយៈមេធាវីរបស់គាត់ស្នើសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចសវនាការដោយផ្ទាល់នៅក្នុងរសៀលនេះ ដោយ

ទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម។

បង្គាប់ឲ្យជនជាប់ចោទត្រូវមានវត្តមាននៅរសៀលនេះ ចំពោះកិច្ចការផ្សេងទៀត អង្គជំនុំជម្រះនឹងពិនិត្យពិចារណាទៅតាមស្ថានភាពជាក់ស្ដែង។

សូមអញ្ជើញលោក នួន ជា!

[១១:៥០:៥៤]

**លោក នួន ជា៖**

សុខភាពខ្ញុំស្រុតកាន់តែទន់ខ្សោយហើយ ខ្ញុំទៅមិនរួចទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ ហើយកិច្ចការនេះគ្រាន់តែលោកមានវត្តមាននៅទីនេះ ប្រសិនបើលោកមិនចង់ធ្វើអ្វី អត្ថាធិប្បាយអ្វី នោះជាសិទ្ធិរបស់លោក។ ហើយអង្គជំនុំជម្រះនឹងពិនិត្យពិចារណាទៅតាមស្ថានភាពជាក់ស្ដែងនាពេលរសៀល។

អង្គជំនុំជម្រះសម្រេចរួចហើយ រសៀលហ្នឹងគឺឲ្យលោកមកវិញណា។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់--

[១១:៥១:៣៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥១:៥៤]

ហេតុផលអង្គជំនុំជម្រះបានសម្រេចរួចហើយ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយឲ្យនាំពួកគាត់ឡើងមកកាន់សាលសវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

*(សវនាការសម្រាកពីម៉ោង ១១:៥២នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តធ្វើការដាក់បង្ហាញឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

នៅពេលដែលយើងបានឈប់ត្រង់ចំណុច ដែលខ្ញុំបានបង្ហាញអំពីសុន្ទរកថាដែលបានរាយការណ៍ថា លោក នួន ជា បានធ្វើសុន្ទរកថាក្នុងនាមខ្លួនជានាយករដ្ឋមន្ត្រីស្តីទី។ ជនជាប់ចោទ នៅពេលនេះគឺគាត់បានលើកការជំទាស់ ដែលថាគាត់មិនបានទទួលឋានៈក្នុងនាមជា នាយករដ្ឋមន្ត្រីស្តីទីនោះឡើយ។ ឯកសារនេះគឺ D56- ឯកសារលេខ 060 ERN គឺអង់គ្លេស ERN ជា S0003883 រហូតដល់ 3884។ ខ្មែរ ERN គឺ S0066200 ទៅដល់ 004។ បារាំង គឺ S00632833។ ឯកសារនេះ គឺជារបាយការណ៍នៅក្នុងសេចក្តីសង្ខេបរបស់វិទ្យុ ប៊ី.ប៊ី.ស៊ី ដែលមានចំណងជើងថា "ប៉ុល ពត ឈប់សម្រាកដោយសារឈឺពីតំណែងនាយករដ្ឋមន្ត្រីរបស់ខ្លួន"។ ខ្ញុំសូមដកស្រង់សម្តី៖ "តាមសំណើរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ក្នុងពេលប្រជុំថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយស្របតាមសេចក្តីសម្រេចខែកញ្ញា ឆ្នាំ១៩៧៦ ដោយសភាតំណាងប្រជាជន។ គណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ចំណុចទី១ បានសម្រេចឲ្យសមមិត្ត ប៉ុល ពត ជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យឈប់សម្រាក ដោយសារជំងឺដើម្បីថែទាំសុខភាពដែលបញ្ហាសុខភាពនេះ មានបញ្ហារយៈពេលពីរបីខែរួចមកហើយ។ ទីពីរ គឺសម្រេចតែងតាំង នួន ជា ដែលជាប្រធានសភាតំណាងប្រជាជន ឲ្យជំនួសតំណែងរបស់លោក ប៉ុល ពត ជាបណ្តោះអាសន្ន ហើយទទួលបានឋានៈជានាយករដ្ឋមន្ត្រីស្តីទី បន្ថែមទៅលើតួនាទីនៅពេលនោះ។ សេចក្តីសម្រេចនេះ គឺមានអានុភាពចាប់ពីថ្ងៃ២៧ ខែកញ្ញា ឆ្នាំ១៩៧៦។ ចុះហត្ថលេខាគណៈប្រធានរដ្ឋគឺលោក ខៀវ សំផន ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦"។

[១៣:៣៧:១២]

ដូច្នេះ នៅក្នុងរឿងក្តីដំណាក់កាលសវនាការដទៃទៀតនោះ គឺមានបង្ហាញអំពីសេចក្តីសុន្ទរកថា និងសេចក្តីថ្លែងការណ៍ដែលនិយាយអំពីជ័យជម្នះក្នុងនាមលោក នួន ជា ជានាយករដ្ឋមន្ត្រីស្តីទី។ ហើយលោកគាត់បានធ្វើសុន្ទរកថា និងចុះហត្ថលេខាទៅលើឯកសារមួយចំនួន ក្នុងនាមក្នុងពេលដែលគាត់ជានាយករដ្ឋមន្ត្រីស្តីទី។ ដូច្នេះហើយគឺ ខ្ញុំសូមអនុញ្ញាតសួរទៅកាន់ជនជាប់ចោទ ហើយសូមឲ្យជនជាប់ចោទផ្តល់ជាអត្ថាធិប្បាយប្រសិនបើខ្លួនចង់។

[១៣:៣៨:០១]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញលោក នួន ជា តើលោកមានចង់ធ្វើអត្ថាធិប្បាយអ្វីទេ លើឯកសារដែលខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញអម្បាញ់មិញនេះ។

**លោក នួន ជា៖**

លោកប្រធាន។ ខ្ញុំមិនដែលបានដឹងឯកសារ មិនដែលបានឃើញឯកសារហ្នឹងផងទេ។ បើពេលដែល ប៉ុល ពត ឈឺៗប្រាំមួយខែទៅដេកនៅស្រុកចិនន៎ៃ គឺអ្នកជំនួស ប៉ុល ពត នោះគឺ សុន សេន ទេ។ សុន សេន ពីព្រោះ ប៉ុល ពត ត្រៀមឲ្យ សុន សេន ជំនួស មិនមែនខ្ញុំទេ បើៗថាលោក មានឯកសារមកឲ្យខ្ញុំសុំមើលមើល៍។ លោកយកឯកសារមកមើល៍។ បានឯកសារពីណាមក? ព្រោះខ្ញុំជាប់នាទីទៅខាងប្រធានសភា។ នេះខ្ញុំសូមជម្រាបលោកប្រធានប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញត! តំណាងសហព្រះរាជអាជ្ញាអន្តរជាតិតការងាររបស់លោក។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឯកសារបន្ទាប់ ដែលយើងចង់ដាក់ជូនគឺ ឯកសារទង់បដិវត្តចុះខែធ្នូ ឆ្នាំ១៦៧៦ (ស៊ីក) ដល់ខែមករា ឆ្នាំ១៩៧៧ ឯកសារនេះមានលេខ D243/2.1.9។ ហើយបានដាក់លេខកូដសម្គាល់ដោយសាលាដំបូង គឺឯកសារ E3/25។ មានចំណុចពីរចំណុច ដែលយើងខ្ញុំចង់លើកឡើងបង្ហាញជូន។ ឯកសារដែលខ្ញុំយោងនៅក្នុងនេះ គឺត្រង់ចំណុចដែលជាបទបង្ហាញ ដោយសមមិត្តតំណាងកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី-- នៅខួបរំឭកលើកទី៩ ទៅលើកងទ័ពបដិវត្តន៍កម្ពុជា។ ខ្ញុំគិតថា ខ្ញុំបានលើកឡើងចំណុចនេះពីមុន ក៏ប៉ុន្តែប្រសិនបើយើងប្រៀបធៀបឯកសារនេះទៅលើឯកសារមុនដែលខ្ញុំបានលើកឡើង យើងឃើញថាឯកសារនេះ គឺបង្ហាញសុន្ទរកថាទាំងមូលដែលបានថ្លែងដោយ នួន ជា នៅក្នុងពិធីរំឭកខួបលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជា។ ហើយវាឯកសារនេះ គឺស្របទៅនឹងឯកសារដែលខ្ញុំបានបង្ហាញនៅក្នុងពេលមុន។

[១៣:៤១:០៤]

ចំណុចទីមួយ ផ្នែកទីមួយដែលខ្ញុំចង់បង្ហាញ ERN ជាភាសាអង់គ្លេស គឺ 00491441។ ខ្មែរ ERN គឺ 00063021។ បារាំង គឺ 00504032 កថាខណ្ឌទី១ ដែលនិយាយអំពីប្រវត្តិសង្ខេបនៃកំណើត

កងទ័ពបដិវត្តន៍កម្ពុជា។ ការដកស្រង់សម្ដីមានដូចតទៅ៖ “នៅក្នុងឆ្នាំ១៩៧០ នាខែតុលា គណៈកម្មាធិការមជ្ឈិមបក្សបានធ្វើសន្និបាតពេញអង្គជាលើកដំបូង។ សូមជម្រាបថា ពេញអង្គជាលើកដំបូងពីព្រោះមុនរដ្ឋប្រហារ យើងជួបជុំគ្នាមិនពេញអង្គប៉ុន្មានទេ ពីព្រោះសមមិត្តម្នាក់ៗនៅតាមភូមិភាគនីមួយៗជួបគ្នាបាន៨០ភាគរយ ៨១ភាគរយ ឬក៏៩០ភាគរយ មិនដែលបានពេញអង្គទេ ពីព្រោះការទាក់ទងពិបាកណាស់ ខ្លះនៅរំព្លិសាន ខ្លះនៅបូព៌ា ខ្លះនៅនិរតី ខ្លះនៅពាយ័ព្យ ខ្លះនៅឧត្តរ។ ដូច្នេះការទាក់ទងគ្នាមានការលំបាក ដោយសារតែខ្មាំងជា-- ធ្វើសកម្មភាពខ្លាំង។ ប៉ុន្តែដល់ឆ្នាំ១៩៧០ នៅខែតុលា យើងបានជួបគ្នាជាលើកដំបូង ដើម្បីរៀបចំយុទ្ធសាស្ត្រ និងយុទ្ធវិធីវាយចក្រពត្តិអាមេរិក និងពួកបរិវារដែលមានអានល់ ខ្វះខាត។ ពេលនេះ យើងបានសម្រេចវិធានការជាច្រើន ជាប្រវត្តិសាស្ត្រ ដែលខ្ញុំបានជម្រាបពីមុនជាបន្តបន្ទាប់។ ក្នុងមហាសន្និបាតលើកនោះ មជ្ឈិមបក្សកំណត់ថា ឈប់លើបញ្ហាសកម្មភាពខ្មាំងយើង ឈរលើសភាពខ្មាំងរបស់យើង យើងមានប្រៀបជាងខ្មាំងនយោបាយ ហើយកងទ័ពមានប្រៀបជាងខ្មាំងទាំងនោះ។ យើងមានលទ្ធភាពទាំងស្រុងក្នុងរយៈប្រាំមួយ ឬក៏ប្រាំបួនឆ្នាំ យើងក៏បានសម្អាតពីឆ្នាំ១៩៧០ យ៉ាងនេះ”។ ដូច្នេះ ចំណុចនេះគឺខ្ញុំសូមផ្ដល់ឱកាសឲ្យជនជាប់ចោទផ្ដល់អត្ថាធិប្បាយទៅលើអត្ថបទដែលខ្ញុំបានអានអម្បាញ់មិញនេះ។

[១៣:៤៣:៤២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

*(ឮមិនច្បាស់)* សុំឲ្យលោកព្រះរាជអាជ្ញាផ្ដល់ឯកសារជាក់ស្ដែង គឺឯកសារដើមហ្នឹងណា៎ មកឲ្យខ្ញុំមើលមើល៍! លោកមិនផ្ដល់ឯកសារឲ្យខ្ញុំ ហើយឲ្យខ្ញុំឆ្លើយទទួលយ៉ាងម៉េច។ បើជាពិតជាឯកសារខ្ញុំ ខ្ញុំទទួល។

**លោក ឌេល លីសាក់៖**

លោកប្រធាន ចំណុចបន្ទាប់នៅក្នុងឯកសារ ដែលខ្ញុំចង់ដាក់ជូនអង្គជំនុំជម្រះ គឺចេញពី ERN អង់គ្លេស 00491422។ បារាំង គឺ 00504046។ ខ្មែរ ERNគឺ 00063036 ដែលក្នុងនេះរួមមានដំណាក់ស្រង់ដូចតទៅ៖ “នៅពេលដែលយើងកំណត់ផែនការវាយប្រហារនៅពាក់កណ្ដាលឆ្នាំ៧៤ និងរៀបចំឆ្នាំ១៩៧៥ យើងបានបិទទ្វារនៅក្នុងបក្ស ហើយមិនឲ្យខ្មាំងចូលជ្រៀតក្នុងបក្ស”។

ដូចគ្នានេះដែរនៅទំព័រដែលមានលេខ ERN ជាភាសាអង់គ្លេស 00491427។ បារាំងគឺ 00504054។ ខ្មែរគឺ 00063044។ មានការដកស្រង់សម្តីដូចតទៅ ខ្ញុំសូមដកស្រង់៖ "ដូច្នេះយើងបិទទ្វារហើយយើងធ្វើការចាត់វិធានការនៅពាក់កណ្តាលឆ្នាំ៧៤ ក្រៅពីទ័ពយើងមិនអនុញ្ញាតឱ្យអ្នកណាគេចូលរួមនោះទេ ដោយសារតែខ្មាំងកំពុងតែវាយប្រហារយើង មិនត្រឹមតែទ័ពទេ គឺគេវាយទាំងមូលដ្ឋាន ហើយគេព្យាយាមចូលរួមនៅក្នុងបក្សរបស់យើង។ គេចូលរួមនៅគ្រប់ផ្នែកទាំងអស់ដើម្បីវាយប្រហារយើង។

[១៣:៤៦:២៨]

ដូច្នេះហើយចាត់វិធានការទប់ទល់ បិទទ្វារនៅពាក់កណ្តាលឆ្នាំ៧៤មក។ វិធានការនេះតាមបក្សយើងពិនិត្យមានប្រសិទ្ធភាព កាត់ទប់ទល់ខ្មាំងពី៧០ ទៅ៨០ភាគរយ យើងទប់រាល់សកម្មភាពខ្មាំងមិនឱ្យចូលមកផ្ទៃក្នុង យើងបានពី៧០ ទៅ៨០ភាគរយ។ ពីមុនវាចូលតាមចិត្ត ឥឡូវពីពាក់កណ្តាល៧៤មកដែលយើងមានវិធានការយ៉ាងនេះ យើងទប់ទល់បានពី៧០ ទៅ៨០ភាគរយ"។

ដូច្នេះ ខ្ញុំសូមស្នើជាថ្មីម្តងទៀតឱ្យជនជាប់ចោទ ប្រសិនបើចង់នោះ មានបំណងនោះ ធ្វើការអធិប្បាយទៅលើអត្ថបទដែលខ្ញុំទើបតែបានអានអម្បាញ់មិញ។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក នួន ជា!

[១៣:៤៧:២២]

**លោក នួន ជា៖**

សូមឱ្យលោកប្រគល់ឯកសារដើមជាភាសាខ្មែរហ្នឹង មកឱ្យខ្ញុំ មិនមែនឯកសារប្រែពីណាមកទេ។ ខ្ញុំសូមបញ្ជាក់ហើយ បញ្ជាក់ទៀត។ ក្រៅពីនេះនៅតែដដែលៗហ្នឹង នាំតែខាតពេលទេ។ ហើយលោកមិនសុខចិត្តប្រគល់ឯកសារដើមជាភាសាខ្មែរហ្នឹងមកឱ្យខ្ញុំ យកតែឯកសារប្រែពីណាមក អ្នកណាសរសេរ? ខ្ញុំមិនមែនអ្នកសរសេរភាសាអង់គ្លេសទេ។

[១៣:៤៨:១៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

ហើយប្រសិនបើលោកលើកយកដកស្រង់នូវឯកសារ ដែលចេញពីទស្សនាវដ្តីទង់បដិវត្ត ឬក៏

ទស្សនាវដ្ដីយុវជន យុវនារីបដិវត្តមកបង្ហាញជនជាប់ចោទ គឺលោកអាចធ្វើតទៅមុខទៅ ពីព្រោះជំហររបស់ជនជាប់ចោទបានបង្ហាញច្បាស់លាស់ហើយ នូវការទាមទារមើលឯកសារដើម។ អ៊ីចឹងចម្លើយរបស់គាត់ គឺមានតែប៉ុណ្ណឹងទេ តាំងពីដើមរហូតដល់ពេលនេះ។ អ៊ីចឹងគាត់មិនធ្វើអត្ថាធិប្បាយបញ្ហាលើខ្លឹមសារទេ លើកលែងតែឯកសារផ្សេងទៀត ដែលគួរតែត្រូវបានសួរបញ្ជាក់គាត់ ឲ្យគាត់ធ្វើអត្ថា-ធិប្បាយពាក់ព័ន្ធនឹងឯកសារដែលលោកដាក់។

[១៣:៤៩:១០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំមានឯកសារទង់បដិវត្តមួយច្បាប់ទៀត។ ដូច្នេះខ្ញុំមិនសួរជាក់លាក់ឲ្យជនជាប់ចោទធ្វើអត្ថាធិប្បាយនោះទេ។ ឯកសារបន្ទាប់ដែលយើងខ្ញុំចង់ដាក់ជូន គឺឯកសារលេខ D189.2 គឺឯកសារទង់បដិវត្តចុះខែសីហា ឆ្នាំ១៩៧៧ ដែលនៅក្នុងនេះមានសុន្ទរកថា មានចំណងជើងថា "បទឧទ្ទេសនាមរបស់តំណាងអង្គការបក្ស ស្ដីពីមតិណែនាំមួយចំនួនក្នុងការកសាង ពង្រឹង ពង្រីកបក្សដឹកនាំក្នុងឱកាសសន្និបាតកម្មាភិបាលភូមិភាគបស្ចិម ថ្ងៃ២៥ ខែកក្កដា ឆ្នាំ១៩៧៧"។

[១៣:៥០:០៩]

ផ្នែកដែលខ្ញុំចង់បង្ហាញ និងអានជូននោះ គឺអង់គ្លេស គឺលេខ ERN គឺ00399226 រហូតទៅដល់399227។ បារាំង គឺ 00611830។ ខ្មែរគឺ 00062952 ទៅដល់62953។ ចំណុចនេះ គឺជាចំណុចដែលលើកឡើងអំពីប្រវត្តិនៅក្នុងតំបន់មួយ ពាក់ព័ន្ធនៅក្នុងគោលនយោបាយឆ្នាំពាក់កណ្ដាលទសវត្សរ៍៧0 យើងបានពិភាក្សាជាមួយជនជាប់ចោទផងដែរ ដែលថាតើមានអ្វីកើតឡើងនៅក្នុងប្រទេសមួយផ្នែកនោះ?

តំបន់៣៧ មានលក្ខណៈស្មុគស្មាញជាងតំបន់៣២ និង៣១ ដោយសារតែមានសមាសភាពមិនល្អ និងមានប្រវត្តិមិនល្អ។ គង់ កោះកុងបានក្បត់តាំងពីយូរមកហើយ នៅក្នុងឆ្នាំ១៩៧៤ យើងបានដោះស្រាយបញ្ហាហ្នឹង ហើយគ្រប់គ្រងស្ថានភាព។ ចំពោះកំពង់សៀម យើងទើបតែបានដោះស្រាយកាលពីឆ្នាំមុនតែប៉ុណ្ណោះ។ បញ្ហាកោះកុងមានលក្ខណៈស្មុគស្មាញ។ វាមិនមានភាពស្មុគស្មាញនៅក្នុងភូមិភាគទេ ក៏ស្មុគស្មាញនៅក្នុងតំបន់ផងដែរ។ វាស្មុគស្មាញដល់មជ្ឈិមបក្សទៀត។ ស្មុគយ៉ាងម៉េច? ស្មុគមានរឿងច្រើន។ ឧទាហរណ៍ កោះកុង យកប្រជាជនពីកំពង់សិលា នាំវត់ទៅដើម្បីប្រឆាំងនឹងកំពង់សិលា ប៉ុន្តែកោះកុង និងកំពង់សិលា នេះវាត្រូវគ្នា។ មិនមែនអ្នកល្អត្រូវគ្នាទេ គឺអ្នកខូចវាត្រូវគ្នា។ អាចុង, អា

ញ៉ើក, និង អាចាន វាត្រូវគ្នា។ ចេះនិយាយតែបីនាក់ចុះ។ នេះនិយាយតែបីនាក់ចុះ ធ្វើឱ្យភាពស្មុគស្មាញជាប់។ ធ្វើឱ្យមជ្ឈិមស្មុគស្មាញជាប់ ប៉ុន្តែវាមិនមែនតែប៉ុណ្ណឹងទេ រឿងនេះវាម្យ៉ាង។

[១៣:៥២:៣៦]

រឿងមួយទៀត គឺវាចង់យកកោះកុងនេះ គឺកោះកុង និងកំពង់សិលាចាស់រួមគ្នា ដើម្បីចូលដៃជាមួយនឹង កាណុល ជាមួយថៃប្រតិកិរិយា ហើយយកកោះកុងទាំងមូលនេះទៅចូលជាមួយនឹងថៃប្រតិកិរិយា។ បើកាលណាចក្រពត្តិអាមេរិក និង អានល់ ចាញ់បដិវត្តន៍នៅភ្នំពេញ អាមេរិកាំង វាបោះទីតាំងនៅកំពង់សោម ឱ្យអានល់ នៅកន្លែងនោះ ហើយយកកោះកុង ដើម្បីធ្វើជាបង្អែក។ ដូច្នេះ វាដណ្តើមទឹកដីកោះកុងទាំងមូលចេញពីកម្ពុជាទៀត។ រឿងនេះ មិនមែនរឿងតូចទេ ពិនិត្យឡើងវិញឃើញថា ពួកដែលចូលដៃជាមួយនឹងពួកអាក្បត់នៅកោះកុង មានទោសធ្ងន់ណាស់។ ប៉ុន្តែយើងដោះស្រាយសមាសភាព ជាមេរោគនៅកោះកុង បាននៅកំពង់សិលាបាន។ ឥឡូវនេះតំបន់៣៧ ទាំងមូលដែលសរុបទាំង ១១ចាស់ និង៣៧ចាស់ ហៅថា៣៧ថ្មី គឺស្អាតៗជាងមុនច្រើនណាស់។

[១៣:៥៣:៤៧]

បន្តចំណុចមួយទៀត នៅក្នុងទំព័រមួយទៀត។ នៅក្នុងឆ្នាំ១៩៧៤ យើងដោះស្រាយបញ្ហាហ្នឹងទាំងមូល គ្មានបញ្ហាណាមួយនៅសល់ទៀតទេ ដោយសារតែយើងលុបបំបាត់នូវខ្មាំង និងសមាសភាពមិនល្អ ខ្មាំងធំៗទាំងឡាយបានបាត់អស់ហើយ។ កោះកុង យើងអាចដោះស្រាយបាន ហើយយើងអាចដោះស្រាយបញ្ហានៅកំពង់សិលាផងដែរ។

លោកប្រធាន ចំណុចបន្ទាប់ទៀត គឺខ្ញុំមានឯកសារមួយចំនួនដែលខ្ញុំចង់បង្ហាញដាក់ជូនពាក់ព័ន្ធទៅនឹងការជម្លៀសឧដុង្គ នៅឆ្នាំ១៩៧៤។

[១៣:៥៤:៤៧]

ឯកសារមួយគឺ D313/1.2.38 ផ្នែកដែលពាក់ព័ន្ធខ្ញុំចង់យោងនោះ លេខ ERN ជាអង់គ្លេសគឺ 00412834។ ខ្មែរគឺ 00709524។ បារាំងគឺ 00726584។ ឯកសារនេះគឺចុះនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ ១៩៧៤ ដកស្រង់ចេញពីអត្ថបទសារព័ត៌មាន។ នៅក្នុងឯកសារនេះ របាយការណ៍បានយោងថា ហ្គ្រុងបានចាប់យកឧដុង្គនៅពេលដែលទីក្រុងនោះត្រូវបានបំផ្លាញ ហើយក៏មានឃើញយោងទៅលើអត្ថបទចុះថ្ងៃទី៩ ខែកក្កដា ដែលលើកឡើងថា ប្រជាជន៣០.០០០នាក់ នៅឧដុង្គត្រូវបណ្តេញចេញពីកន្លែងនោះ។

ឯកសារមួយទៀត ដែលពាក់ព័ន្ធទៅនឹងឧដុង្គផងដែរ ដែលខ្ញុំចង់បង្ហាញជូនគឺឯកសារ D313/1.2.32។ ផ្នែកដែលពាក់ព័ន្ធ គឺមានលេខ ERN អង់គ្លេស 00412703។ ខ្មែរគឺ 00740837។ បារាំងលេខ ERN គឺ 00771779។ ឯកសារនេះ គឺយោងទៅលើរបាយការណ៍ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៤ ដែលក្នុងនោះយោងទៅលើទូតអាមេរិកាំងនៅក្នុងប្រទេសកម្ពុជា ដែលក្នុងនេះចែងអំពីការបណ្តេញលោក និងកម្ទេចវត្តអារាមនៅឧដុង្គ។ ហើយខ្ញុំសូមអាននៅក្នុងផ្នែកដែលពាក់ព័ន្ធ ដកស្រង់សម្តី កថាខណ្ឌ៤ នៅក្នុងឯកសារនេះគឺ៖

[១៣:៥៧:៥៥]

“សម្តេចសង្ឃមហានិកាយ ដែលជាសម្តេចសង្ឃនិកាយព្រះពុទ្ធសាសនាធំជាងគេបង្អស់ បានបន្តទស្សនសកម្មឈានជនគាំទ្ររដ្ឋាភិបាលបន្តិចម្តងៗ តាមរយៈការផ្សាយលិខិតចំហមួយទៅមេដឹកនាំខ្មែរក្រហម និងមេដឹកនាំខ្មែររំដោះ ដោយអំពាវនាវឲ្យមានការផ្សះផ្សារកសន្តិភាព។ កម្មវត្ថុរបស់ព្រះអង្គគឺផ្តោតលើខ្មែរកុម្មុយនីស្ត ដែលបានកម្ទេចឧដុង្គ ដែលមានវត្តជាច្រើន និងសម្បត្តិវប្បធម៌ជាច្រើនទៀត ព្រមទាំងចង្អុលបង្ហាញថា ពួកគេកំពុងបម្រើគោលបំណងរបស់ពួកប្រល័យពូជសាសន៍ ពួកវាតទីនិយមវៀតណាមខាងជើង ដោយការបន្តកាប់សម្លាប់អ្នកស្រុកជាជនស្លូតត្រង់គ្មានកំហុស។ ព្រះអង្គបានអំពាវនាវឲ្យខ្មែរកុម្មុយនីស្តបង្ហាញពីមេត្តាករុណា ដោយអនុញ្ញាតឲ្យអ្នកភូមិវិលត្រឡប់ទៅស្រុកកំណើតវិញ និងអនុញ្ញាតឲ្យព្រះសង្ឃ និងអ្នកស្រុកវិលត្រឡប់ទៅឧដុង្គវិញ។ លោកបានទទូចសុំឲ្យមេដឹកនាំខ្មែរក្រហម និងមេដឹកនាំខ្មែររំដោះ បោសសម្អាតវៀតកុង វៀតណាមខាងជើងចេញពីប្រទេសកម្ពុជា និងត្រឡប់ទៅសហគមន៍ជាតិ ដើម្បីជួយកសាងសន្តិភាព និងសាធារណរដ្ឋរុងរឿង”។

ដោយសារឯកសារនេះ មិនមែនជាឯកសារទង់បដិវត្ត ដូច្នេះហើយខ្ញុំសូមអនុញ្ញាតផ្តល់ឱកាសឲ្យជនជាប់ចោទ ធ្វើអត្ថាធិប្បាយទៅលើឯកសារ ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជននៅឧដុង្គ ប្រសិនបើលោកជនជាប់ចោទមានបំណងចង់ធ្វើដូច្នោះ។

[១៣:៥៩:៣៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ចង់យកឯកសារហ្នឹងមកពិនិត្យសិន។

[១៤:00:00]

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងរីករាយផ្តល់ជូនឯកសារនេះជាភាសាខ្មែរបាន នៅពេលនេះ ខ្ញុំមានតែភាសាអង់គ្លេសតែប៉ុណ្ណោះ។ យើងខ្ញុំនឹងព្យាយាមយកឯកសារខ្មែរផ្តល់ជូនទៅមេធាវីការពារក្តី ហើយបន្ទាប់មកយើងនឹងស្នើសុំឱ្យជនជាប់ចោទនោះផ្តល់នូវអត្ថាធិប្បាយ បើសិនជាគាត់មាន និងមានបំណងធ្វើដូច្នោះ ដូច្នេះ យើងខ្ញុំនឹងរៀបចំឯកសារជាភាសាខ្មែរជូនជនជាប់ចោទ។

[១៤:00:៣៥]

ឯកសារបន្ទាប់ទៀតដែលខ្ញុំចង់បង្ហាញដាក់ជូននោះ លោកប្រធាន គឺឯកសារ IS20.30 ឯកសារនេះមានចំណងជើងថា "សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ជូនចំពោះបក្សកុម្មុយនីស្តដាណឺម៉ាក ចុះខែកក្កដា ឆ្នាំ១៩៧៨" គឺជារបាយការណ៍ស្តីអំពីសុន្ទរកថាដែលថ្លែងដោយ នួន ជា។ ទំព័រដែលពាក់ព័ន្ធដែលខ្ញុំយោង អានចំពោះចំណុចឯកសារនេះគឺ ERN ជាភាសាអង់គ្លេសគឺ 00762402។ បារាំងគឺ 00280675។ ខ្មែរគឺ 00224474។ នៅក្នុងសុន្ទរកថាដែល នួន ជា ថ្លែងជូនគណៈបក្សកុម្មុយនីស្តដាណឺម៉ាក រួមមានការថ្លែងការណ៍ដូចតទៅ៖ "គេដឹងយ៉ាងសុះសាយថា សហរដ្ឋអាមេរិកមានផែន-- ក្តាប់អំណាចពីយើង ប្រាំមួយខែបន្ទាប់ពីការរំដោះ" ផែនការនោះគឺជាសកម្មភាពរួមគ្នារបស់សហរដ្ឋអាមេរិក កា.ហ្សេ.បេ និងវៀតណាម។

[១៤:0២:១៣]

ត្រូវតែមានការតស៊ូរួមគ្នាពីខាងក្នុងនិងខាងក្រៅ ប៉ុន្តែយើងបានកម្ទេចផែនការនោះ។ ភ្លាមៗបន្ទាប់ពីការរំដោះ យើងបានជម្លៀសប្រជាជនពីទីក្រុង ភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារកា.ហ្សេ.បេ និងភ្នាក់ងារវៀតណាមបានចេញទៅកាន់ទីជនបទ ហើយពួកវាមិនអាចអនុវត្តផែនការបានឡើយ"។ បញ្ចប់ការដកស្រង់សម្តី។

ដូច្នេះជាថ្មីម្តងទៀត គឺខ្ញុំសូមផ្តល់ឱកាសជូនដល់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទមានបំណងឆ្លើយតបទៅលើឯកសារមួយនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា!

[១៤:0២:៥0]

**លោក នួន ជា៖**

សូមឯកសារទាំងអស់មកពិនិត្យសិន។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំនឹងសូមដាក់ឯកសារនេះ ហើយយើងសូមបញ្ជូនឯកសារជាក្រដាសជូនលោក នួន ជា មើលបាន។

**ប្រធានអង្គជំនុំ៖**

អង្គុយៗ ចុះសិន!

**លោក នួន ជា៖**

ស្ដាប់មកយល់ទេ ទាល់តែយកមកពិនិត្យ ពិចារណាឲ្យច្បាស់លាស់សិន។ លោកគ្រាន់តែអានៗហើយមកឲ្យខ្ញុំឆ្លើយយ៉ាងម៉េច?

[១៤:០៣:៥១]

**ប្រធានអង្គជំនុំ៖**

លោក នួន ជា អង្គជំនុំជម្រះនឹងពិនិត្យពិចារណាដោះស្រាយបញ្ហានេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៦:០៤]

**ប្រធានអង្គជំនុំ៖**

លោក នួន ជា តាមពិតឯកសារទាំងអស់នេះ គឺមាននៅក្នុងសំណុំរឿងរួចហើយ ហើយខ្ញុំគិតថាមេធាវីរបស់-- ក្រុមមេធាវីលោក នួន ជា គឺអាចរៀបចំនូវឯកសារទាំងអស់នេះ ពីព្រោះឯកសារហ្នឹងខាងសហព្រះរាជអាជ្ញា បានកំណត់អត្តសញ្ញាណឯកសារច្បាស់លាស់ហើយ។ ហើយអង្គជំនុំជម្រះក៏បានរីករាយផងដែរ ចំពោះសមានចិត្តរបស់ខាងភាគីសហព្រះរាជអាជ្ញា ដែលបានខិតខំប្រឹងប្រែងក្នុងការសន្យា ថានឹងផ្ដល់ជាជំនួយក្នុងការរៀបចំឯកសារជាក្រដាស ហើយឲ្យជូនដល់លោក នួន ជា នោះ។ ប៉ុន្តែអង្គជំនុំជម្រះយល់ថា កិច្ចការនេះវាគួរតែជាភារកិច្ចរបស់ក្រុមមេធាវីការពារក្ដី នួន ជា ឬក៏ក្រុមជំនួយការរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីរៀបចំបញ្ហានេះ។

បញ្ហាទីពីរ គឺសូមជម្រាបលោក នួន ជា ថាតាមដែលទំហំ និងខ្លឹមសារនៃឯកសារភស្តុតាងដែលដាក់របៀបនេះ លោកមិនអាចពិនិត្យមើលភ្លាមៗឥឡូវហ្នឹង ហើយឆ្លើយតបភ្លាមបានទេ។ ដូច្នេះ

ឯកសារនេះ សូមភាគីតំណាងសហព្រះរាជអាជ្ញាដែលមានសមានចិត្តនេះ គឺរៀបចំនូវឯកសារដែលបានដាក់ជូនរួចហើយនេះ គឺជាក្រដាសជូនទៅលោក នួន ជា ដើម្បីលោកមានឱកាសនៅក្នុងការសិក្សាពិនិត្យ ហើយគាត់-- អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាមួយសមស្រប នៅក្នុងសប្តាហ៍ក្រោយ ដើម្បីឲ្យគាត់មានឱកាស ក្នុងការឆ្លើយតបទៅលើខ្លឹមសារ នៃឯកសារដែលលោកតំណាងសហព្រះរាជអាជ្ញា បានដាក់អម្បាញ់មិញនេះ។ ហើយជាការគួរគប្បីខាងមេធាវីរបស់ខ្លួន ក្នុងការរៀបចំឯកសារទៅតាមលំដាប់លេខឯកសារដែលបានដាក់ដោយសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ដើម្បីឲ្យគាត់មានលទ្ធភាពពិនិត្យឯកសារនោះបាន។

អ៊ីចឹងអញ្ជើញបន្តទៀត ដើម្បីបន្តការដាក់ឯកសារតទៅទៀត ហើយគប្បីមិនចាំបាច់ឲ្យគាត់ផ្តល់នូវមតិយោបល់លើឯកសារដែលលោកដាក់ទៀតទេ។ សូមដាក់បង្ហាញនូវឯកសារតាមមធ្យោបាយដែលលោកប្រើក្នុងអំឡុងពេលនេះរហូតដល់ចប់ទៅ ហើយលទ្ធភាពនៃការជួយមានសមានចិត្តជួយហ្នឹង ក៏ប្រឹងប្រែងជួយទៅបើសិនជាអាចជួយបាន ក្នុងការផ្តល់ឯកសារជាក្រដាសជូនដល់គាត់នោះ។

សូមអញ្ជើញ!

[១៤:០៨:៤៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ឯកសារមួយចំនួនចុងក្រោយដែលខ្ញុំចង់បង្ហាញនៅរសៀលនេះ គឺទាក់ទងទៅនឹងសក្ខីកម្ម ឬចម្លើយរបស់ជនជាប់ចោទ ដែលបានរៀបរាប់អំពីបញ្ហាបក្សមុនឆ្នាំ១៩៧៥ និងការវិភាគសង្គមកម្ពុជាមុនឆ្នាំ១៩៧៥។ ខ្ញុំគិតថា បើភាគីមិនបានមានការរកឃើញការជំទាស់អ្វី និងគោលបំណង ក៏ដូចជាមនោគមន៍វិជ្ជា ហើយនិងក៏រួម ទាំងព្រះមហាក្សត្រផងដែរ ហើយនៅក្នុងនោះ គឺគាត់បានលើកថាសមមិត្តមានការវាយប្រហារទៅដល់សម្តេច គឺជាការយល់ខុសទៅលើមាគ៌ារបស់បក្សហើយ។ ខ្ញុំចង់បង្ហាញនូវឯកសាររបស់បក្សមួយចំនួន ដែលបង្ហាញអំពីជំហរពិតប្រាកដរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះសម្តេច ក៏ដូចជាព្រះរាជវង្សានុវង្សផងដែរ។

[១៤:០៩:៥៣]

ឯកសារនេះគឺ IS13.9 គឺកំណត់ហេតុរបស់គណៈ-- កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបានប្រារព្ធធ្វើនៅថ្ងៃទី១១ មីនា ១៩៧៦ ដែលពិភាក្សាថាតើគួរទទួលយកការលាលែងពីតំណែងរបស់សម្តេច

នរោត្តម សីហនុ ដែរឬក៏អត់? ហើយកិច្ចប្រជុំនេះ គឺចូលរួមមានវត្តមាន នួន ជា នៅក្នុងនេះ គឺមាន សមមិត្តលេខា វត្តមាន មានវត្តមាន ខៀវ សំផន ដែលហៅរហស្សនាមគាត់ឈ្មោះ ហែម។ ហើយនៅក្នុងផ្នែកទីមួយ ខ្ញុំសូមបង្ហាញជូនអង្គជំនុំជម្រះ ដែលមកពីអង់គ្លេស ERN 00182638។ ERN ជាភាសាបារាំង 00334961។ ERN ជាភាសាខ្មែរ 0000745។ នៅក្នុងការពិភាក្សាអំពីគំនិតយោបល់របស់អង្គការទាក់ទងទៅនឹងហេតុផលវែងឆ្ងាយ ចំពោះការលាឈប់ពីមុខតំណែងរបស់សម្តេច នរោត្តម សីហនុ គឺមានលើកឡើងដូចខាងក្រោម។ សូមដកស្រង់សម្ដី៖ “មូលហេតុដែលនាំឲ្យ សីហនុ លាលែងឈប់ មានពីរយ៉ាង គឺមូលហេតុវែងឆ្ងាយ និងនៅចំពោះ។ មូលហេតុវែងឆ្ងាយ គឺទំទាស់វណ្ណៈជាមូលដ្ឋានរវាងបដិវត្តន៍ និងគាត់ ព្រមទាំងគ្រួសារគាត់។ គាត់រស់នៅជាមួយយើងមិនបានទេ កន្លងមកគាត់រស់នៅបានជាយុទ្ធវិធីទេ។ ដោយយើងដំណើរការជាយុទ្ធវិធីទូទៅ គាត់ចេះតែនៅបានជាបណ្ដើរៗ សីហនុ មិនមែនលាឈប់តែម្ដងនេះទេ គាត់លាឈប់តាំងពីឆ្នាំ១៩៧១ មកម្ល៉េះ”។

[១៤:១២:០៥]

ហើយចុងបញ្ចប់នៃឯកសារនោះ គឺERN 00182641 ជាភាសាបារាំង 00334963 ហើយជាភាសាខ្មែរ 0000748 ដែលមានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម។ សូមដកស្រង់សម្ដី៖ “យើងត្រូវតែបញ្ចប់ពួកចក្រពត្តិ-- ដូចតទៅនេះ ពួកមូលធននិយម។ ហើយរបបមូលធននិយមគឺត្រូវបានកម្ចាត់ទាំងស្រុង ហើយព្រះមហាក្សត្រនេះ គឺថាមាន ដែលមានអាយុកាលជាង២.០០០ឆ្នាំនេះគឺត្រូវតែបញ្ចប់ យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ”។ សូមបញ្ចប់សម្ដី។

លោកប្រធាន ខ្ញុំសូមឲ្យសហការីជាតិរបស់ខ្ញុំ។ សូមឲ្យអានពី-- ជាភាសាខ្មែរនៅក្នុងផ្នែកនេះ។ ខ្ញុំមិនដឹងថា តើមានការបកប្រែត្រឹមត្រូវ ឬក៏យ៉ាងនោះនោះទេ? ហេតុដូច្នេះឯង សុំឲ្យសហការីសហព្រះរាជអាជ្ញារងជាតិ គាត់អានជាភាសាខ្មែរតែម្ដង។

[១៤:១៣:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញសហព្រះរាជអាជ្ញារងជាតិ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមដកស្រង់សម្ដីដូចតទៅ៖ “គឺត្រូវតែបញ្ចប់សក្តិភូមិយ៉ាងដូច្នេះឯង ក្រឡាអុកវាចេញមកដល់ត្រង់ហ្នឹងហើយ។ របបសក្តិភូមិទាំងមូល ត្រូវបដិវត្តន៍កម្ទេច និង

គាស់រំលើងជាស្ថាពរ។ ស្តេចដែលមានមក២.០០០ឆ្នាំហើយ ទីចុងបំផុតត្រូវស្អាត យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ”។ បាទសូមអរគុណ។

[១៤:១៤:០៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញបន្តបាទ!

**លោក ឌេល លីសាក់៖**

លោកប្រធាន ឯកសារចុងក្រោយដែលខ្ញុំចង់បង្ហាញនៅថ្ងៃនេះ គឺIS6.2 ហើយឯកសារយោងនោះ គឺពីទំព័រជាភាសាអង់គ្លេស ERN 00244275។ ERN ជាភាសាបារាំង 00611568 ហើយខ្មែរ 00072403។ នេះគឺឯកសារចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ដែលនិយាយអំពីការអនុវត្តអំពីមាគ៌ានយោបាយបក្ស ក្នុងការប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស។ ហើយមានផ្នែកពាក់ព័ន្ធទៅនឹងគោលនយោបាយ ដែលនិយាយអំពីការទំនាស់គ្នានៅក្នុងបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងក្រុមគ្រួសារព្រះរាជវង្សានុវង្ស។ ហើយនៅក្នុងឯកសារមួយនេះ ខ្ញុំក៏សូមឲ្យសហព្រះរាជអាជ្ញាជាតិសូមអានចេញពីភាសាខ្មែរផ្ទាល់តែម្តង ដោយសារការបកប្រែជាភាសាអង់គ្លេសនេះហាក់ដូចជាពិបាកបន្តិច។ ដូច្នេះសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យគាត់អាន សហការីខ្ញុំអានជាភាសាខ្មែរតែម្តង។

[១៤:១៦:០៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាជាតិ!

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដកស្រង់សម្តី៖ “សីហនុ ក៏យើងក្តាប់បាន ដោយគាត់គ្មានអ្វីទាំងអស់ ទាំងសេដ្ឋកិច្ច ទាំងអំណាច។ ដូច្នេះ ត្រូវរណបយើងទាំងស្រុងទាំងសម្ភារៈ ទាំងនយោបាយ។ បើប្រៀបធៀបគាត់នៅមានឥទ្ធិពលជាងអ្នកដទៃទៀត។ ពីមុនយើងប៉ានថា បើចេញពីយើងគាត់ត្រូវស្លាប់ ដល់ឥឡូវយើងក្តាប់គាត់បានច្រើនជាងមុន ដោយយើងឈ្នះខ្លាំង។ យើងមានអ្វីៗទាំងអស់ អ្វីក៏នៅលើយើង រហូតដល់វាំង ក៏ជាវាំងយើង ក៏ប៉ុន្តែយើងដំណើរការជាមួយគាត់បានស្រួល។ បច្ចុប្បន្នគាត់ឃើញថា គាត់នៅជាមួយយើងបាន បើបានប៉ុណ្ណឹងគាត់ពេញចិត្តហើយ ឲ្យតែបាននៅក្នុងប្រទេសខ្លះទៅក្រៅប្រទេសខ្លះ។ នេះជាសភាពការណ៍ ដែលពន្យារពេលឲ្យយើងពង្រឹង និងពង្រីកកម្លាំងយើងបាន

បើថ្ងៃក្រោយគាត់ប្រែប្រួល យើងប្រដូចគាត់បានទៅនឹងការក្រមរ គឺជ្រុះឯង គ្មាននរណាធ្វើអីទេ ដោយគ្មានការឈឺចាប់ មិនមែនបួស ឬដំបៅទេ”។ បាទ សូមអរគុណ។ សូមបញ្ចប់ការដកស្រង់បាទ។

[១៤:១៧:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញបន្ត!

**លោក ឌេល លីសាក់៖**

ខ្ញុំដឹងថា យើងមិនអាចផ្តល់ឯកសារដើមចំពោះឯកសារនេះបានទេ។ មុននឹងខ្ញុំបញ្ចប់ការបង្ហាញ ខ្ញុំសូមផ្តល់ឱកាសជូនជនជាប់ចោទសាជាថ្មីម្តងទៀត ថាតើមានការផ្តល់មតិយ៉ាងម៉េចទៅលើចំណុចនេះ? ដោយសារថា វាមានការមិនចុះសម្រុងគ្នា ជំទាស់គ្នា គឺរវាងបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងព្រះរាជវង្សានុវង្សនោះ ហើយនិងក៏ដូចជាជាមួយនឹងវណ្ណៈអភិជននោះ។

[១៤:១៨:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា តើមានចង់--

បាទ សូមអញ្ជើញ!

**លោក នួន ជា៖**

មិនទាន់ឆ្លើយតបអីបានទេ ទាល់តែបានឯកសារមកសិន ឲ្យខ្ញុំឃើញជាក់ស្តែងសិន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តការងាររបស់លោកតទៅទៀត!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឯកសារដែលបង្ហាញអម្បាញ់មិញនេះ គឺជាឯកសារទាំងអស់ដែលខ្ញុំបានបង្ហាញជូនសម្រាប់ថ្ងៃនេះ។ យើងខ្ញុំនឹងចូលទៅឯកសារជាក់លាក់ គឺនៅថ្ងៃចន្ទ និងថ្ងៃអង្គារ ឯណោះ។ សហការីរបស់ខ្ញុំ គាត់មានឯកសារមួយក៏សូមចង់បង្ហាញនៅក្នុងពេលនេះដែរ។

ដូច្នេះ ខ្ញុំសូមផ្តល់ឱកាសនេះជូនទៅសហការីរបស់ខ្ញុំ សហព្រះរាជអាជ្ញារងជាតិ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាជាតិ!

**លោក ច័ន្ទ តារាស្មី៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំតំណាងសហព្រះរាជអាជ្ញាជាតិ សូមអនុញ្ញាតលើកឡើងនូវការកត់សម្គាល់ ក៏ដូចជាការយល់ឃើញមួយចំនួនទាក់ទិនទៅនឹងក្រុមមេធាវីការពារក្តីលោក អៀង សារី ដែលបានលើកឡើងទាក់ទិននឹងឯកសារ។ ប្រសិនបើលោកប្រធានអនុញ្ញាតចំពោះសវនាការលើឯកសារនៅសប្តាហ៍ក្រោយ សហព្រះរាជអាជ្ញាស្នើថា នឹងដាក់ចំពោះមុខអង្គជំនុំជម្រះនូវអង្គហេតុព្រមព្រៀង ដែលទាក់ទិននឹងផ្នែកនៃប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់ជនជាប់ចោទ អៀង សារី នៅមុនឆ្នាំ១៩៧៥ ក្នុងបក្សកុម្មុយនីស្តកម្ពុជាកន្លងមក។ ប៉ុន្តែបើសិនជាលោកប្រធានអនុញ្ញាតនៅពេលនេះ ខ្ញុំសូមអានអង្គហេតុព្រមព្រៀងនៅថ្ងៃនេះតែម្តង ដោយសារតែខ្ញុំចំណាយពេលប្រហែលជា៤០នាទី ឬក៏៤៥នាទីប៉ុណ្ណោះ។ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមអាននូវអង្គហេតុព្រមព្រៀងនៅពេលនេះ ដើម្បីជូនអង្គសវនាការជ្រាប បាទ។

[១៤:២០:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណ ប៉ុន្តែអង្គជំនុំជម្រះសួរទៅខាងក្រុមមេធាវីការពារក្តីលោក អៀង សារី ថាតើមានការព្រមព្រៀងអង្គហេតុរវាងសហព្រះរាជអាជ្ញា ជាមួយនឹងក្រុមមេធាវីការពារក្តីលោក អៀង សារី អំពីក្របខ័ណ្ឌដែលគាត់បានលើកឡើងអម្បាញ់មិញនេះដែរទេ?

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីទាំងអស់គ្នា។ អង្គហេតុព្រមព្រៀងដែលយើងខ្ញុំបានដាក់នោះ គឺតាមការដែលខ្ញុំចាំ ខ្ញុំគិតថាអានប្រហែលជាប្រាំនាទីទេ ហេតុអ្វីបានជាសហព្រះរាជអាជ្ញាជាតិថា អានរហូតទៅដល់៤៥នាទីឯណោះ។ ខ្ញុំគិតគ្រាន់ថា តំណាងសហព្រះរាជអាជ្ញាជាតិហ្នឹង គឺថាបានដឹងហើយអំពីអង្គហេតុព្រមព្រៀងនោះ។ សូមអរគុណច្រើន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២២:០០]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ តំណាងសហព្រះរាជអាជ្ញាជាតិ ហើយការចំណាយពេលវេលាក្នុងការអាន ហេតុអ្វីក៏គណនាពេលវេលាហ្នឹងឃើញខុសគ្នាឆ្ងាយយ៉ាងនេះ? វាយ៉ាងម៉េចទៅ?

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន តាមពិតទៅ បើសិនជាលោកប្រធានអនុញ្ញាតក្នុងការអានប្រើពេលលើស បន្តិចហ្នឹង គឺដោយសារតែយោងទៅលើឯកសារ អាន ERN អានឯកសារយោងមួយចំនួន តែបើសិនជា មិនចំបាច់ លោកប្រធានយល់ថាមិនចាំបាច់ទេ ខ្ញុំសូមអនុញ្ញាតតែអានតែខ្លឹមសារដែលមានការព្រម ព្រៀងតែប៉ុណ្ណោះ។ ហើយខ្ញុំចំណាយពេលប្រហែល២០នាទី ទេ ហើយការអានយឺតបន្តិចដើម្បីឲ្យងាយ ស្រួលដល់ខាងអ្នកបកប្រែ ឲ្យបកប្រែឲ្យបានច្បាស់លាស់។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យអាននូវខ្លឹមសារនៃការព្រមព្រៀង។ បាទ សូមអញ្ជើញ!

[១៤:២២:៤៥]

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតអាន។ លោកប្រធាន ប្រហែលជាឆ្នាំហើយ ដោយសារ តែយោងលើវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីនានា ជូនដំណឹងអំពីអង្គហេតុទាំងឡាយដែល បានព្រមព្រៀងគ្នាក្នុងគោលបំណងដើម្បីឲ្យសវនាការផ្តោតចំពោះតែចំណុចសំខាន់ៗនៃទំនាស់។ ហេតុ ដូច្នេះហើយ សហព្រះរាជអាជ្ញា បានស្វះស្វែងនូវការព្រមព្រៀងគ្នាលើអង្គហេតុជាលាយលក្ខណ៍អក្សរ ពីសំណាក់ជនជាប់ចោទទាំងបីរូប តាមរយៈក្រុមមេធាវីការពាររបស់ពួកគាត់ថា អង្គហេតុណាខ្លះដែល ពួកគាត់គ្មានបំណងជំទាស់តវ៉ា។

ដូចអស់លោក លោកស្រីចៅក្រមជ្រាបហើយថា សហព្រះរាជអាជ្ញា បានដាក់ឯកសារជូនអង្គ ជំនុំជម្រះកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ដែលមានលេខឯកសារ E9/21។ ជនជាប់ចោទ នួន ជា និងខៀវ សំផន មិនបានព្រមព្រៀងលើអង្គហេតុណាមួយទេ ក្នុងដីកាដំណោះស្រាយកន្លងមក។ ទោះជា យ៉ាងណា ជនជាប់ចោទ អៀង សារី បានផ្តល់នូវអង្គហេតុព្រមព្រៀងចំនួនពីរ ដែលទាក់ទងទៅលើ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងសកម្មភាពរបស់គាត់នៅមុនឆ្នាំ១៩៧៥ ដែលមាននៅក្នុងដីកាដំណោះ ស្រាយកន្លងមក។

[១៤:២៤:១៣]

អង្គហេតុព្រមព្រៀង ដែលមានកម្រិតទាំងនោះ បានដាក់ជូនតុលាការក្នុងឯកសារដែលមាន លេខយោង E9/21.3 រួចហើយ។

លោកប្រធានជាទីគោរព ដោយមានការអនុញ្ញាត ខ្ញុំសូមអាននូវការព្រមព្រៀង អង្គហេតុដែលបានព្រមព្រៀងនេះ ដែលអង្គហេតុទាំងនោះ មេធាវីការពារក្តីលោក អៀង សារី គឺការអានរបស់ខ្ញុំនៅពេលនេះ គោលដៅសំខាន់គឺសម្រាប់ជាប្រតិចារឹក ដោយចាប់ផ្តើមពីលេខកថាខណ្ឌដែលមាននៅក្នុងដីកាដំណោះស្រាយ ហើយបន្ទាប់មកនឹងអាននូវកថាខណ្ឌជាក់លាក់មួយម្តងៗ។ ហើយខ្ញុំបាទ សូមបញ្ជាក់ផងដែរថា ដោយសារតែមានសំណើពីសហព្រះរាជអាជ្ញា មេធាវីការពារក្តីលោក អៀង សារី ក៏បាន *ហាយឡាយ* ៗលើអង្គហេតុដែលបានព្រមព្រៀងគ្នាទាំងនោះនៅក្នុងដីកាដំណោះស្រាយដោយដាក់ពណ៌បៃតង។ ជាធម្មតាមានតែផ្នែកខ្លះនៃកថាខណ្ឌដែលបានព្រមព្រៀង និងមានកន្លែងមួយចំនួនក្នុងឃ្លាខ្លះ ក្នុងកថាខណ្ឌខ្លះតែប៉ុណ្ណោះ ដែលខ្ញុំនឹងអានជូនបន្តិចទៀតនេះបាទ។

ជាបន្ថែម គឺមានអង្គហេតុមួយចំនួនបានព្រមព្រៀង តែមានជាយោបល់កែប្រែខ្លះដែលបានធ្វើឡើងដោយជនជាប់ចោទ អៀង សារី បញ្ជាក់មក ហើយខ្ញុំនឹងអានជូននៅពេលបន្តិចទៀត។

ហេតុដូច្នេះ គឺសូមអនុញ្ញាតពីលោកប្រធាន ហើយខ្ញុំធ្វើការអាន ដែលមានខ្លឹមសារដូចទៅនេះ៖

[១៤:២៥:៤៣]

ចំពោះកថាខណ្ឌទី១៨ លោកប្រធានជាទីគោរព។ កថាខណ្ឌទី១៨ បានព្រមព្រៀងគ្នាទៅលើអត្ថិភាពរបបបក្សកុម្មុយនីស្តកម្ពុជា ប.ក.ក ត្រូវបានប្រកាសជាផ្លូវការនាខែកញ្ញា ឆ្នាំ១៩៧៧។ នេះគឺជាអង្គហេតុដែលបានព្រមព្រៀងគ្នាក្នុងកថាខណ្ឌទី១៨។

ចំពោះកថាខណ្ឌទី២០ បានព្រមព្រៀងគ្នាទៅលើចំណុចមហាសមាជនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដែលពេលនោះ ប.ជ.ប.ខ ត្រូវប្តូរឈ្មោះទៅជា បក្សពលករខ្មែរ ដែលសរសេរអក្សរកាត់ ប.ព.ខ គឺជាចំណុចចាប់ផ្តើមពិតប្រាកដនៃការបង្កើតចលនាកុម្មុយនីស្តខ្មែរ។ ខ្ញុំសូមបញ្ជាក់ជូនលោកប្រធានជ្រាបថា ចំណុចនេះ កថាខណ្ឌទី២០ គឺខាងលោកមេធាវីការពារក្តីលោក អៀង សារី បានស្នើបានជូនជាយោបល់ បានលើកជាយោបល់ថា សូមឲ្យមានការកែប្រែដូចតទៅនេះ។ ហើយចំណុចដែលគាត់មានជាយោបល់នេះ គឺមានដូចតទៅ៖

ខ្ញុំសូមអាន "ក្នុងដីកាដំណោះស្រាយជាភាសាខ្មែរ គឺថ្ងៃខែពិតប្រាកដសម្រាប់មហាសមាជនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០"។ បាទ នេះគឺគាត់បានបញ្ជាក់អ៊ីចឹងមកខាងខ្ញុំបាទ។

[១៤:២៧:៣០]

ចំពោះកថាខណ្ឌទី២២ ខ្ញុំសូមអាននូវអង្គហេតុដែលបានព្រមព្រៀងគ្នា "បន្ទាប់ពីការបាត់ខ្លួន

លេខាបក្សពលករកម្ពុជាឈ្មោះ ទូ សាមុត នៅឆ្នាំ១៩៦២ (មិនដែលមានការបំភ្លឺច្បាប់លាស់អំពីរឿងនេះទេ) សមាជលើកទីពីររបស់បក្សត្រូវបានធ្វើឡើងនៅចុងខែកុម្ភៈ ឆ្នាំ១៩៦៣ ដែលពេលនោះ សាឡុត ស បានក្លាយខ្លួនជាលេខាបក្សថ្មី ចំណែក នួន ជា នៅបន្តធ្វើជាអនុលេខាបក្សដដែល។ សមាជនេះត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ដោយមានកម្រិតចំនួនអ្នកចូលរួមត្រឹមមនុស្សសំខាន់ៗដូចជា អៀង សារី និង សោ ភឹម។ អ្នកទាំងពីរត្រូវបានបោះឆ្នោតជ្រើសរើស ជ្រើសតាំង បោះឆ្នោតជ្រើសតាំងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ រីឯតាម៉ុក, វន វ៉េត, រស់ ញឹម គឺជាមនុស្សសំខាន់ផ្សេងទៀតនៅក្នុងពេលនោះ។ ប៉ុន្តែខែក្រោយមក បន្ទាប់ពីរដ្ឋាភិបាលបានចេញផ្សាយនូវបញ្ជីឈ្មោះមនុស្សដែលគេស្គាល់ថា ជាអ្នកឆ្វេងនិយម ចំនួន៣៤រូប ប៉ុល ពត និងមេដឹកនាំបក្សពលករកម្ពុជាមួយចំនួន ដែលមានឈ្មោះក្នុងបញ្ជីនោះ រួមទាំង អៀង សារី និង សុន សេន ក៏បានភៀសខ្លួនពីទីក្រុង។ អ្នកទាំងនោះបានទៅជ្រកកោននៅឯបន្ទាយវៀតណាមមួយ នៅតាមបណ្តោយព្រំដែន ដែលនៅទីនោះ ពួកគេបានបង្កើតមន្ទីរមួយឈ្មោះថា មន្ទីរ១០០។ មកដល់ឆ្នាំ ១៩៦៥ ប្រពន្ធរបស់អ្នកទាំងនោះ ដូចជា ខៀវ ប៉ុណ្ណារី, អៀង ធីរិទ្ធ, និង យុន យ៉ាត បានចូលរួមជាមួយពួកគេនៅមន្ទីរ១០០នោះ។

[១៤:២៩:៤៣]

ដោយសារអត្តសញ្ញាណរបស់ នួន ជា មិនត្រូវបានគេស្គាល់ ហើយឈ្មោះរបស់គាត់ពុំស្ថិតនៅក្នុង។ ពេលនោះគឺមេធាវីការពារក្តី បានលើកស្នើថា នៅក្នុងកថាខណ្ឌ២២ គាត់បានឲ្យជាយោបល់ថា សុំកែប្រែនូវពាក្យ "នៅបន្ត" នៅបន្ទាត់ទី៣ ចុងបន្ទាត់ទី៣ នៃកថាខណ្ឌ២២ គាត់ស្នើជាយោបល់ថា សុំឲ្យកែទៅជា "បានក្លាយជា" បានន័យថា ចំណែក នួន ជា នៅបន្តធ្វើជាអនុលេខាបក្សដដែលនោះ គឺខាងលោកមេធាវីការពារក្តីបានស្នើថា "បានក្លាយជា"។ នួន ជា បានក្លាយជាអនុលេខាបក្សដដែល។

ខ្ញុំសូមអនុញ្ញាតបន្តទៅកថាខណ្ឌទី២៣។ កថាខណ្ឌទី២៣ គឺជាកថាខណ្ឌដែលមានការព្រមព្រៀង ខ្ញុំសូមអានចំណុចដែលមានការព្រមព្រៀង "នៅអំឡុងឆ្នាំ១៩៦៧ មេដឹកនាំមួយចំនួនរបស់បក្សបានឯកភាពការបះបោរប្រដាប់អាវុធមួយនៅឆ្នាំ១៩៦៨។ ទីស្នាក់ការគណៈមជ្ឈិមឈ្មោះ "មន្ទីរ១០០" ត្រូវបានបង្កើតឡើងក្នុងខេត្តរតនគិរី"។ ចំណុចនេះខាងមេធាវីការពារក្តីក៏ស្នើថាគួរប្តូរមកជា"ប្តូរទីតាំង" ត្រូវបានបង្កើតឡើង គាត់ស្នើផ្តល់យោបល់ថាឲ្យប្តូរមកជា "ប្តូរទីតាំង" វិញ ក្នុងខេត្តរតនគិរី ចម្ងាយប្រហែលប៉ុន្មានគីឡូម៉ែត្រពីមន្ទីរ១០២ ដែលជាមន្ទីរភូមិភាគឦសាន ដែលត្រូវបានប្រើប្រាស់ដោយ អៀង សារី ដែលគាត់ត្រូវបានតែងតាំងជាលេខាភូមិភាគ កាលសម័យនោះ។

[១៤:៣១:៤១]

ខ្ញុំសូមបន្តត្រង់កថាខណ្ឌទី២៤ អង្គហេតុព្រមព្រៀងគឺមានដូចទៅនេះ "បន្ទាប់មកកាលបរិច្ឆេទខាងលើនេះត្រូវបានបក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា"។

រីឯកថាខណ្ឌទី២៥ "នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុ ត្រូវបានឧត្តសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់ សិរិមតៈ ទម្លាក់ពីតំណែង ហើយពួកគេបានបង្កើតរបបមួយឈ្មោះថា "សាធារណរដ្ឋខ្មែរ"។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេច សីហនុ បានប្រកាសអំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងបានអំពាវនាវឲ្យអ្នកស្នេហាជាតិ ធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលថ្មី"។ បាទ នេះគឺជាចំណុចព្រមព្រៀងគ្នានៅកថាខណ្ឌទី២៥។

ខ្ញុំសូមបន្តចូលកថាខណ្ឌទី២៧ ដែលជាអង្គហេតុព្រមព្រៀងគ្នាមានដូចតទៅនេះ "នៅខែធ្នូ ឆ្នាំ១៩៧០ អៀង សារី បានធ្វើដំណើរទៅហាណូយ ដើម្បីរៀបចំឡើងនូវវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា"។ ចំណុចកាលបរិច្ឆេទនេះ ខាងលោកមេធាវីការពារក្តី អៀង សារី បានផ្តល់ជាយោបល់ថាសូមកែៗមកជា "នៅដើមឆ្នាំ១៩៧១" វិញ ព្រោះអត្ថបទដើមដាក់ "នៅខែធ្នូ ឆ្នាំ១៩៧០" ប៉ុន្តែខាងមេធាវីគាត់បានស្នើថា "នៅដើមឆ្នាំ១៩៧១" វិញ។ ខុសគ្នាត្រង់កាលបរិច្ឆេទ។

[១៤:៣៣:៤៤]

អ៊ីចឹងខ្ញុំសូមអានបន្តកថាខណ្ឌ២៧ "នៅខែធ្នូ ឆ្នាំ១៩៧០ អៀង សារី បានធ្វើដំណើរទៅហាណូយ ដើម្បីរៀបចំឡើងវិញនូវវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងរបស់ អៀង ធីរិទ្ធ រហូតដល់ខែឧសភា ឆ្នាំ១៩៧៥។ បន្ទាប់មកនៅក្នុងខែមេសា ឆ្នាំ១៩៧១ គាត់បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង និងធ្វើជាបេសកជនពិសេសនៃចលនាតស៊ូខ្មែរ។ នៅឯភូមិគ្រឹះរបស់គាត់នៅទីក្រុងប៉េកាំង អៀង សារី មានទំនាក់ទំនងតាមរយៈទូរលេខផ្ទាល់ជាមួយមន្ទីរស-៧១"។ ចំណុចនេះលោកមេធាវីបានស្នើ ផ្តល់យោបល់ផ្លាស់ពី "មន្ទីរស-៧១" ដាក់ថា "មន្ទីរ១០០" វិញ។

លោកប្រធានខ្ញុំសូមអនុញ្ញាតបន្តទៅកថាខណ្ឌបន្ទាប់ទៀត គឺទាក់ទងនឹងផ្នែកទី២ រចនាសម្ព័ន្ធរដ្ឋបាល ហើយចំណុចអង្គហេតុដែលមានការព្រមព្រៀងនេះក្នុងកថាខណ្ឌទី៣៣។ ក្នុងកថាខណ្ឌទី៣៣ ខ្ញុំសូមអនុញ្ញាតអាននូវអង្គហេតុព្រមព្រៀងដូចតទៅៈ

[១៤:៣៥:១៦]

"មកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈដែលដំបូងឡើយត្រូវបានអនុម័តក្នុងឱកាសសមាជលើកទី១ របស់បក្ស នៅខែកញ្ញា ឆ្នាំ១៩៦០"។ បាទ ចំណុចនេះ មានការឯកភាពគ្នាលើអង្គហេតុដូច្នេះ។

ខ្ញុំសូមអនុញ្ញាតបន្តទៅ ការឯកភាពគ្នាលើអង្គហេតុត្រង់កថាខណ្ឌ៣៥។ ចំណុចដែលមានការព្រមព្រៀងគ្នាមានដូចតទៅ៖

"គណៈមជ្ឈិម ក៏ដូចជាគណៈអចិន្ត្រៃយ៍ មានសមាសភាពសមាជិក ពេញសិទ្ធិ និងសមាជិកត្រៀម (ឬបម្រុង) សមាជិកត្រៀម មានឋានៈទាបជាងសមាជិកពេញសិទ្ធិ។ ចំណែកឯ សមាជិកត្រៀម ត្រូវបានអនុញ្ញាតឲ្យចូលរួមប្រជុំតែប៉ុណ្ណោះ ក៏ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតសម្រេចនោះទេ"។ បាទ នេះគឺជាចំណុចឯកភាពគ្នាត្រង់កថាខណ្ឌ៣៥។

[១៤:៣៦:៤០]

លោកប្រធានជាទីគោរព អង្គសវនាការជាទីគោរព។ ខ្ញុំសូមអនុញ្ញាតបន្តទៅកថាខណ្ឌ ដែលមានការឯកភាពគ្នាត្រង់កថាខណ្ឌ៤២។ កថាខណ្ឌ៤២ បាទ ខ្ញុំសូមអាននូវអង្គហេតុដែលមានការព្រមព្រៀងគ្នា "ក្នុងនាមជាលេខាគណៈអចិន្ត្រៃយ៍ ប៉ុល ពត គឺជាអ្នកដែលមានអំណាចខ្ពស់ នៃបក្សកុម្មុយនីស្តកម្ពុជា និយាយជាមួយ ប៉ុល ពត ក៏ដូចជានិយាយនៅក្នុងអង្គប្រជុំដែរ"។ បាទ ចំណុចនេះ មានការឯកភាពគ្នាប៉ុណ្ណឹងត្រង់កថាខណ្ឌ៤២។

ចំពោះកថាខណ្ឌ៤៣ អង្គហេតុដែលមានការព្រមព្រៀងគ្នាមានដូចតទៅ៖ "នួន ជា គឺជាមនុស្សទីពីរ នៅក្នុងឋានានុក្រមគណៈអចិន្ត្រៃយ៍ ហើយបន្ទាប់មកគឺ អ៊ុង ជឿន ហៅ តាម៉ុក"។ បាទ នេះគឺជាអង្គហេតុដែលមានការព្រមព្រៀងត្រង់កថាខណ្ឌ៤៣។

ខ្ញុំសូមអនុញ្ញាតបន្តទៅកថាខណ្ឌ៩៥ ទាក់ទិនទៅនឹងប្រវត្តិសាវតាររបស់ជនជាប់ចោទ អៀង សារី។ ក្នុងកថាខណ្ឌ៩៥ ចំណុចដែលមានការព្រមព្រៀងគ្នាមានដូចតទៅ៖ "ក្នុងឆ្នាំ១៩៥០ អៀង សារី បានធ្វើដំណើរទៅទីក្រុងប៉ារីស ដើម្បីសិក្សា"។ បាទ ចំណុចនេះ មានការឯកភាពគ្នាប៉ុណ្ណឹងចំណុចក្នុងកថាខណ្ឌ៩៥។

ចំពោះកថាខណ្ឌ៩៦ អង្គហេតុដែលមានការព្រមព្រៀងគ្នា គឺមានដូចតទៅ៖ "ត្រឡប់មកដល់ទីក្រុងភ្នំពេញវិញ ក្នុងឆ្នាំ១៩៥៧ អៀង សារី គឺជាសាស្ត្រាចារ្យប្រវត្តិវិទ្យានិងភូមិវិទ្យា នៅក្នុងអនុវិទ្យាល័យឯកជនមួយឈ្មោះ "កម្ពុជបុត្រ" រហូតដល់គាត់លាក់ខ្លួនក្នុងឆ្នាំ១៩៦៣"។ បាទ នេះគឺជាអង្គហេតុ

ព្រមព្រៀងគ្នាក្នុងកថាខណ្ឌ៩៩៦។

ចំពោះកថាខណ្ឌ៩៩២ អង្គហេតុដែលមានការព្រមព្រៀងគ្នាមានដូចតទៅ៖ "ក្នុងឆ្នាំ១៩៦០ អៀង សារី បានចូលរួមក្នុងសមាជលើកទី១ របស់បក្សពលករខ្មែរ ដែលជាឈ្មោះថ្មីរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។ គាត់ត្រូវបានជ្រើសរើសជាសមាជិកគណៈមជ្ឈិម និងជាសមាជិកត្រៀម នៃគណៈអចិន្ត្រៃយ៍"។ ត្រង់កថាខណ្ឌ៩៩៧ នេះ លោកប្រធាន ខ្ញុំសូមជូនជម្រាបជូន លោកមេធាវីការពារក្តីបានស្នើផ្តល់ជាយោបល់ឲ្យលុបពាក្យ "ជ្រើសរើស" ប្តូរមកជា "ជាសមាជិកគណៈមជ្ឈិមវិញ"។ ខ្ញុំសូមអានឡើងវិញ ឃ្លាដើមគឺ "គាត់ត្រូវបានជ្រើសរើសជាសមាជិកគណៈមជ្ឈិម និងជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍"។ លោកមេធាវីបានស្នើដូច្នេះថា គាត់ត្រូវបានក្លាយជាសមាជិកគណៈមជ្ឈិម និងសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍វិញ ដោយលុបពាក្យ "ជ្រើសរើស" ចេញ និងលុបពាក្យ "ត្រៀម" ចេញ ដាក់ "ពេញសិទ្ធិ"។

[១៤:៤០:២៧]

លោកប្រធានជាទីគោរព! ចំពោះកថាខណ្ឌ៩៩៨ អង្គហេតុដែលមានការព្រមព្រៀងគ្នាមានដូចតទៅ៖ ក្នុងខែមេសា ឆ្នាំ១៩៦៣ ក្រោយពីសម្តេច នរោត្តម សីហនុ បានចាត់ទុកគាត់ជាអ្នកឆ្វេងនិយមម្នាក់ក្នុងចំណោមអ្នកឆ្វេងនិយមចំនួន៣៤នាក់។ អៀង សារី បានភៀសខ្លួនទៅព្រំដែនវៀតណាម ដើម្បីចូលរួមជាមួយ សុន សេន និង ប៉ុល ពត។ ត្រង់ឃ្លាចុងក្រោយនេះ លោកមេធាវីបានផ្តល់ជាយោបល់ ហើយគាត់ស្នើឲ្យមានការផ្លាស់ប្តូរដូច្នេះ "អៀង សារី បានភៀសខ្លួនទៅព្រំដែនវៀតណាម ដើម្បីចូលរួមជាមួយ សុន សេន" គាត់សូមស្នើប្តូរពាក្យយ៉ាងដូច្នេះថា "អៀង សារី បានភៀសខ្លួនទៅព្រំដែនវៀតណាម ក្នុងអំឡុងពេលជាមួយគ្នា ជាមួយ សុន សេន" បាទ គឺគាត់សុំប្តូរពាក្យថា "ក្នុងអំឡុងពេលជាមួយគ្នា ជាមួយ សុន សេន វិញ" និង ប៉ុល ពត គាត់សុំលុបពាក្យ ប៉ុល ពត-- អ៎ លុបពាក្យ "និង" (សូមទោស) លុបពាក្យ "និង" សុំលុបពាក្យ "និង" ប្តូរមកជា "ចូលរួមជាមួយ ប៉ុល ពត វិញ"។ អ៊ីចឹង ឃ្លាដើមដាក់ថា "និង ប៉ុល ពត" តែគាត់សុំប្តូរថា "ចូលរួមជាមួយ ប៉ុល ពត វិញ"។

[១៤:៤២:០០]

បាទ ខ្ញុំសូមបន្តក្នុងកថាខណ្ឌ៩៩៨ដដែល។ ក្នុងឆ្នាំ១៩៦៦ អៀង សារី និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត។ ត្រង់ចំណុចនេះ គាត់សុំលុបពាក្យ "មេដឹកនាំ" លុបពាក្យ "មេដឹកនាំ" ដាក់ថា "សមាជិក" វិញ។ នេះជាយោបល់របស់លោកមេធាវីការពារក្តី អៀង សារី។ អ៊ីចឹង ឃ្លាដើមគឺ១៩៦៦

អៀង សារី និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គាត់ស្នើថា ក្នុងឆ្នាំ១៩៦៦ អៀង សារី និងសមាជិកបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត បានប្តូរទីតាំងទៅនៅក្នុងខេត្តរតនគិរី ភូមិភាគឦសាន ជាទីកន្លែងដែលទីស្នាក់ការថ្មីរបស់គណៈមជ្ឈិមបានតាំងនៅ។ ដូច្នេះ អៀង សារី បានក្លាយជាលេខាភូមិភាគឦសាន។ បាទ អ៊ីចឹង កថាខណ្ឌចុងក្រោយនេះគាត់-- លោកមេធាវីគ្រាន់តែស្នើឲ្យលុបពាក្យ “មេដឹកនាំ” មកប្តូរជា “សមាជិក” វិញ។

ចំពោះកថាខណ្ឌ៩៩៩ សំអាងហេតុដែលមានការព្រមព្រៀងមានដូចតទៅៈ

ក្នុងឆ្នាំ១៩៧០ អៀង សារី បានធ្វើដំណើរទៅទីក្រុងហាណូយ ជាទីកន្លែងដែលគាត់បង្កើតស្ថានីយវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ដែលគ្រប់គ្រងដោយ អៀង ធីរិទ្ធ។ អៀង សារី បានធ្វើដំណើរពីទីក្រុងហាណូយទៅទីក្រុងប៉េកាំង ដើម្បីចងសម្ព័ន្ធភាពជាមួយបក្សកុម្មុយនីស្តចិន។ នៅឆ្នាំ១៩៧១ អៀង សារី បានតាំងមូលដ្ឋានជាអចិន្ត្រៃយ៍នៅទីក្រុងប៉េកាំង។ ស្របពេលជាមួយគ្នានោះ គាត់បានធ្វើជាបេសកជនពិសេសនៃអ្នកតស៊ូផ្ទៃក្នុងនៅក្រុងប៉េកាំង និងទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយសម្តេចនរោត្តម សីហនុ។

ក្នុងអំឡុងពេលនោះ អៀង សារី បានមកកម្ពុជាចំនួនពីរដង។ គឺម្តងនៅក្នុងឆ្នាំ១៩៧៣ នាពេលដែលគាត់អមដំណើរសម្តេចនរោត្តម សីហនុ ទៅពិនិត្យមើលតំបន់រំដោះ និងម្តងទៀត ក្នុងឆ្នាំ១៩៧៤ គាត់ត្រឡប់មកកម្ពុជាជាអចិន្ត្រៃយ៍ក្នុងខែមេសា ឆ្នាំ១៩៧៥។

[១៤:៤៤:៥៥]

លោកប្រធាន ជាទីគោរព! ចំពោះអង្គហេតុនៅក្នុងកថាខណ្ឌ៩៩៩នេះ គឺគ្មានការផ្លាស់ប្តូរទេ ថែមថយទេ ប៉ុន្តែអ្វីដែលខ្ញុំអាននេះគឺជាចំណុចដែលមានការឯកភាពគ្នា ហើយមានពីរបីឃ្លានោះគឺមិនមានការឯកភាពគ្នាទេ។ ហើយឥឡូវខ្ញុំសូមអនុញ្ញាតចុងក្រោយនូវចំពោះការអានអង្គហេតុព្រមព្រៀងរបស់ខ្ញុំ នៅក្នុងកថាខណ្ឌ១.០០០ កថាខណ្ឌត្រង់ចំណុច១.០០០។ នេះគឺជាចំណុចក្រោយរបស់ខ្ញុំបាទ។

អង្គហេតុដែលមានការព្រមព្រៀងក្នុងកថាខណ្ឌ១.០០០ គឺក្នុងអំឡុងរបបកុម្មុយនីស្តកម្ពុជាៗ អៀង សារី បានប្រើឈ្មោះបដិវត្តន៍របស់គាត់ គឺឈ្មោះ វ៉ាន់។ បាទមានការឯកភាពគ្នាប៉ុណ្ណឹងបាទ។

លោកប្រធាន ខ្ញុំសូមអរគុណចំពោះលោកប្រធានដែលបានអនុញ្ញាតខ្ញុំអាននូវអង្គហេតុព្រមព្រៀងនៅពេលនេះ ហើយខ្ញុំសូមបញ្ចប់ការអានរបស់ខ្ញុំតែប៉ុណ្ណេះ។

សូមអរគុណលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាជាតិ។

ជាបន្តអង្គជំនុំជម្រះសូមអញ្ជើញមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ឡើងបញ្ជាក់អំពីអង្គហេតុដែលបានព្រមព្រៀង ឬអង្គហេតុដែលមិនមានការជំទាស់តវ៉ា ដែលបានបង្ហាញឡើងដោយតំណាងសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ។

[១៤:៤៦:១៩]

**លោក ម៉ៃខល កាណាវាស៖**

ជាថ្មីម្តងទៀត សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ វាជាការត្រឹមត្រូវដែលថាការអាននោះត្រឹមត្រូវហើយ យើងក៏បានដាក់ជាលាយលក្ខណ៍អក្សរ។ ហើយយើងក៏បានធ្វើការពិនិត្យ និងមានការបង្គាប់ណែនាំទៅដល់កូនក្ដីរបស់យើងខ្ញុំផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកមេធាវី។

ហើយជាកិច្ចបន្ត តើមានភាគីណាត្រូវបាន-- ត្រូវមានបំណងដាក់ឯកសារទៀតដែរឬទេ នៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

[១៤:៤៧:០០]

បាទ ប្រសិនបើមិនមានទេ តាមកាលវិភាគកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឃើញថាអស់បញ្ហាដែលត្រូវពិភាក្សាដេញដោលហើយៗ បញ្ហានឹងលើកទៅបន្តធ្វើសវនាការនៅសប្តាហ៍ក្រោយចាប់ផ្តើមពីថ្ងៃចន្ទ។

សូមអញ្ជើញ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានសូមគោរព។ យើងពុំមានឯកសារបង្ហាញនៅរសៀលនេះទេ គឺថាយើងនឹងបង្ហាញឯកសារនៅសប្តាហ៍ក្រោយ បន្ទាប់ពីសហព្រះរាជអាជ្ញាបានធ្វើទៅ គឺថាអនុលោមទៅតាមអនុស្សរណៈដែលអង្គជំនុំជម្រះបានផ្តល់ជូន។

**ប្រធានអង្គជំនុំ៖**

បាទ ដោយមិនមានបញ្ហាអីត្រូវលើកយកមកពិភាក្សា ឬក៏ដាក់ឯកសារភស្តុតាងនៅចំពោះមុខ

អង្គជំនុំជម្រះ ឬភាគីទៀតទេ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺត្រូវផ្អាកត្រឹមនេះ សវនាការនឹងលើកទៅបន្តធ្វើនៅសប្តាហ៍ក្រោយចាប់ផ្តើមពីថ្ងៃចន្ទ បន្តធ្វើនៅថ្ងៃចន្ទ ទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញលោក១ មេធាវីការពារក្តី អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន។ គឺតាមខ្ញុំអ្វីដែលខ្ញុំដឹងនោះ ការបកប្រែនោះគឺយើងលើកឡើងថា យើងខ្ញុំបង្គាប់ទៅខាងជនកូនក្តីរបស់យើងខ្ញុំ ក៏ប៉ុន្តែយើងខ្ញុំចង់បានន័យថា កូនក្តីរបស់ខ្ញុំធ្វើការណែនាំជូនមេធាវីការពារក្តី យើងខ្ញុំមិនបានធ្វើការបង្គាប់ជូនទៅដល់កូនក្តីនោះទេ។ សូមអរគុណលោកប្រធាន។

[១៤:៤៨:៥៦]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់ និងកែតម្រូវដូច្នេះ។

បាទ ឥឡូវនេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក គឺថ្ងៃចន្ទសប្តាហ៍ក្រោយនេះ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

សូមអញ្ជើញសម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៤:៥០ នាទី)*